# មជ្ឈមណ្ឌលឯកសារកម្ពុជា

សម្ភាសន៍លើកៈ ទី១

អ៊ុល ហឿន ភេទប្រុស អាយុ៧៥ឆ្នាំ

ស្រុកកំណើតនៅភូមិត្រពាំងប្រីយ៍ ឃុំត្រពាំងធំខាងត្បូង ស្រុកត្រាំកក់ ខេត្តតាកែវ

រស់នៅភូមិតាសាញជើង ឃុំតាសាញ ស្រុកសំឡូត ខេត្តបាត់ដំបង

មុខងារសម័យខ្មែរក្រហមៈ សមាជិកស្រុកត្រាំកក់

ថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៣

សម្ភាសន៍ដោយៈ ឡុង ដានី

០១:៣១:២១

៤៩ទំព័រ

ដានីៈ ជំរាបសួរ ដំបូងខ្ញុំចង់ណែនាំខ្លួនខ្ញុំមួយសារទៀតឲ្យអ៊ំស្គាល់កុំឲ្យអ៊ំនេះ ពួកខ្ញុំពីរនាក់នេះមកពីភ្នំពេញមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយពួកខ្ញុំគឺ ជាទូទៅចុះស្រាវជ្រាវយើងប្រមែលប្រមូលចងក្រងឯកសារប្រវត្តិសាស្ត្រ ជាពិសេសគឺជំនាន់៣ឆ្នាំ ពីឆ្នាំ៧៥-៧៩ ។

ហឿនៈ ខ្ញុំដឹងតែរឿង៣ឆ្នាំទេ ក្រៅពីហ្នឹងអត់ដឹងទេ ។

ដានីៈ ហើយការចងក្រងហ្នឹងដើម្បីទុកឲ្យក្មេងៗជំនាន់ក្រោយ សំរាប់អ្នកសិក្សាស្រាវជ្រាវដែលគេចង់ដឹង គេចង់សរសេរ គេចង់អានពីរឿងរ៉ាវពីសម័យ៣ឆ្នាំ គេអាចអាន គេអាចសរសេរ ឬក៏គេទៅអាននៅមជ្ឈមណ្ឌលឯកសារកម្ពុជាបាន ។ ខ្ញុំឈ្មោះដានី ហើយគាត់ឈ្មោះវណ្ណៈ ។ អីចឹងអ៊ំខ្ញុំសុំសួរអ៊ំជាពិសេសទាក់ទងប្រវត្តិអ៊ំ អ្វីដែលអ៊ំដឹង អ៊ំអាចជួយជំរាបប្រាប់ខ្ញុំផងបានទេ?

ហឿនៈ ប្រាប់បាន ខ្ញុំប្រាប់តែតាមការពិត អត់និយាយបំផ្លើសទេ ។

ដានីៈ អីចឹងដំបូងខ្ញុំចង់ស្គាល់ឈ្មោះអ៊ំ?

ហឿនៈ ឈ្មោះ អ៊ុល ហឿន ។

ដានីៈ "អ"!

ហឿនៈ "អ៊ុយ" និង "អិល" ។

ដានីៈ អ៊ុល ហឿន ។

ហឿនៈ នៅភូមិត្រពាំងប្រិយ៍ ។

ដានីៈ អ៊ំអាយុប៉ុន្មានហើយសព្វថ្ងៃ?

ហឿន៖ ឥឡូវហ្នឹង៧៥ហើយ ។

ដានី៖ អ៊ីកំណើតអ៊ីនៅណាទៅ?

ហឿន៖ នៅក្នុងភូមិត្រពាំងប្រីយ៍ ឃុំត្រពាំងធំខាងត្បូង ឃុំខ្ញុំចែកជាពីរក៏នៅតែធំដែរ ។

ដានី៖ ស្រុក?

ហឿន៖ ស្រុកត្រាំកក់ ។

ដានី៖ ខេត្តតាកែវ?

ហឿន៖ បាទ!

ដានី៖ សព្វថ្ងៃអ៊ីរស់នៅក្នុងភូមិអីដែរ?

ហឿន៖ ឥឡូវនេះ?

ដានី៖ បាទ!

ហឿន៖ នៅក្នុងភូមិតាសាញដើង ។

ដានី៖ ឃុំអីដែរ?

ហឿន៖ ឃុំតាសាញដែរ ស្រុកសំឡូត ខេត្តបាត់ដំបង ។

ដានី៖ អ៊ីគ្រួសារអ៊ីគាត់ឈ្មោះអីដែរ?

ហឿន៖ ជា នី ។

ដានី៖ គាត់អាយុប៉ុន្មានដែរ?

ហឿន៖ ប្អូនខ្ញុំ វាខ្ទង់ ខ្ញុំ៧៥ យាយហ្នឹងប្អូនខ្ញុំ៦ឆ្នាំកាលខ្ញុំអាយុ២១ ឥឡូវហ្នឹងខ្ទង់ ។

ដានី៖ ប្អូនអ៊ី៦ឆ្នាំ?

ហឿន៖ បាទ! ប្អូន៦ឆ្នាំ ។

ដានី៖ អីចឹងអ៊ី៧៥ គាត់៦៩?

ហឿន៖ បាទ! ខ្ញុំគិតឃើញប៉ុណ្ណឹងដែរ ។

ដានី៖ អាយុ៦៩ឆ្នាំ?

ហឿន៖ បាទ!

ដានី៖ អ៊ីស្រីគាត់អ្នកស្រុកកំណើតនៅណាដែរ?

ហឿន៖ នៅជាមួយគ្នា ភូមិជាមួយគ្នា ឃុំជាមួយគ្នា ។

ដានី៖ ភូមិ-ឃុំជាមួយគ្នា?

ហឿន៖ បាទ!

ដានី៖ អ៊ំមានកូនចៅទាំងអស់ប៉ុន្មាននាក់ដែរ?

ហឿន៖ កូនខ្ញុំ៧នាក់ តែស្លាប់បាត់មួយហើយ ចូលព្រៃ ។

ដានី៖ ប្រុសប៉ុន្មាន ស្រីប៉ុន្មាន?

ហឿន៖ ស្រីវាតែ២ ប្រុស៤ ។

ដានី៖ ស្រី២ ប្រុស៤ = ៦នាក់ ។

ហឿន៖ ងាប់មួយអត់និយាយ ។

ដានី៖ ស្លាប់ម្នាក់ហ្នឹងស្រី ឬប្រុស?

ហឿន៖ ប្រុស ។

ដានី៖ ឪពុកអ៊ំឈ្មោះអីដែរ?

ហឿន៖ ឪពុកខ្ញុំឈ្មោះឯក ។

ដានី៖ អ៊ីឯកទៅ?

ហឿន៖ អ៊ុល ឯក ខ្ញុំដាក់ឈ្មោះ អ៊ុល ហឿន ដែរ ។

ដានី៖ គាត់ស្លាប់តាំងពីអង្កាល់ទៅ?

ហឿន៖ ស្លាប់ឆ្នាំ៧៧ ទៅស្លាប់នៅភ្នំពេញហ្នឹង ដាក់ពេទ្យអីគេទេ ។

ដានី៖ ស្លាប់ឆ្នាំ៧៧ នៅភ្នំពេញ?

ហឿន៖ បាទ! អត់បានទៅឃើញសព គេកប់ចោលណាបាត់ ។

ដានី៖ ម្ដាយ?

ហឿន៖ ម្ដាយឈ្មោះ ណាំ ហង ម្ដាយខ្ញុំយួនគេរកតែរឿង អាប្អូនខ្ញុំគេចាប់ដាក់គុក ។

ដានី៖ ណាំ ហង គាត់ស្លាប់ឆ្នាំណាទៅ?

ហឿន៖ ស្លាប់ឆ្នាំ៨៧ ។

ដានី៖ ចុះម្ដាយអ៊ំគាត់វៀតណាម?

ហឿន៖ បាទ!

ដានី៖ វៀតណាមមកពីស្រុកវៀតណាមតែម្ដង ឬយ៉ាំងម៉េច?

ហឿន៖ យាយខ្ញុំមកពីស្រុកវៀតណាម ម៉ែខ្ញុំនៅកើតកំណើតនៅស្រុកខ្មែរនេះ តាខ្ញុំមកអត់ចេះខ្មែរ ហើយតាខ្ញុំមកយកយាយខ្ញុំ ។ យាយខ្ញុំចេះខ្មែរអត់មានយួនទេ តាខ្ញុំយួនចំតែម្ដង នៅខេត្តចូវដុកគេហៅខេត្តក្របៅ-មាត់ជ្រូក ។

ដានី៖ ចុះម្ដាយអ៊ំគាត់ចេះយួនច្បាស់?

ហឿនៈ ចេះខ្ទិច អីចឹងបានគេរករឿង។

ដានីៈ អ៊ំចេះអត់?

ហឿនៈ អត់ចេះ ចេះតែម៉ែខ្ញុំ។

ដានីៈ អ៊ំមានបងប្អូនបង្កើតទាំងអស់ប៉ុន្មាននាក់?

ហឿនៈ ឈប់ខ្ញុំរាប់ ទីមួយយាយគុជ(ស្រី) , ទីពីរតាយ៉ែវ, ទីបីតាហេង, ទីបួនខ្ញុំ, ទីប្រាំអាញ៉ូន, ទីប្រាំមួយអន្ទិតញ៉ឹន នៅនេះ អាញ៉ូន មុននៅនេះដែរ។

ដានីៈ ទីមួយឈ្មោះគុជ។

ហឿនៈ យាយគុជ។

ដានីៈ ទីពីរ?

ហឿនៈ តាយ៉ែវ ហើយទីបី តាហេង, ទីបួនខ្ញុំហ្នឹងហើយ តាហឿន ហើយទីប្រាំ ញ៉ូន ហើយទីប្រាំមួយ ញ៉ឹន។

ដានីៈ គាត់នៅណា ញ៉ូន?

ហឿនៈ ឥឡូវនៅត្រាំកក់ តែមុននៅរកស៊ីនេះ។

ដានីៈ ទី៤អ៊ំ, ទី៥ ញ៉ូន, ទី៦ ញ៉ឹន។

ហឿនៈ ញ៉ឹន!

ដានីៈ ៦នាក់អ៊ំ?

ហឿនៈ បាទ!

ដានីៈ អីចឹងស្រីតែមួយ តែបងគេមួយ ក្រៅពីហ្នឹងប្រុសទាំងអស់?

ហឿនៈ តែមួយគត់ស្រី។

ដានីៈ អ៊ំកាលពីក្មេងៗ អ៊ំបានរៀនសូត្រដល់ណាដែរ?

ហឿនៈ ខ្ញុំរៀនថ្នាក់ទី៧ដែរ ឈប់ឆ្នាំ១៩៥៧ ចប់ចូលរៀន វាអត់លុយ ឆ្នាំ៥៧ស្តេចទៅលេងស្រុក ទៅសម្ពោធន៍នៅវត្តត្រពាំងធំ គេបង្គាប់ទិញខោអាវយុវត្ត ខ្ញុំអត់មានលុយទិញ ខ្ញុំខ្មាសគេឈប់ទៅ។

ដានីៈ ឆ្នាំ៥៧?

ហឿនៈ ឈប់ឆ្នាំ៥៧។

ដានីៈ ឈប់ឆ្នាំ៥៧ដោយសារអ៊ំអត់លុយទិញខោអាវពេលដែលសម្តេចឪទៅលេងនៅត្រពាំងធំ។

ហឿនៈ ឲ្យស្លៀកពាក់យុវ័ន្ត។

ដានី៖ ខ្មាសគេក៏ឈប់រៀនទៅ?

ហឿន៖ ឈប់ទៅ ។

ដានី៖ បានថ្នាក់ទី៧ដែលកាលហ្នឹង?

ហឿន៖ បាទ!

ដានី៖ អ៊ំចេះច្រើនដែលកាលហ្នឹង?

ហឿន៖ រៀងចេះកាលហ្នឹង គេឲ្យរៀនបារាំងទាំងអស់ បារាំងហើយនិងខ្មែរ បារាំងចេះច្រើនជាង សរសេរបារាំងបាន១០ សរសេរខ្មែរបាន៧-៨ គេរៀនតែបារាំងសុទ្ធជំនាន់ហ្នឹង ។

ដានី៖ ដល់ពេលអ៊ំឈប់រៀនហើយ អ៊ំធ្វើអីទៀតទៅ?

ហឿន៖ ធ្វើស្រែរហូត ។

ដានី៖ ធ្វើស្រែជាមួយពីណាទៅ?

ហឿន៖ ធ្វើជាមួយឪពុកម្ដាយ៥ឆ្នាំ បានខ្ញុំការហើយបានខ្ញុំបែក ។

ដានី៖ ឪពុកម្ដាយ៥ឆ្នាំ?

ហឿន៖ ហើយខ្ញុំបែករកស៊ី២នាក់ប្ដីប្រពន្ធ ។

ដានី៖ ការឆ្នាំណាអ៊ំ?

ហឿន៖ ខ្ញុំការឆ្នាំ១៩៥៩ ខ្វះមួយឆ្នាំ៦០ ។

ដានី៖ ៥៩ ការជាមួយអ៊ំស្រី?

ហឿន៖ តែមួយហ្នឹង ។

ដានី៖ ការឆ្នាំ៥៩ ការហើយរកស៊ីបែកពីឪពុកម្ដាយ?

ហឿន៖ បែកពីឪពុកម្ដាយ រកស៊ីរៀងខ្លួន ។

ដានី៖ បែកពីឪពុកម្ដាយទៅនៅណាវិញ?

ហឿន៖ ចេញមកនៅវាលស្រែខាងលិច ជាប់ៗហ្នឹងដែរ ។

ដានី៖ នៅក្នុងភូមិដដែល?

ហឿន៖ នៅក្នុងភូមិដដែល ។

ដានី៖ ដល់ពេលចេញមកយើងការហើយប្ដីប្រពន្ធ យើងរកស៊ីធ្វើតែស្រែទេ?

ហឿន៖ បាទ! រកស៊ីធ្វើស្រែហើយថ្ងៃឡើងទៅកាប់ឈើនៅភ្នំ ដឹកឈើលក់ ។

ដានី៖ ភ្នំអីគេហ្នឹង?

ហឿន៖ ភ្នំដីវីរមៀល រកស៊ីឡើងតែភ្នំ ។

ដានី៖ អ៊ំរកស៊ីអីចឹងដល់ឆ្នាំណាទៅ?

ហឿន៖ ដល់ឆ្នាំ១៩៧០ គេធ្វើរដ្ឋប្រហារ ខ្ញុំរកស៊ីទិញរបស់របរមាន់ ទា យកទៅលក់ឲ្យយួន យួនមកនៅក្នុងស្រុកពេញ រែកមាន់ រែកទា រែកដូងលក់ឲ្យយួន។

ដានី៖ លក់មាន់ឲ្យយួន?

ហឿន៖ មួយគីឡូ១៥០០ឥឡូវហ្នឹង កាលហ្នឹងតែ១៥ទេ។

ដានី៖ ហើយម៉េចទៀតទៅបន្ទាប់ពីរកស៊ីលក់?

ហឿន៖ ដល់ហើយពីហ្នឹងទៅឆ្នាំ១៩៧៣ គេឲ្យខ្ញុំធ្វើប្រធានក្រុម។

ដានី៖ ឆ្នាំ១៩៧៣ ឲ្យធ្វើប្រធានក្រុមខាងណា?

ហឿន៖ ខាងខ្មែរក្រហមហ្នឹង។

ដានី៖ នៅណាដែរអ៊ំ?

ហឿន៖ នៅស្រុកដដែល នៅភូមិដដែល។

ដានី៖ ប្រធានក្រុមហ្នឹងក្នុងភូមិទេ?

ហឿន៖ ក្នុងភូមិ ក្រុមទី៤។

ដានី៖ ប្រធានក្រុមខ្មែរក្រហម?

ហឿន៖ ជំនាន់ប៉ុល ពត ហើយធ្វើប្រធានក្រុមដល់ឆ្នាំ៧៤គេឲ្យខ្ញុំធ្វើអនុភូមិ។

ដានី៖ ឆ្នាំ៧៤ឡើងអនុភូមិ?

ហឿន៖ បាទ!

ដានី៖ ពីណាអ្នកតែងតាំងអ៊ំ?

ហឿន៖ កាលហ្នុងគណៈស្រុក តាជីម ហ្នឹង។

ដានី៖ តាជីម គាត់តែងតាំង?

ហឿន៖ ព្រាប ជឹម ឥឡូវនៅតែហៅអីចឹង តែអត់ហៅតាទេ ប៉ុន្តែដាច់ដៃម្ខាងបាត់ហើយ គេទៅបាញ់ ដេកនៅអង្រឹងគេបាញ់សម្លាប់ មិនត្រូវខ្លួនទៅត្រូវដៃ អត់ងាប់។

ដានី៖ ឈ្មោះព្រាប ជឹម។ ហើយអ៊ំធ្វើអនុប្រធានភូមិហ្នឹងដល់ពេលណា?

ហឿន៖ ដល់ឆ្នាំ៧៥រំដោះទូទាំងប្រទេស គេហៅខ្ញុំទៅនៅមន្ទីរស្រុក។

ដានី៖ ឆ្នាំ៧៥បែក។

ហឿន៖ រំដោះហើយគេហៅខ្ញុំក្នុងថ្ងៃហ្នឹងតែម្តង។

ដានី៖ ផ្លាស់ទៅមន្ទីរស្រុក?

ហឿនៈ ហ្នឹងហើយ មន្ទីរស្រុក ។

ដានីៈ មន្ទីរស្រុកត្រាំកក់ហ្នឹង?

ហឿនៈ ហ្នឹងហើយ ។

ដានីៈ ទៅធ្វើអីទៅ?

ហឿនៈ ទៅលើកដាក់លីសែងសម្ភារៈគេដឹកអង្ករ ដឹកស្បៀងមកឲ្យប្រជាជនដែលគេជម្លៀសមកពីភ្នំពេញ ខ្ញុំលីអង្ករតែគ្នាពីរនាក់ តែ២ឡានហើយអង្ករ៦០បាវលីចង់ងាប់ លីទាំងយប់ លីទាំងថ្ងៃ គ្នា២នាក់ ។

ដានីៈ គ្នា២នាក់ពីណាគេទៅ?

ហឿនៈ ក្មេចឈ្មោះបាត់ ងាប់បាត់អស់ហើយ តាផន ងាប់ៗតាំងពីនៅក្នុងប្រទេស ។

ដានីៈ មកចែកឲ្យប្រជាជនថ្មី?

ហឿនៈ បាទ!

ដានីៈ ពីណាគេអ្នកហៅអ៊ំទៅមន្ទីរស្រុក?

ហឿនៈ តាជឹម ហ្នឹងតែម្តង ។

ដានីៈ តាជឹម ហ្នឹងនៅរស់ទេ?

ហឿនៈ នៅ ។

ដានីៈ នៅណាឥឡូវ?

ហឿនៈ ឥឡូវនៅភូមិស្រុកប្រាសាទ ។

ដានីៈ ត្រពាំងប្រាសាទ ។

ហឿនៈ ស្រុកត្រពាំងប្រាសាទ វាអត់សូវចាំ គាត់នៅហ្នឹង នៅជិប្រពន្ធចុង ។

ដានីៈ ទៅមន្ទីរស្រុកត្រាំកក់ទៅលីអង្ករ យកសម្ភារៈមកចែកឲ្យប្រជាជនថ្មីរយៈពេលប៉ុន្មានថ្ងៃទៅ?

ហឿនៈ ចែកដល់៧៦បានចប់ លែងមានហើយ អស់អង្ករហើយ ចិនលែងឲ្យ ។

ដានីៈ ដល់៧៦?

ហឿនៈ ៧៦ ។

ដានីៈ អីចឹងអង្ករ សម្ភារៈច្រើន?

ហឿនៈ គេដឹកទៅតែអង្ករមួយមុខ ។

ដានីៈ កាលហ្នឹងអ៊ំធ្វើតួនាទីអីទៅ?

ហឿនៈ បាទ?

ដានីៈ តួនាទីអីអីគេ?

ហឿនៈ អត់មានតួនាទីអីផង គ្រាន់តែទៅជួយលើកដាក់អង្ករ លីសែងគេចេញពីឡាន ដល់យ៉ាប់ទៅ គេឲ្យអ្នកទោស ពួកសាលាកែប្រែ ជាប់គុក៣-៤ខែគេឲ្យទៅស្រុកវិញ ទៅផ្ទះវិញ ហៅគេមកជួយដាក់លីសែង ខ្ញុំទំនេរបន្តិច អ្នកហ្នឹងដូចថាខូចប្រពន្ធកូនគេ គេអត់ធ្វើអី គេដាក់គុក២-៣ខែគេអប់រំហើយគេឲ្យទៅវិញ ។

ដានីៈ ពីណាគេដាក់គុក?

ហឿនៈ មេស្រុក តាជីម ហ្នឹង ។

ដានីៈ តាជីម ហ្នឹងឃុំឃាំងពីណាគេ? អ្នកយ៉ាងម៉េច?

ហឿនៈ ឃុំឃាំងដូចថា យុទ្ធជនទៅសមរភូមិ អាប្រធានភូមិ ប្រធានក្រុមនៅក្រោយខូចប្រពន្ធគេ ចាប់ទៅដាក់ យកទៅកែប្រែ ។

ដានីៈ ខុសសីលធម៌?

ហឿនៈ ហ្នឹងហើយរឿងសីលធម៌ ដល់កែប្រែហើយឲ្យគេមកផ្ទះគេវិញមក អត់មានសម្លាប់ទេហ្នឹង សាលាកែប្រែ ។

ដានីៈ បានន័យថាអ្នកមានប្រពន្ធហ្នឹង ប្ដីគេទៅសមរភូមិបាត់ទៅ?

ហឿនៈ ទៅបាត់ ។

ដានីៈ ហើយអ្នកនៅស្រុកហ្នឹងមានខូចសីលធម៌ជាមួយប្រពន្ធកូនគេ គេចាប់ដែរ?

ហឿនៈ តែអីចឹង ។

ដានីៈ តែគេអត់សម្លាប់ទេ?

ហឿនៈ អត់សម្លាប់ទេ គេសម្រាលទោស ។

ដានីៈ គេសម្រាល?

ហឿនៈ បាទ!

ដានីៈ ពី៧៥ អ៊ំជាមួយប្រពន្ធកូននៅជុំគ្នាដែរ?

ហឿនៈ អត់ទេ ប្រពន្ធខ្ញុំនៅរែកដី ។

ដានីៈ ប្រពន្ធនៅរែកដី?

ហឿនៈ បាទ! ប្រពន្ធខ្ញុំរែកដី កូនខ្ញុំអាពៅគ្រប់ខែ យាយខ្ញុំហើមដៃហើមជើង សុំគេទៅផ្ទះ ទៅសម្រាលកូន គេថាអត់ទេ មានពេទ្យអីនៅផ្ទះទេ ពេទ្យនៅនេះ បើកូនងើតទៅពេទ្យទៅដល់

ខ្ញុំ ទៅមើលយាយខ្ញុំនៅវែកដីដឹបូកខែប្រាំង កាប់ណាមុតហើយចេះតែវែកទៅ ដល់ខ្ញុំទៅឃើញយាយខ្ញុំឃើញហើមដៃ ហើមជើង យាយខ្ញុំថាអត់ស្រួលទេ ខ្ញុំយកដាក់ពេទ្យស្រុកៗកើតថ្ងៃហ្នឹង ។

ដានី: ពេទ្យស្រុកណា?

ហឿន: ពេទ្យស្រុកត្រាំកក់ ។

ដានី: អ៊ំទៅយកមកដាក់ពេទ្យ គេឲ្យទៅយកដែរ?

ហឿន: អត់ហ៊ានទេ ឃើញខ្ញុំទៅខ្លាចខ្ញុំដាងខ្លាទៀត ឃើញខ្ញុំនៅមន្ទីរស្រុក ។

ដានី: ឃើញអ៊ំនៅមន្ទីរស្រុក អីចឹងអ៊ំទៅកន្លែងវែកដីគេខ្លាចអ៊ំ?

ហឿន: គេខ្លាចអត់ហ៊ានមាត់កដង ។

ដានី: ពីណាគេអ្នកនៅខាងហ្នឹង?

ហឿន: បាទ?

ដានី: អ្នកនៅខាងមូលដ្ឋានហ្នឹង?

ហឿន: នៅខាងកងចល័តគេហ្នឹង ឈ្មោះស្អីទេ ភ្លេចឈ្មោះហើយ អត់នឹកឃើញទេឈ្មោះអស់ហ្នឹង ភ្លេចអស់ហើយ... ។

ដានី: អ៊ំយកមកដាក់មន្ទីរពេទ្យស្រុកត្រាំកក់ កាលហ្នឹងពីណាគេប្រធានមន្ទីរពេទ្យស្រុក?

ហឿន: ប្រធានហ្នឹងឈ្មោះតាសន អត់ស្គាល់ដូនតាគាត់ ។

ដានី: រៀល សន?

ហឿន: មិនដឹងអីសន អត់ស្គាល់គាត់ ។

ដានី: គាត់ប្រធានពេទ្យ?

ហឿន: កូនគាត់អាឈ្មោះអាគូ មួយ ។

ដានី: កូនគាត់នៅស្រុកដែរ?

ហឿន: នៅស្រុក ស្លូតណាស់អត់ចេះរករឿងអ្នកណាទេ ។

ដានី: កាលហ្នឹងអ៊ំមានកូនប៉ុន្មាននាក់ ពេលនៅហ្នឹង?

ហឿន: កូនខ្ញុំ៦នាក់ដដែលហ្នឹង ។

ដានី: កាលហ្នឹង៦នាក់ហើយ ។

ហឿន: បាទ! ៦នាក់ ។

ដានី: អ៊ំបានកូន៦ហើយពេលដល់ឆ្នាំ ។

ហឿនៈ បាទ!

ដានីៈ ចុះឪពុកម្ដាយអ៊ំកាលហ្នឹងគាត់នៅណាទៅ?

ហឿនៈ នៅភូមិជាមួយខ្ញុំ កាលហ្នុងគាត់ចាស់ជរាដែលហើយ ៧៧ ។

ដានីៈ គាត់ចាស់ជរាហើយ ចុះម្ដាយអ៊ំជាវៀតណាមអីចឹងគេអត់ធ្វើអីទេ?

ហឿនៈ គេរករឿងដែលហ្នឹង តែបានបងខ្ញុំខ្មោចតាហេង មេទ័ពធំ កងពល កងចល័តព្រំដែន ដល់បេ៥២ទម្លាក់ស្លាប់៧៣ ហើយតាយ៉ែវ បងខ្ញុំគាត់ធ្វើចៅហ្វាយស្រុកកោះអណ្ដែត ។

ដានីៈ តាយ៉ែវ ហ្នឹងគាត់ធ្វើចៅហ្វាយស្រុកកោះអណ្ដែតឆ្នាំណា?

ហឿនៈ ទល់ឆ្នាំយួនចូលស្រុកបានរត់ចេញ ។

ដានីៈ ចៅហ្វាយកោះអណ្ដែតជាមួយពីណាគេខ្លះ?

ហឿនៈ កាលហ្នឹងឈ្មោះតាសឿនៗ តាយ៉ែវ ហ្នឹងអនុទេ តាសឿនហ្នឹងបង តាសឿន ហ្នឹងមេនគរបាលតំបន់ ហើយគេធ្វើលេខាស្រុកកោះអណ្ដែតទៀត តាសឿនហ្នឹងហើយដែលមករកសម្លាប់ខ្ញុំ ។ ខ្ញុំធាក់ខ្នុបជញ្ជាំង ។

ដានីៈ ម៉េចបានអ៊ំធាក់?

ហឿនៈ ខ្ញុំដេក ពីថ្ងៃឃើញចៅហ្វាយស្រុកតាអ៊ុចប្អូនថ្លៃតាម៉ុកនេះ ថាឲ្យចាំទទួលកំលាំងពីកោះអណ្ដែត៣នាក់ ហើយខ្ញុំចាំមើលដល់ម៉ោង៤អត់ខ្ញុំដេកលក់លើគ្រែប៉ុណ្ណឹងគ្រែពេទ្យហើយខ្ញុំគ្របវាំងននជិត ស្រាប់តែគេទៅដល់គេកន្ត្រាក់វាំងនន អាគេបាននបោះវាមុនថ្មី ដល់កន្ត្រាក់ខ្មោកមុតក ខ្ញុំថាអ្នកណាគេរកអី កុំបញ្ចាំងពិលមើលអីអត់ឃើញទេ គេអត់នៅតែបញ្ចាំងដល់ខ្ញុំទាញគ្រប គេកន្ត្រាក់ខ្មោកមកទៀត ខ្ញុំគ្របលែងបាន ខ្ញុំងាកទៅកើត នៅតាមបញ្ចាំងពិលដាក់មុខទៀត ខ្ញុំសួរថាអ្នកណាគេហ្នឹងក៏បញ្ចាំងពិលមិនព្រមបិទ មកនិយាយគ្នាដឹងអ្នកណាអ្នកណី ដល់ថាអ្នកណាអ្នកណី ខ្ញុំមកទាក់ទងមិត្តឯងកាចម៉្លេះ ខ្ញុំបង្វែរជើងទាំងពីរដាក់ ខ្ញុំគោងរនាបគ្រែទាំងពីរ ខ្ញុំលើកជើងទាំងពីរធាក់ខ្នុបជញ្ជាំងអីចឹង ជញ្ជាំងផ្ទះថ្មខ្នុបផាំងទៅ ព្រួសូរអុកគូថទៅទៀត គេតមកអុកគូថទៅដី កាំភ្លើងខ្លីព្រួសូរអុកថ្ម បេតុងផ្ទះថ្មព្រួសូរគ្រាំងដូចផ្ទុះអីចឹង ដល់ហើយខ្ញុំស្រវ៉ាចាប់អាគុយនៅលើក្បាលហ្នឹង ឃើញកងការពារគេតំរង់អីចឹង អញថាកុំអាលនិយាយគ្នាសិន ឃើញគេនៅឈរតំរង់ដាក់ខ្ញុំអីចឹង ហើយដល់ហើយខ្ញុំសួរថា បងខាងណា ថាខ្ញុំនៅកោះអណ្ដែក អ៊ូ! បងកោះអណ្ដែត ចុះថាមានមនុស្ស៣នាក់អត់ឃើញ ខ្ញុំសួរអីចឹង ថានោះនៅឡាន គេនិយាយកំបុតអីចឹង ដល់អីចឹងគេមករកចាប់ដៃខ្ញុំ ខ្ញុំចុះចាប់ដៃគេ ចុះពីលើគ្រែចាប់ដៃគេ ដល់ចាប់ដៃគេ ខ្ញុំឲ្យអ្នកនៅហ្នឹង

ទៅមើល ទៅមើលយកទៅឲ្យដេកនៅសាលាកែប្រែ យើងអត់កន្ទេលដេកទេ ដល់ហើយយកទៅហ្នុងទៅ ចងដៃហើមប៉ុណ្ណឹង១ ចងដៃចៅហ្វាយស្រុកកោះអណ្តែតហ្នឹង ចាប់ទាំង៣នាក់ ។

ដានីៈ ចាប់ចៅហ្វាយស្រុកទាំង៣នាក់?

ហឿនៈ ប្រធាន អនុប្រធាន សមាជិកគេ ទាំង៣នាក់យកមក ។

ដានីៈ ឈ្មោះអីខ្លះ?

ហឿនៈ អត់ស្គាល់ គ្រាន់តែឃើញមួយភ្លែត ទៅអើតមើលមួយភ្លែត ។

ដានីៈ អ៊ំកាលហ្នឹងធ្វើអី?

ហឿនៈ ខ្ញុំនៅក្នុងមន្ទីរហ្នឹង ។

ដានីៈ មន្ទីរស្រុកត្រាំកក់ហ្នឹង?

ហឿនៈ បាទ!

ដានីៈ តែអ៊ំមានតួនាទីអីនៅក្នុងមន្ទីរស្រុក?

ហឿនៈ កាលហ្នឹងគេឲ្យខ្ញុំធ្វើសមាជិកស្រុកគេហ្នឹង ។

ដានីៈ សមាជិកស្រុកត្រាំកក់ហ្នឹង?

ហឿនៈ បាទ! ដល់ហើយវាទៅបាត់ ពួសួរអាជាងថ្កិតរូបថតហ្នឹងវាទល់ម៉ោង៩អត់ទាន់ដេកដែរ ពួសួរទៅហៅ អើយតាឈឿន១ ឈ្មោះអាជា វានៅថ្កិតរូបថត អួសទស្សនាវដ្តី ថ្កិតរូបថត អត់មានតាឈឿនទេ មានតែតាហឿន ថាអីចឹង មានតែតាហឿន នៅផ្ទះដួរហ្នឹង ចុងកើតផុត ហើយពួសួរវាអួស១មក មកដល់ជិតរំលងពីរបន្ទប់ពួសួរវាហៅខ្ញុំ ថាអើយតា ។ អញថា បាទ! តាឯងធ្វើម៉េចបងកោះអណ្តែត មិនដឹងអ្នកណាណីវាងងឹត ស្រវាំងភ្នែកពីរដើងហើយ ខ្ញុំថាអីចឹង ។ ដល់ខ្ញុំឲ្យគេយកមនុស្សទៅបាត់ គេទៅអត់លាទេ ទៅសុំចៅហ្វាយស្រុកយកខ្ញុំទៅសម្លាប់ សុំតាំងពីម៉ោង១០ ទល់ម៉ោង៦ព្រឹក សុំយកសម្លាប់ ។ គេថាអាណាចាត់តាំងអាហ្នឹងឲ្យនៅហ្នឹង ។ អាហ្នឹងសាហាវណាស់គេថាអីចឹង ដល់គេថាអីចឹងសុំយកទៅសម្លាប់ អាណាចាត់តាំងអាហ្នឹង ហើយគ្រូអ៊ីចប្អូនថ្លៃតាម៉ុក គាត់ថាអត់ដឹងទេ គាត់ឃើញនៅតែហ្នឹង តាម៉ុកទេអ្នកចាត់តាំងឲ្យនៅហ្នឹង គាត់ថាអីចឹងថាឲ្យយករួច ។ តែតាជីមទេអ្នកចាត់តាំងខ្ញុំឲ្យនៅហ្នឹង ហើយគេរកសម្លាប់ សម្លាប់អត់បាន ដល់យប់ឡើងបងខ្ញុំនៅកោះអណ្តែត តាយ៉ែវហ្នឹងមក ។ មកដល់យំរ៉ូតែម្តង ខ្ញុំថាបងឯងយំអី ថាឯង

ក្បត់ ឯងធាក់ចៅហ្វាយ ខេត្តជង ចៅហ្វាយស្រុកជងអាពូហ្នឹង គណៈតំបន់, នគរបាល គេខាងនគរបាលខាងដើរចាប់ ដើរចង អាគាត់ហ្នឹងឃោរឃៅឥឡូវនៅអន្លង់វែងហ្នឹងដែរ ។

ដានី: ឈ្មោះអី?

ហឿន: ឈ្មោះសឿន តែមិនដឹងនាមត្រកូលឈ្មោះអីទេ ។

ដានី: ប្រពន្ធឈ្មោះអី?

ហឿន: ប្រពន្ធអត់ស្គាល់ ជួបគ្នាពេលខ្លីណាស់ ។

ដានី: អ៊ំខ្ញុំសុំសួរបន្តិច កាលហ្នឹងតាកែវតំបន់ប៉ុន្មាន?

ហឿន: តំបន់១៣ ។

ដានី: គណៈតំបន់ឈ្មោះអី?

ហឿន: គណៈតំបន់កាលខ្ញុំនៅហ្នឹងវាច្រើនដំណារមកទៅហើយ កាលខ្ញុំនៅហ្នុងឈ្មោះតាគិត ។

ដានី: តាគិត?

ហឿន: ព្រាប គិត បងតាដឹម មិញហ្នឹង ។

ដានី: ព្រាប គិត?

ហឿន: ដល់ចូលព្រៃស្លាប់ក្នុងព្រៃបាត់ហើយ ។

ដានី: ព្រាប គិត បងតាដឹម ។ ចុះបន្ទាប់ពីតាគិត មក? គណៈតំបន់៣នាក់អី?

ហឿន: បន្ទាប់តាគិត កាលហ្នឹងផ្លាស់ទៅអត់មាន ហើយតាគិត ទៅនៅតាកែវហ្នឹងបានតែប៉ុន្មានថ្ងៃ តាម៉ុក ឲ្យទៅនៅតំបន់ទឹកខ្មៅទៀត តំបន់២៥ទៀត នៅទឹកខ្មៅ ខ្ញុំទៅជួបគាត់នៅទឹកខ្មៅ ចៅហ្វាយខេត្តគេ ។

ដានី: តែមុនតាគិត ហ្នឹង ពីណាខ្លះទៅ?

ហឿន: មុនហ្នឹងមើល តាសោម មេខ្មែរក្រហម មេកន្ទ្រាញ ។ តាសោមហើយក្មួចទៀតតាអីទេ ក្មួចហើយ តាញ៉ែវ, តាគាវ, តាមុត ហ្នឹងចៅហ្វាយខេត្តដែរតែខាងទ័ព ។

ដានី: តាមុត?

ហឿន: បាទ! តាញ៉ែវ បេ៩២ទម្លាក់ស្លាប់ដំណាលខ្មោចតាហេង ។

ដានី: តាសោម បន្ទាប់ពីតាសោម មក តាញ៉ែវ ។

ហឿន: តាគាវ ។

ដានី: តាគាវ ទៀត?

ហឿន: តាគាវ អនុ ដល់ប្រធានស្លាប់ទៅនៅតាគាវ ។

ដានីៈ ហើយពីណាទៀតទៅ?

ហឿនៈ ដល់ហើយពីតាគាវ, តាញ៉ៅ ហ្នឹងទៅ តាអ៊ួច នេះធ្វើចៅហ្វាយស្រុកទេ ហើយពីហ្នឹងអ៊ូ! តាប្រាក់ បន្ទាប់ពីតាគាវ ទៅតាប្រាក់ ចៅហ្វាយខេត្ត ហើយគេនាំទៅឲ្យរៀនសូត្របាត់ទៅ បានឲ្យតាគិត ហ្នឹងចូល ។

ដានីៈ ចុះតាអ៊ួច មិញ?

ហឿនៈ គ្រូអ៊ួច ហ្នឹងមុនដំបូងចៅហ្វាយស្រុកកោះអណ្តែតហ្នឹង ដល់គេផ្លាស់ពី ។

ដានីៈ អ៊ួច ហ្នឹងឈ្មោះសាន មិនមែនទេ?

ហឿនៈ ឈ្មោះតាណា?

ដានីៈ អ៊ួច ហ្នឹង?

ហឿនៈ គ្រូអ៊ួច គ្រូបង្រៀនទេអតីត តែមិនដឹងឈ្មោះអីនាមត្រកូនអត់ស្គាល់ ។

ដានីៈ ប្រពន្ធគាត់ឈ្មោះអី?

ហឿនៈ ឈ្មោះ អ៊ុង គៀន ។ មីគេន ប្រពន្ធតាទិត ។

ដានីៈ អីចឹងអ៊ួច ហ្នឹងគាត់គណៈស្រុក?

ហឿនៈ គណៈស្រុកត្រាំកក់ទល់យួនចូលបានរត់ចូលព្រៃ ។

ដានីៈ អីចឹងគណៈស្រុកត្រាំកក់ទេ?

ហឿនៈ បាទ! ចុងក្រោយបំផុតហើយអ៊ួចហ្នឹង ប្រពន្ធឈ្មោះមីគៀន, ប្រពន្ធតាទិតឈ្មោះមីគេន ។

ដានីៈ គៀន ហ្នឹងគណៈស្រុក ។ អ៊ួច គាត់បានធ្វើគណៈតំបន់ដែលអត់?

ហឿនៈ អត់ទេ ធ្វើត្រឹមមេឃុំ ហើយឡើងមកស្រុក ។

ដានីៈ អីចឹងគណៈតំបន់មានតាសោម, តាញ៉ៅ, តាគាវ, តាប្រាក់ ហើយតាគិត ចុះតាជឹម?

ហឿនៈ តាជឹម គាត់ធ្វើគណៈក្រសួងនៅចំការកៅស៊ូ ។

ដានីៈ អ៊ំ! កាលជំនាន់អ៊ំធ្វើនៅក្នុងជួរគណៈស្រុកហ្នឹងដែរ គណៈស្រុកឈ្មោះតាអ៊ួច ហ្នឹង?

ហឿនៈ អត់ទេ ខ្ញុំចេញផុតបានតាអ៊ួច ចូលទៅ ។

ដានីៈ តាអ៊ួច ហ្នឹងគណៈស្រុកចុងក្រោយគេ?

ហឿនៈ មុនតាអ៊ួច ហ្នឹងតាចាយ ។ អត់ស្គាល់នាមត្រកូលគាត់ទៀត អ៊ូ!ឈ្មោះតាទី នាមត្រកូលគាត់ឈ្មោះ ទី ចាយ រកនឹកទំរាំតែឃើញ ។

ដានីៈ ហើយគាត់ផ្លាស់ទៅណាទៅ តាចាយ, តាទី ហ្នឹង?

ហឿនៈ បាទ?

ដានី: អីចឹងខ្ញុំចង់ដឹងពីដំបូង កាលអ៊ំនៅត្រាំកក់គណៈស្រុក តាជឹម?

ហឿន: នៅជាមួយតាជឹម ។

ដានី: តាជឹម គាត់ធ្វើតាំងពីដើមមកអី?

ហឿន: តាជឹម មេខ្មែរក្រហមហើយ ដើរបាចគ្រាក់ហើយគ្រាន់តែគេចេញមកពីព្រៃ គេចាត់តាំង តាជឹម ហ្នឹងធ្វើចៅហ្វាយស្រុករហូត ។

ដានី: តាជឹម ដំបូង ហើយអនុតាជឹម ពីណាគេ?

ហឿន: អនុតាជឹម ឈប់រកនឹកសិន ។ តាជឹម អនុគេ, យាយខុម ប្រពន្ធតាមុតនេះធ្វើប្រធាន ។ ឈ្មោះ ព្រៀក ខុម កូនតាម៉ុក ។

ដានី: ប្រធាន ។

ហឿន: តាជឹម អនុ ។

ដានី: ព្រៀក ខុម ប្រធាន, តាជឹម អនុ ។

ហឿន: ហើយតាដន សមាជិក តែស្លាប់បាត់ហើយ ។

ដានី: តាដន?

ហឿន: តាដន ភូមិភាគ៥ហ្នឹងស្លាប់បាត់ហើយ ។

ដានី: តាដន សមាជិក ឪពុកឈ្មោះលី, ឡា ហ្នឹង?

ហឿន: លី, ឡា!

ដានី: កូនតាដន ដន្ទងតាទិត ហ្នឹង?

ហឿន: ហ្នឹងហើយ ។

ដានី: អីចឹងអ៊ំដំបូងគេយាយខុម ប្រពន្ធតាមុត, ព្រៀក ខុម?

ហឿន: ព្រៀក ខុម ហើយតាជឹម ហ្នឹងមុនគេបង្អស់ ។

ដានី: ហើយតាដន ក៏នៅមុនគេដែរ?

ហឿន: តាដន ជីតាឈ្មោះតាសោម ។ សោម ដន ជីដូនមួយជាមួយខ្ញុំដែរ ។

ដានី: អីចឹង សោម ដន ជីដូនមួយអ៊ំដែរ?

ហឿន: ម៉ែវាប្អូនម៉ែខ្ញុំបង្កើត ។

ដានី: បន្ទាប់ពីយាយខុម, តាជឹម បន្ទាប់មកពីណាឡើងប្រធាន?

ហឿន: តាចាយ ។

ដានី: តែតាជឹម បន្ទាប់ពីខុម ចេញទៅ ជឹម ឡើងប្រធាន?

ហឿនៈ ជីម គេឡើងប្រធាន ដល់តាជីម ចេញទៅ បានឡើងតាចាយ ។

ដានីៈ តែអ៊ំឡើងជាសមាជិក?

ហឿនៈ ខ្ញុំនៅហ្នឹងធ្វើសមាជិក ខាងធ្វើបញ្ជីមួយរយគេ ។

ដានីៈ អ៊ំជាសមាជិកពីឆ្នាំណាដល់ឆ្នាំណាទៅ?

ហឿនៈ តាំងពីឆ្នាំ៧៦ ។

ដានីៈ ពី៧៦ដល់ចិតប៉ុន្មាន?

ហឿនៈ ដល់៧៨ ខ្ញុំទៅនៅកោស៊ូជប់ ។

ដានីៈ អ៊ីចឹងអ៊ំនៅសមាជិកស្រុកត្រាំកក់ហ្នឹងពី៧៦-៧៨?

ហឿនៈ បាទ!

ដានីៈ ហើយកាលហ្នឹងពេលផ្លាស់ទៅ ផ្លាស់ទៅជាមួយតាជីម ដែរ?

ហឿនៈ ទៅជាមួយតាជីម ។

ដានីៈ ផ្លាស់ទៅជាមួយគ្នាតែម្ដង?

ហឿនៈ បាទ!

ដានីៈ ដល់ពេលអ៊ំផ្លាស់ទៅបានតាចាយ គាត់ឡើង?

ហឿនៈ គ្រូអ៊ូច នេះឡើង ។ តាចាយ ផ្លាស់មុនតាជីម ទៀត ។

ដានីៈ តាចាយ ផ្លាស់មុនតាជីម ។ តាចាយ ផ្លាស់ទៅឆ្នាំណា?

ហឿនៈ ហ្នឹង៧៦ដែរ ។ ដល់៧៨ បានតាជីម ផ្លាស់ ។

ដានីៈ ៧៦ តាចាយផ្លាស់មកនៅខាងណា?

ហឿនៈ មកនៅខាងព្រះនេត្រព្រះនេះ មកជាមួយយាយថែម ។

ដានីៈ ហើយតាចាយ ហើយនិងយាយថែម ពីណាធំជាង?

ហឿនៈ តាចាយ ធំជាង តែតាចាយ គេជាប់ប្រវត្តិតស៊ូ ពូជគេល្អ យាយថែម ហ្នឹង ។

ដានីៈ ដល់ពេលចុងក្រោយគេឈ្មោះ អ៊ូច?

ហឿនៈ គ្រូអ៊ូច ហ្នឹងចុងក្រោយហើយទល់នឹងយួនចូល ។

ដានីៈ អ៊ូច ហ្នឹងគាត់មានឈ្មោះផ្សេងទៀតដែលអត់?

ហឿនៈ អត់ទេ ឈ្មោះតែមួយហ្នឹង គ្រូបង្រៀន ។

ដានីៈ គាត់គ្រូបង្រៀន?

ហឿនៈ ហ្នឹងហើយ នៅស្រុកខ្ញុំតាំងពីមកការប្រពន្ធ ឈ្មោះតាអ៊ូចហ្នឹង ដល់ហើយគេហៅទៅនៅ កោះអណ្តែតគេហៅ សាន , អ៊ូច ។

ដានីៈ គេហៅតាសាន ផង តាអ៊ូច ផង ។

ហឿនៈ បាទ! ឈ្មោះដើមឈ្មោះអ៊ូច ។

ដានីៈ គាត់នៅណាឥឡូវ?

ហឿនៈ នៅសំឡូតចាស់ ។

ដានីៈ នៅឃុំអីគេ?

ហឿនៈ សំឡូតចាស់ហ្នឹងគេដាក់ឃុំឆករការ ។

ដានីៈ នៅកន្លែងអូររថក្រោះហ្នឹង?

ហឿនៈ អូររថក្រោះហើយកន្លែងហ្នឹងឃុំតែមួយ តាំងពីត្រឹមនេះ ខាងលិចផ្លូវទៅរហូតទល់អូររថ ក្រោះហ្នឹងឃុំ... ។

ដានីៈ ឥឡូវគេស្គាល់គាត់តែអ៊ូចៗទេ?

ហឿនៈ ស្គាល់តែតាអ៊ូចទេ អត់ដែលហៅសានផង ។

ដានីៈ សាន ហ្នឹងគេអត់ស្គាល់ទេ?

ហឿនៈ អត់ទេ ឈ្មោះខ្មែរក្រហម គាត់នៅស្រុកកោះអណ្តែត ។

វណ្ណៈ : ចុះតាជីម ហ្នឹងនៅរស់ទេ ពល់ថ្ងៃ?

ហឿនៈ នៅរស់ បងថ្លៃខ្ញុំ នៅផ្ទះប្រពន្ធកូនខ្ញុំនេះ តែគេលែងតាំងពីឆ្នាំ៨៥ ។

ដានីៈ ដល់ពេលគ្រូអ៊ូចហ្នឹង ប្អូនថ្លៃតាម៉ុកគាត់ធ្វើគណៈស្រុកត្រាំកក់ពីណាអនុគាត់?

ហឿនៈ អត់ដឹង ខ្ញុំចេញផុតទៅ ។

ដានីៈ អ៊ីគណៈស្រុកកោះអណ្តែត?

ហឿនៈ គណៈស្រុកកោះអណ្តែតមុនដំបូង គ្រូអ៊ូច ហ្នឹងចេញមកនៅស្រុកត្រាំកក់ បានតាសឿន និងតាយ៉ែវ ហ្នឹងចូលទៅ ។

ដានីៈ ដំបូងគេគ្រូអ៊ូច ហៅសាន។ កាលនៅកោះអណ្តែត អ៊ូច ដូរទៅជាឈ្មោះសាន វិញ?

ហឿនៈ ឈ្មោះសាន ។

ដានីៈ ហើយគាត់ដូរចេញឆ្នាំណាទៅ?

ហឿនៈ កាលហ្នឹងកំពុងតែវៃគ្នា មិនដឹងឆ្នាំប៉ុន្មាន គាត់ទៅនៅហ្នឹងតាំងពីទី១មកគេរៀបចំរដ្ឋអំណាច គាត់ទៅនៅហ្នឹង ។

ដានី៖ ដល់ពេលគាត់ផ្លាស់មកត្រាំកក់ សឿន ហ្នឹងទៅម្ដង?

ហឿន៖ តាសឿន ហើយនិងតាយ៉ែវ ។

ដានី៖ តាសឿន ហើយតាយ៉ែវ ។ តាយ៉ែវ ត្រូវជាបងរបស់អ៊ំ?

ហឿន៖ បងខ្ញុំ ។

ដានី៖ តាយ៉ែវ មុនគាត់ទៅត្រាំកក់គាត់នៅណា?

ហឿន៖ កាលមុននៅត្រាំកក់ជាមួយគ្នា នៅភូមិជាមួយគ្នាហ្នឹង ។

ដានី៖ កាលមុនគាត់នៅត្រាំកក់ ប៉ុន្តែកាលមុនគាត់ទៅកោះអណ្ដែត គាត់ធ្វើអី?

ហឿន៖ ធ្វើអនុស្រុកកោះអណ្ដែត ។

ដានី៖ ដឹបូង?

ហឿន៖ បាទ ។

ដានី៖ មុនទៅកោះអណ្ដែត?

ហឿន៖ មុនកោះអណ្ដែតធ្វើស្រែ ធ្វើចំការដែរ ដល់គេចាត់តាំងគាត់ទៅនៅហ្នុង ។

ដានី៖ គាត់ទៅធ្វើអនុស្រុកកោះអណ្ដែត?

ហឿន៖ បាទ!

ដានី៖ ហើយសឿន ប្រធាន?

ហឿន៖ តាសឿន ហ្នឹងនគរបាលតំបន់ផង អនុស្រុកផង ។

ដានី៖ សន្តិសុខរបស់តំបន់?

ហឿន៖ ហ្នឹងហើយ គេដើរចាប់ ដើរចងនៅលើគេហ្នឹង បានមករកចងខ្ញុំបានគេអត់ឲ្យ ។

ដានី៖ តាសឿនហ្នឹងសព្វថ្ងៃគាត់នៅរស់ទេ?

ហឿន៖ នៅ ជួបខ្ញុំមកអូររថក្រោះ ។

ដានី៖ តែគាត់នៅណាឥឡូវ?

ហឿន៖ នៅអន្លង់វែងនោះ ។

ដានី៖ អត់ស្គាល់ប្រពន្ធគាត់ឈ្មោះអីទេ?

ហឿន៖ ប្រពន្ធគាត់ស្គាល់កាលនៅនោះ តែឥឡូវភ្លេចអស់ទៅ ។

ដានី៖ នៅអន្លង់វែង នៅម្ដុំណាទៅ? សឿន ត្រកូលអីគេសឿន ហ្នឹង?

ហឿន៖ អត់ស្គាល់ទៀត ។

ដានី៖ អ្នកស្រុកណា?

ហឿនៈ នៅកំពតដែរ ។

ដានីៈ អ្នកកំពត ស្រុកណាទៅ?

ហឿនៈ ស្រុកឈូក ។

ដានីៈ ហើយត្រាំកក់មុនដំបូងតាអ៊ូច ។ អ៊ូច ចេញមកបានតាសឿន ហ្នឹងទៅ?

ហឿនៈ តាសឿន ហើយនិងតាយ៉ែវ ទៅ ។ ទៅទល់នឹងយួនចូលបានចេញវិញ ។

ដានីៈ អង្គរជ័យ?

ហឿនៈ អង្គរជ័យ យាយថែម គេធ្វើស្រុកទេ តាញ៉ែន ។

ដានីៈ យាយថែម-តាញ៉ែន ហ្នឹងគាត់នៅអង្គរជ័យ?

ហឿនៈ ហ្នឹងហើយ ចៅហ្វាយស្រុកអង្គរជ័យ ប្តីគាត់ឈ្មោះញ៉ែន តូច! ។

ដានីៈ តាញ៉ែន?

ហឿនៈ តាញ៉ែនៗ ។

ដានីៈ ចុះមានឈ្មោះសៀង មួយទៀត មានស្គាល់ឈ្មោះសៀង?

ហឿនៈ តាសៀង ប្អូនថ្លៃយាយថែមហ្នឹង ។ តាសៀង ហ្នឹងឈ្មោះស្អីសៀងទេ ភ្លេចបាត់ ។

ដានីៈ តាសៀង គណៈស្រុកណាដែរ?

ហឿនៈ តាហ្នឹងគេចចេញក្រៅស្រុក មកដល់កំពង់ចាមដែរមិនដឹងនៅស្រុកណាអត់ដឹង ។

ដានីៈ តាសៀង ហ្នឹង?

ហឿនៈ បាទ! ដល់យួនចូល ។

ដានីៈ តាសៀង ហើយអ៊ូច ហ្នឹងមានធ្លាប់ឈ្លោះគ្នាអត់?

ហឿនៈ ដូចអត់ដែលឮ អត់ ។

ដានីៈ តែតាសៀង អត់ដឹងថាគាត់នៅស្រុកណាទេ?

ហឿនៈ ស្រុកគាត់នៅស្រុកត្រាំកក់ដែរ ។

ដានីៈ តែគាត់មានធ្វើគណៈស្រុកអីនៅ?

ហឿនៈ ធ្វើ ។

ដានីៈ គណៈស្រុកណា?

ហឿនៈ មិនដឹងគាត់ចេញទៅក្រៅខេត្តទៅអត់ដឹង ។

ដានីៈ ចុះស្រុកទ្រាំងមានស្គាល់ពីណាគេគណៈស្រុក?

ហឿនៈ អត់ស្គាល់សោះ ។

ដានី៖ ចុះយាយចែម-តាញៀន ហ្នឹងគាត់មិនផ្លាស់ចេញដែរ?

ហឿន៖ ផ្លាស់មកជាមួយតាចាយ ៧៦ហ្នឹង មកនៅព្រះនេត្រព្រះ ។

ដានី៖ ដល់គាត់ផ្លាស់មកព្រះនេត្រព្រះពីណាឡើងជំនួសគាត់? នៅខាងអន្លង់វែង?

ហឿន៖ កាលហ្នឹងឈ្មោះតានិត។ ប្អូនថ្លៃតាម៉ុក ។ ម៉ម និត ។

ដានី៖ ម៉ម និត គាត់ប្អូនថ្លៃតាម៉ុក?

ហឿន៖ ប្អូនថ្លៃតាម៉ុក ។

ដានី៖ ប្រពន្ធគាត់ឈ្មោះអី?

ហឿន៖ ប្រពន្ធគាត់ឈ្មោះ ពូន ។

ដានី៖ យាយពូន?

ហឿន៖ យាយពូន តែស្លាប់អស់ហើយ នៅតែកូន។ ព្រៀក ពូន ដែរ ។

ដានី៖ គណៈស្រុក ហើយ និត ហ្នឹងទើបតែស្លាប់ឬស្លាប់យូរហើយ?

ហឿន៖ ស្លាប់រត់ចូលព្រៃ ស្លាប់ក្នុងព្រៃបាត់អស់ ។

ដានី៖ គាត់មានធ្វើគណៈតំបន់១៣ដែលអត់ទេ?

ហឿន៖ អត់ទេ ខ្ញុំបែកទៅ អត់ទេ អត់មានមកទេ ។

ដានី៖ និត ហ្នឹងគាត់ធ្វើរហូតដល់បែកយួនចូល?

ហឿន៖ បាទ ។

ដានី៖ ចុះស្រុកទ្រាំង?

ហឿន៖ ស្រុកទ្រាំងអត់ដឹង អត់ដែលទៅដល់ទេ ។

ដានី៖ ស្រុកទ្រាំងអត់ដឹងពីណាទេ?

ហឿន៖ អត់ ។

ដានី៖ ចុះគិរីវង្ស?

ហឿន៖ គិរីវង្សអត់ដែលទៅដល់ដែរ ដែលតែចែកសម្ភារៈទៅ ។

ដានី៖ ចុះអ៊ំមានប្រសាសន៍មិញ តាទិត ប្ដីយាយគេន គាត់ធ្វើអី?

ហឿន៖ តានិត?

ដានី៖ តាទិត?

ហឿន៖ តាទិត គាត់ចៅហ្វាយខេត្តបាត់ដំបងហ្នឹង ។

ដានី៖ តែមុនមកបាត់ដំបង?

ហឿនៈ	កាលមុនមក កាលមុនចេញនៅធ្វើចៅហ្វាយស្រុកតានី ដល់តាទិត ចេញមកយាយថែម ទៅនៅបានប៉ុន្មាន ចេញមកជាមួយតាចាយ ទៀត មកដំណាលគ្នាទាំង៣នាក់ហ្នឹង ។

ដានីៈ	ស្រុកអីគេ?

ហឿនៈ	ស្រុកអន្លុងជ័យ មិនដឹងស្រុកអី អត់ដឹង ។ តែកាលខ្ញុំនៅធ្វើបញ្ជី១០០ នៅក្នុងស្រុកត្រាំកក់ដែរ ចែកស្បៀង ចែកអង្ករគេមកយកតែពីហ្នឹងទៅ ។

ដានីៈ	យកពីណាទៅ?

ហឿនៈ	យកពីស្រុកត្រាំកក់ទៅហូប ឲ្យប្រជាជនថ្មីហ្នឹង គេមកយកពីត្រាំកក់ទៅ ។

ដានីៈ	កាលហ្នឹងតាទិត គាត់នៅហ្នឹងដែរ?

ហឿនៈ	នៅហ្នឹងដែរ ។

ដានីៈ	គាត់ធ្វើអីគេកាលហ្នឹង?

ហឿនៈ	ធ្វើចៅហ្វាយស្រុក ។

ដានីៈ	ចៅហ្វាយស្រុកជំនាន់ពីណាគេ?

ហឿនៈ	ជំនាន់យាយថែម ហ្នឹង ។

ដានីៈ	ចៅហ្វាយជំនាន់យាយថែម អីចឹងតាំងពីមុនបែក៧៩?

ហឿនៈ	កាលហ្នឹងភ្លេចអស់ហើយ! តាទិត, យាយថែម, ហើយអាជឿន បងអាជននេះ កាលហ្នឹងនៅអន្លុងជ័យ ។

ដានីៈ	ជឿន?

ហឿនៈ	សោម ជឿន, សោម ជន ហ្នឹងបងប្អូនគ្នា ។

ដានីៈ	សោម ជឿន ហ្នឹងធ្វើអីគេ?

ហឿនៈ	កាលហ្នឹងគេនៅហ្នឹងគេធ្វើចៅហ្វាយស្រុកដែរ ។ ធ្វើចៅហ្វាយស្រុកតានី ។

ដានីៈ	តានីហ្នឹងអន្លុងជ័យអី?

ហឿនៈ	ស្រុកអន្លុងជ័យហ្នឹងហើយ នឹកឃើញហើយ ស្រុកអន្លុងជ័យ ។

ដានីៈ	តាទិត មិនមែនស្រុកគិរីវង្សទេ?

ហឿនៈ	មិនមែនទេ នៅស្រុកអន្លុងជ័យហ្នឹង ។

ដានីៈ	ចុះតាតេម?

ហឿនៈ	តាគេម ស្គាល់នៅក្នុងព្រៃ អត់ស្គាល់ទេ ស្គាល់តែតាគេម មេទ័ពកំពូលរបស់តាម៉ុក ហើយ ។ តាគេមៗហ្នឹងពូកែច្បាំងណាស់ ជួបគ្នាក្នុងព្រៃហើយ លែងស្គាល់ហើយ ស្គាល់គ្នាក្នុងព្រៃនោះ ។

ដានីៈ	អ៊ីចឹងអ៊ំនៅជាសមាជិកហ្នឹងរហូតពី៧៦-៧៨ ហើយកាលហ្នឹងខាងភូមិភាគនិរតីពីណាធ្វើប្រធាន?

ហឿនៈ	តាម៉ុក មានតែតាម៉ុក មួយហ្នឹង ។

ដានីៈ	ពីណាធ្វើអនុតាម៉ុក?

ហឿនៈ	អត់មានទេ មានតាម៉ុក មួយ ។

ដានីៈ	មានតែតាម៉ុក មួយ?

ហឿនៈ	ជិត តាម៉ុក ហ្នុងមានតែគណៈតំបន់ ។

ដានីៈ	មានប៉ុន្មានតំបន់កាលហ្នឹង?

ហឿនៈ	មាន៥ ។

ដានីៈ	តំបន់ណាខ្លះ?

ហឿនៈ	១ត្រាំកក់, ២ស្រុក១០៨, ១០៩, ១០៧, ១០៦ ។

ដានីៈ	ហ្នឹងស្រុក?

ហឿនៈ	ហ្នឹងស្រុកហើយ ។

ដានីៈ	ហ្នឹងក្នុងតំបន់១៣?

ហឿនៈ	ហ្នឹងហើយ ។

ដានីៈ	តំបន់១៣នៅណាទៅ? មន្ទីរតំបន់១៣នៅណា?

ហឿនៈ	មន្ទីរតំបន់១៣មានឈ្មោះតាសឿន ឆាប់បាត់ហើយ ។ តាសឿន មេខ្មែរក្រហមដែរ ណាំសឿន ។

ដានីៈ	តែនៅណាទៅមន្ទីរតំបន់?

ហឿនៈ	មន្ទីរតំបន់១៣នៅក្នុងក្រុងតាកែវ ។

ដានីៈ	តំបន់២៥នៅណា?

ហឿនៈ	អត់ដឹងទេ ដល់តាគិត ចេញទៅគាត់ទៅឈរនៅតំបន់២៥ ។

ដានីៈ	តាគិត?

ហឿនៈ	ព្រាប គិត មិញហ្នឹង ។

ដានី៖ គាត់មកខាងទន្លេ ខាងកោះធំ ស្អាង?

ហឿន៖ កន្លែងខេត្តគេនៅមាត់ទន្លេ ខ្ញុំទៅដល់ម្ដង។

ដានី៖ តំបន់២៥។

ហឿន៖ អាទឹកខ្មៅ នៅជាប់ទឹកខ្មៅ នៅជាប់មាត់ទន្លេ។

ដានី៖ តាគិត!

ហឿន៖ នៅសាលាខេត្តគេហ្នឹង។

ដានី៖ ហើយចុះតំបន់៣៣?

ហឿន៖ អត់ដឹងទេ។

ដានី៖ តំបន់៣៣អឹអត់ដឹងទេ?

ហឿន៖ អត់ដឹង។

ដានី៖ តំបន់៣៥ ខាងកំពត?

ហឿន៖ ហ្នឹងក៏អត់ដឹងដែរ ដឹងតែមួយតំបន់ហ្នឹង ដើរជួបគ្នា ដើរធ្វើការជាមួយគ្នា។

ដានី៖ អីចឹងតាទិត អ៊ំដឹងថាគាត់មកបាត់ជំបង មកឆ្នាំណាទៅ?

ហឿន៖ ឆ្នាំ៧៦ មកយាយថែម យាយថែមមកបាន២-៣ខែបានតាចាយ មកក្រោយ។

ដានី៖ ហើយតាទិត?

ហឿន៖ តាទិត ចៅហ្វាយខេត្ត។

ដានី៖ គាត់មកមុនគេ ឬមក?

ហឿន៖ មកដំណាលយាយថែម, តាចាយ, តាទិត ៣នាក់ហ្នឹង។

ដានី៖ ពីណាធំជាងគេក្នុងចំណោម៣នាក់ហ្នឹង?

ហឿន៖ តាទិតធំជាង ចៅហ្វាយខេត្ត។ តាទិត ឪប្ដូមលីសង់។

ដានី៖ ដូចអឹមានប្រវត្តិម្ដាយជាវៀតណាមអីចឹង អ៊ំបានធ្វើធំដែរ ម៉េចបាន?

ហឿន៖ គេឲ្យធ្វើត្រឹមកំប៉ិកកំប៉ុកអីចឹង។

ដានី៖ ពីណាអ្នកឲ្យអ៊ំធ្វើ?

ហឿន៖ តាជីម ហ្នឹង។ តាជីម ហ្នឹងបងថ្លៃទៀត។

ដានី៖ តាជីម ហ្នឹងត្រូវជាបងថ្លៃអ៊ំ?

ហឿន៖ បាទ! ហើយនៅភូមិជាមួយគ្នាទៀត។

ដានី៖ តាជីម ហ្នឹងហើយអ៊ំម៉េច? តាជីម ត្រូវបងថ្លៃរបស់អ៊ំបង្កើត?

ហឿនៈ បាទ!

ដានីៈ យ៉ាងម៉េច ប្រពន្ធតាជឹម ហើយនិងប្រពន្ធអ៊ី?

ហឿនៈ ប្រពន្ធតាជឹម បងយាយខ្ញុំបង្កើត ។

ដានីៈ ដល់ពេលអ៊ីចឹងតាជឹម គាត់ឲ្យអ៊ីធ្វើជាសមាជិកស្រុកទៅ?

ហឿនៈ បាទ!

ដានីៈ ម្តាយអ៊ីកាលហ្នឹងពីណាគេចេះតែរករឿងសម្លាប់?

ហឿនៈ ចៅហ្វាយស្រុក យាយខុម ហ្នឹង ។

ដានីៈ យាយខុម ហ្នឹង?

ហឿនៈ ព្រៀក ខុម ហ្នឹង ហើយតាជឹមថា វវល់តែគេរករឿង ឯងទៅនៅមន្ទីរស្រុកទៅយកខ្ញុំទៅដាក់មន្ទីរស្រុក យាយខុម មករកដក សោម ដន នេះថា ដកម៉េចត្រូវប្អូនថ្លៃ តាជឹម ហើយយាយខុមហ្នឹងគេថាមិនដឹងជឹមណាទេមិនដែលស្គាល់ទេ គេសំឡុត អាដន អ៊ីចឹង ។ អាដន ប្អូនខ្ញុំ ។

ដានីៈ សោម ដន ហ្នឹង?

ហឿនៈ បាទ! កុំអីគេយកទៅបាត់ ហើយអាសឿន គេប្រុងសម្លាប់ខ្ញុំ សុំគេមួយយប់ទល់ភ្លឺគេអត់ឲ្យ ។ រកសម្លាប់ខ្ញុំ អាព្រឹកឡើងនីរសាខ្ញុំរត់ទៅប្រាប់ខ្ញុំថា តាឯងធាក់បងកោះអណ្តែតម៉េចមិញគេសុំតាអ៊ូចយកទៅសម្លាប់ហើយ ។ គេប្រាប់អ៊ីចឹងខ្ញុំកំពុងតែរៀបលប់មុខព្រឹកឡើងលប់មុខតែមួយឆាច់ទាញម៉ូតូទៅខេត្ត ទៅជួបតាគិត ថាពួគេរកសម្លាប់ខ្ញុំហើយ ។ ថាអាណា ថាអាសឿន កោះអណ្តែត ។ ថាអាសឿនហ្នឹង អាណាចាត់តាំងឲ្យអាសឿនឲ្យនៅហ្នឹង អញទៅជួបវា អញសួរវាមួយម៉ាត់ វាក្រពត់ដៃដើរទៅនេះ ដើរទៅនោះ ឡានអញរអិលធ្លាក់ព្រែក អាហ្នឹងឲ្យនីរសាទៅហៅ ។ ទៅហៅអាសឿន ឲ្យមកជួប ដល់ហៅនីរសាយកពីស្រុកខ្ញុំទៅហ្នឹង ខ្ញុំថាហ្វែងបើតាគិត សំរេចឲ្យគេសម្លាប់អញ ហ្វែងប្រាប់អញម៉េចៗ ហ្វែងមកប្រាប់អញ ។ ដល់ខ្ញុំផ្តាំវាអ៊ីចឹង វាទៅហៅកោះអណ្តែតហ្នឹងទល់គ្នាម៉ោង៧រសៀលបានមកដល់ ឆ្ងាយណាស់ ។ ដល់មកតាគិត ថាម៉េចសឿន ឯង? អាងសឿនឯងមានអំណាចទៅគំរាមកំហែងគេ សុំគេយកទៅបាញ់ចោល សឿន ឯងធ្វើហ្នឹងធ្វើម៉េចហ្នឹងមិត្តហ្នឹងទេ បើក្រៅពីមិត្តហ្នឹង សឿន ឯងយកគេវ៉ៃចោលបាត់ហើយ ។ សំឡុតអ៊ីចឹងសំឡុតទាល់តែយំ សឿន ហ្នឹងយំ ។ ដល់សំឡុតអ៊ីចឹងថា អញចង់ទៅជួបហ្វែងចៅហ្វាយស្រុក ហ្វែងអត់ជួបជាមួយអញ អត់ឈរនិយាយជាមួយអញទេ អញដើរតាមហ្វែង

និយាយមួយម៉ាត់ទៅនេះមួយម៉ាត់ទៅនោះ ក្រពត់ដៃ ថាសឿនហ្នឹង ហើគាត់ខឹង។ ថាខំទៅជួបវាអត់និយាយជាមួយគាត់អន្ទុយ ដល់អីចឹងបានបងខ្ញុំយប់ឡើងព្រិល១មកយំហ៊ួថា ខ្ញុំក្បត់ បងឯងកុំភ័យ កុំខ្លាចគេ ខ្ញុំអត់ខុសគេ ខ្ញុំធាក់វា២ជើងខ្ញុំអស់ចិត្តហើយ ។

ដានីៈ បងឈ្មោះយ៉ែវហ្នឹង?

ហឿនៈ បងខ្ញុំឈ្មោះ តាយ៉ែវ ហ្នឹងអនុគេហ្នឹង ។

ដានីៈ តាយ៉ែវ?

ហឿនៈ តាយ៉ែវ ។

ដានីៈ ហើយបងអ៊ំហ្នឹងគាត់ស្លាប់ឆ្នាំណា?

ហឿនៈ ស្លាប់វត់ចូលព្រៃ ស្លាប់ក្នុងព្រៃ ៧៩ហ្នឹង ។

ដានីៈ ហើយបងអ៊ំមួយទៀតដែលធ្វើធំ ខាងកងទ័ពឈ្មោះហេង ហ្នឹងគាត់ស្លាប់?

ហឿនៈ អ៊ុល ហេង ហ្នឹងបេ៥២ទម្លាក់ស្លាប់៧៣ ។

ដានីៈ ឪពុករបស់អ៊ំដែលស្លាប់ឆ្នាំ៧៧ហ្នឹង ស្លាប់នៅពេទ្យនៅភ្នំពេញ?

ហឿនៈ ពេទ្យ១៧ មេសា ភ្នំពេញ ។

ដានីៈ ពីណាគេយកមក?

ហឿនៈ ខ្ញុំផ្ញើរតាមពេទ្យតំបន់ ត្រូវប្រពន្ធខ្មោចតាហេង ហ្នឹង គេប្រធាន ។

ដានីៈ ប្រធានពេទ្យតំបន់?

ហឿនៈ ប្រធានពេទ្យតំបន់ ។

ដានីៈ គាត់ឈ្មោះអី?

ហឿនៈ ឪវាឈ្មោះយិន ហើយតាវាឈ្មោះអីទេ យាយហ្នឹងឈ្មោះបងឌី ធ្វើប្រធានពេទ្យ យកមកដាក់ពេទ្យ ស្លាប់នៅពេទ្យ ។

ដានីៈ ស្លាប់ហើយបានអ៊ំយកសពទៅស្រុកវិញ?

ហឿនៈ អត់ទេ អត់បានមកទេ ។

ដានីៈ អត់បានមកយកសពទៅបញ្ចុះត្រឹមត្រូវទេ?

ហឿនៈ អត់ដឹងគេយកទៅទុកដាក់ណាអីណាយើងអត់ដឹង ។

ដានីៈ យើងអត់បានមកមើលទេ?

ហឿនៈ អត់ ។

ដានីៈ គេអត់ឲ្យមកមើល ឬអ៊ំអត់ចង់មក?

ហឿន៖ បើមកសុំគេ ថីមិនបាន តែខ្ញុំអត់មក ។

ដានី៖ ម៉េចអីចឹង?

ហឿន៖ កាលហ្នឹងខ្ញុំទៅភ្នំពេញគេឲ្យទៅរុះផ្ទះមួយខែ ខ្ញុំទៅបានតែមួយអាទិត្យខ្ញុំខ្លាច យប់ឡើងទាហានចេញពីផ្ទះខាងៗឲ្យភ្លឺដូចថ្ងៃអីចឹង ខ្លាច ។

ដានី៖ ទាហានចេញ-ចូល?

ហឿន៖ ទាហាន លន់ នល់ គេដើរចាប់មួយយប់បាន១០-២០ ហើយសួរថាឯងនៅណា ថាខ្ញុំនៅក្នុងបន្ទន់ចាស់ៗ នៅក្នុងប្រឡាយ នៅក្នុងប្រឡាយច្រើនណាស់ វាថាអីចឹង ហើយគេដើរចាប់រាល់ថ្ងៃ ហើយខ្ញុំឃើញសភាពការណ៍អីចឹងខ្ញុំរត់មកស្រុក មកផ្ទះវិញ បានខ្ញុំឲ្យកំលាំងទៅដូរខ្ញុំ ឈ្មោះខ្ញុំហ្នឹង ។ ទៅដេកចំលើផ្ទះលន់ នល់ ដល់ថ្ងៃមួយប្អូនសោម ដន ឈ្មោះអាដាង ហៅខ្ញុំទៅមើលកូនស្តេច ខ្ញុំមិនដឹងថាគេហួងហែងអី ខ្ញុំទៅអង្គុយលើផ្លូវ ហើយពួកហ្នឹងគេ ចូលទៅឡូកលេងតាមចិត្ត ។

ដានី៖ ឡូកលេងម៉េច?

ហឿន៖ ឡូកកូនស្តេចលេង វាមកឈរជញ្ជាំង អាជញ្ជាំងដែករុញបើកមានប្រហោង ឡូកលេងៗ ហើយដល់ស្អែកឡើងខ្ញុំទៅបបួលវា សួរថាអាដាងទៅណាហើយ? គេឲ្យទៅរៀនបាត់ហើយទៅយប់មិញ គេយកទៅវៃចោលនៅគុកព្រៃស ។

ដានី៖ សោម ដាង ហ្នឹង?

ហឿន៖ ហ្នឹងហើយ!

ដានី៖ ឆ្នាំណា?

ហឿន៖ ឆ្នាំ៧៦ ហើយអាសោម ជឿន ក៏ឆ្នាំ៧៦ បងអាដាងហ្នឹង ។

ដានី៖ គេវៃចោលដែរ?

ហឿន៖ វៃចោល ក្រសួងការបរទេស ចូលភ្នំពេញធ្វើក្រសួងការបរទេស សោម ជឿន ។

ដានី៖ ចុះសោម ដាង ធ្វើអីគេ?

ហឿន៖ ដាង វរសេនាតូច ហើយអាឡៀក ដៃគូវាហ្នឹងនាំខ្ញុំទៅមើលហ្នឹង គេវៃចោលទាំងពីរ ។

ដានី៖ ទៅមើលកូនស្តេចឈ្មោះអី?

ហឿន៖ គេហៅអ្នកអង្គម្ចាស់ ប៉ាង ខ្ញុំស្គាល់តែប៉ុណ្ណឹង មិនដឹងឈ្មោះអីទៀត ។

ដានី៖ អ្នកអង្គម្ចាស់ប៉ាង ហ្នឹងយើងទៅមើលនៅណា? យើងទៅឡូកលេង?

ហឿន៖ វាមកឡូកយើង យើងឡូកវា ។

ដានី៖ ឡូកប៉ះអីគេ?

ហឿន៖ ឡូកចាប់ត្រង់ណាក៏បាន វាអត់ថាអីផង ហើយកង់ទ័ពប្រុសៗនៅហ្នឹងគេសម្លាប់អស់ហើយ អាមួយខ្ញុំឡើងលើផ្ទះ លន់ នល់ គេឲ្យដេកហ្នឹង ខ្ញុំទៅឃើញគេរុំដូចអន្ទូងអីចឹង អូនឯង និយាយអីបានគេធ្វើអីចឹង ថាខ្ញុំទៅមើលកូនស្ដេច ហើយគេរុំខ្ញុំៗ ចុះថ្ងៃណាបានគេលែង ថាអត់ទេ អត់មានលែងទេ គេយកខ្ញុំទៅសម្លាប់ហើយ ហើយខ្ញុំចេញទៅរុះផ្ទះមកវិញបាត់

ដានី៖ ចុះអ៊ំបានទៅឡូកអីនឹងគេអត់?

ហឿន៖ អត់ទេ ខ្ញុំអង្គុយនឹងផ្លូវ បើឡូកលេងបែបនេះបាត់បាត់ហើយ ។

ដានី៖ សោម ដាង បានឡូកដែរ?

ហឿន៖ សោម ដាង គេទៅឈរក្បែរជញ្ជាំងហ្នឹងមិនដឹងឡូកដែរអត់ ។

ដានី៖ តែគេចាប់មួយសារហ្នឹងដែរ?

ហឿន៖ បាទ! ចាប់ជំនាន់ហ្នឹង ។

ដានី៖ ដឹងថាពីណាអ្នកចាប់ទេ?

ហឿន៖ តាម៉េត កងភូមិភាគ៥ ។

ដានី៖ ស៊ូ ម៉េត ហ្នឹង?

ហឿន៖ ស៊ូ ម៉េតៗ

ដានី៖ អ្នកចាប់?

ហឿន៖ អ្នកចាប់ គុកហ្នឹងគុកតាម៉េត ទាំងអស់ ។

ដានី៖ គុកអីគេ?

ហឿន៖ គុកទួលស្លែង យាយខ្ញុំទិញសំបុត្រចូលទៅមើលឃើញអាដាង ឃើញអាជឿន បងប្អូនខ្ញុំ ឃើញនៅក្រៀមលើគ្រែ ហើយមានឈ្មោះរូបថតវាដែរ គេយក២០០រៀលៗ

ដានី៖ កាលហ្នឹងទៅឡូកលេងនៅម្ដុំណា?

ហឿន៖ នៅមុខផ្ទះលន់ លន់ ទៅខាងជើងផ្លូវអីចេះ ផ្លូវទៅកើតអីចឹង នៅខាងជើងផ្លូវ ជិតផ្ទះ លន់ នល់ រំលងផ្ទះ២ហ្នឹង ។

ដានី៖ ព្រះអង្គម្ចាស់ប៉ាង (ស្រី)?

ហឿន៖ បាទ! ស្រីស្អាតណាស់ ខ្ញុំទៅមើលពីចំងាយ ។

ដានី៖ មើលឃើញដែរ?

ហឿន៖ មើលឃើញ ។

ដានីៈ អីចឹងអ៊ំបានទៅភ្នំពេញច្រើនដងដែរ?

ហឿនៈ ខ្ញុំទៅកាល៧៦ ទៅតែមួយដងហ្នុង ។

ដានីៈ កាលហ្នឹងពេលអ៊ំធ្វើខាងសមាជិកស្រុកអីហើយ យើងចង់ទៅភ្នំពេញក៏អត់អីដែរ?

ហឿនៈ អត់អីទេ ចង់ទៅណាក៏បានដែរ ។

ដានីៈ យើងមិនចាំបាច់សុំច្បាប់ពីណាទេ?

ហឿនៈ សុំច្បាប់សំបុត្រពីប្រធានស្រុកទៅ គេឲ្យ ។

ដានីៈ យើងសុំប្រាប់ថាទៅធ្វើអី?

ហឿនៈ ថាទៅលេងភ្នំពេញ ចង់ឃើញភ្នំពេញ គេឲ្យទៅ ។ ថាចង់ទៅលេងស្រុកណាគេឲ្យទៅ ។

ដានីៈ យើងមានសំបុត្រកាន់ដែរ?

ហឿនៈ បាទ! មាន ។

ដានីៈ មានសំបុត្រតែពីគណៈស្រុកបានហើយ? ចៅហ្វាយស្រុក?

ហឿនៈ ដើរក្នុងខេត្ត ដើរតែត្រឹមសំបុត្រស្រុក ។

ដានីៈ ប៉ុន្តែមកភ្នំពេញ?

ហឿនៈ មកភ្នំពេញដើរត្រឹមសំបុត្រស្រុកដែរ គេធ្វើសំបុត្រឲ្យខ្ញុំទៅរុះផ្ទះ គេធ្វើតែត្រឹមស្រុកដែរ ។

ដានីៈ តែអ៊ំជិះអីមក?

ហឿនៈ ជិះឡាន គេទៅដឹកឈើ រុះផ្ទះឈើខាង១ រុះក្បែរបឹងទំពុនពីខាងត្បូងទៅខាងលិច... ។

ដានីៈ រុះផ្ទះយកទៅធ្វើអី?

ហឿនៈ គេឲ្យរុះយកមកធ្វើសាលារៀន យកមករោងបាយសហករណ៍ គេឲ្យរុះឈើវែង១ ។

ដានីៈ គេឲ្យរុះឈើវែង១?

ហឿនៈ បាទ!

ដានីៈ ហើយរុះឈើហ្នឹងយើងដឹកមកត្រាំកក់វិញ?

ហឿនៈ ឡានស្រុកទៅដឹក ។

ដានីៈ ហើយកាលហ្នឹងមានមកជួបពីណាគេនៅភ្នំពេញទេ?

ហឿនៈ ក្មេចឈ្មោះ តាគីម នៅភូមិគុស កងវរសេនាធំ នាំខ្ញុំទៅដាក់លើផ្ទះលន់ នល់ហ្នឹង ហើយ តាគីម ហ្នឹងនៅនីរសាតាជីម ដល់ធ្វើធំ តាជីម ទាក់ទងតាគីមហ្នឹង យកពួករុះផ្ទះទៅរុះ ។

ដានីៈ ក្នុងវរសេនាធំរបស់កងពលពីណាគេ?

ហឿនៈ កងពលតាម៉េតហ្នឹង ។

ដានីៈ អ៊ំស្គាល់តាម៉េត ច្បាស់អត់?

ហឿនៈ ស្គាល់ច្បាស់ មកតាំង៧៩មកទល់គ្នា ។

ដានីៈ ស្គាល់៧៩ហើយទេ?

ហឿនៈ បាទ!

ដានីៈ ចុះកាលជំនាន់ពនាំស្គាល់គាត់អត់?

ហឿនៈ អត់ស្គាល់ទេ ។

ដានីៈ ចុះតាមុត?

ហឿនៈ ឃើញតែកង់ទ័ពគាត់នៅពេញមុំជួរផ្ទះ លន់ នល់ ពីចំហៀងខាងត្បូងនៅលើតាម៉េត ទាំងអស់ មួយចំហៀងខាងត្បូងគេចែកឲ្យភាគនីរតី ។

ដានីៈ ចុះ មាស មុត ស្គាល់គាត់ច្បាស់អត់?

ហឿនៈ ស្គាល់ឆ្នាំ៧០ចេញពីព្រៃទៅនៅធ្វើមន្ទីនៅក្បែរផ្ទះខ្ញុំ ស្រែខ្ញុំ នៅក្នុងព្រៃទល់៧៦បានគេឲ្យខ្ញុំទៅយកពពែ យកសម្ភារៈកំប៉ិកកំប៉ុកមកដាក់មន្ទីរស្រុក ខ្ញុំទៅយកពពែបាន១២៣ពែ ហើយឥវ៉ាន់កំប៉ិកកំប៉ុកអត់មានប្រើកើតទេ ប្រើកើតតែពពែ ។

ដានីៈ ស្គាល់គាត់ឆ្នាំ៧០?

ហឿនៈ បាទ!

ដានីៈ គាត់ធ្វើមន្ទីរអីគេ? មន្ទីរតំបន់?

ហឿនៈ មន្ទីរហ្នឹងអត់ដែលឮឈ្មោះទៀត បើមន្ទីរតាម៉ុក ដឹង ។ មន្ទីរតាមុត អត់ដែលមានឈ្មោះ ។

ដានីៈ ស្គាល់គាត់តែឆ្នាំ៧០ ហើយក្រោយមកមានដែលស្គាល់គាត់ទៀតអត់?

ហឿនៈ ឡើងក្នុងដងវែកស្គាល់ ស្គាល់តាំងពី៧៥ ថ្ងៃ២៤ ខែ៤ ដែលរំដោះទូទាំងប្រទេសភ្លាម តាម៉ុក ប្រគល់អំណាចឲ្យ ថាឲ្យ មាស មុត នាំទ័ពឲ្យទៅនៅធ្វើចៅហ្វាយកោះកុង ។

ដានីៈ នៅណា?

ហឿនៈ ចៅហ្វាយកោះកុង ។

ដានីៈ ហើយម៉េចទៀតទៅ?

ហឿនៈ រឿងច្រើនណាស់ និយាយអត់ចប់ទេ នៅខេត្តកោះកុងពេលទៅដល់ ប្អូនជីដូនមួយខ្ញុំ ប្អូនយាយនេះមកប្រាប់ខ្ញុំ ហើយកូនខ្ញុំនៅហ្នឹង វាថាឪអើយខ្ញុំខ្លាចណាស់ គេសម្លាប់អីសម្លាប់ម្ល៉េះ ខ្ញុំអត់ហ៊ាននៅទេ ខ្ញុំថាទ្រាំទៅកូនកុំមាត់ ។

ដានីៈ ពីណាគេសម្លាប់?

ហឿនៈ កងតាញ៉ាន់ អ្នកសម្លាប់ តាមុត អ្នកបើកសិទ្ធិ ។

ដានីៈ តាញ៉ាន់ ហ្នឹងគាត់?

ហឿនៈ គាត់កងពលនៅខេត្តកំពតដែរ ស្រុកឈូក ។

ដានីៈ តាញ៉ាន់ហ្នឹង គាត់អ្នកស្រុកកំពតដែរ តែគាត់នៅក្នុងកងពលជាមួយតាមុត?

ហឿនៈ កងពលជាមួយតាមុត ។

ដានីៈ តាញ៉ាន់ហ្នឹងតូចជាងតាមុត?

ហឿនៈ តូច អនុតាមុតហ្នឹង ។

ដានីៈ ប៉ុន្តែកងតាញ៉ាន់ ហ្នឹងសម្លាប់ ។

ហឿនៈ អ្នកខាងសម្លាប់ ។

ដានីៈ សម្លាប់អីគេ?

ហឿនៈ សម្លាប់ពួកទាហាន ពួកស៊ីវិលនៅក្នុងក្រុងទាំងអស់អត់មានសល់មួយ ។

ដានីៈ ក្រុងណា? សម្លាប់នៅខាងណា?

ហឿនៈ សម្លាប់ខាងគណបក្សលន់ នល់ហ្នឹង ។ ពួកលន់ នល់ ចាញ់សង្គ្រាម តាម៉ុក ប្រកាសឲ្យទៅ នៅថ្ងៃទី២១ ខែ៤ហ្នឹងទៅ ។ នាំទ័ពទៅ ទៅដល់គេដាក់មេក្រូលើឡានគេប្រកាសថាកងទ័ព សាធារណរដ្ឋឲ្យដាក់កាំភ្លើងគរម្តុំ ប្រមូលមកគរម្តុំ ផ្ទះស្រុកកំណើតនៅណាគេជូនទៅ ទាំងអស់ គេនិយាយអីចឹង ដល់ហើយពួកហ្នឹងចាញ់បោកតាមុត យកកាំភ្លើងទៅគរដាក់ម្តុំ ប្រមូលសម្ភារៈគរជុំៗ គេយកឡានទៅដឹក ។ យកទៅដល់ឲ្យកាប់រណ្តៅក្បែរៗចំការដូង ចំការក្រូច, ចំការល្មុត, ចំការធុរេន កប់ជុំវិញរណ្តៅ កាប់ខ្លួនឯងកប់ខ្លួនឯង ទាក់ច្រវ៉ាក់ ជើងសម្លាប់ទាំងអស់ ។

ដានីៈ ហ្នឹងកូនអ៊ំគាត់?

ហឿនៈ កូនខ្ញុំរត់ចូលព្រៃជាមួយតាមុត ងាប់បាត់ទៀត ។

ដានីៈ កូនដែលដឹង?

ហឿនៈ ថាងាប់មួយហ្នឹង ។

ដានីៈ គាត់មកនិយាយប្រាប់អ៊ំហ្នឹង?

ហឿនៈ បាទ?

ដានីៈ កូនអ៊ំនិយាយប្រាប់ហ្នឹងគាត់ស្លាប់បាត់ហើយ?

ហឿនៈ ស្លាប់ហើយ ។

ដានីៈ ឈ្មោះអីគេ?

ហឿនៈ ខ្ញុំហៅតែអាបារាំង១ សរដូចបារាំងអីចឹង ។

ដានីៈ អ្នកមកនិយាយប្រាប់អ៊ំថា ។

ហឿនៈ ខ្លាច! គេសម្លាប់ទាំងឡាន១ ។

ដានីៈ ខែប៉ុន្មាន?

ហឿនៈ ៧៥ វាមកម្តង, ៧៦ មកម្តង មកផ្ទះមកនិយាយតែរឿងសម្លាប់ ។

ដានីៈ សម្លាប់នៅណាហ្នឹង?

ហឿនៈ នៅខេត្តកោះកុងហ្នឹង ទាហានទៅដល់មិនទៅពេញក្រុង គេអត់ដាក់អាវុធ កាំភ្លើង ដល់គេប្រកាសមេក្រូឲ្យដាក់កាំភ្លើងគរម៉ុំ ឥវ៉ាន់គរម៉ុំ គេដឹកយកទៅស្រុក មិនដឹកយកទៅស្រុក ដឹកយកទៅទាក់ប្រវ៉ាក់ជើង កាប់រណ្តៅជុំវិញដើមឈើហូបផ្លែហ្នឹង កប់ផាប់ ដល់ធ្លាក់ភ្លៀងមកផាប់ខ្ទិច ដល់ផាប់ខ្ទិចដំណាំហ្នឹងមនុស្សនៅអត់ទាន់អស់ ។

ដានីៈ តាញ៉ាន់ គាត់នៅរស់?

ហឿនៈ នៅរស់ ។

ដានីៈ គាត់ទៅណាឥឡូវ?

ហឿនៈ ឥឡូវហ្នឹងមិនដឹងនៅណាទេ ជួបការខ្ញុំចេញមកពីភាគខាងជើងគាត់នៅអន្លង់វែង តែមិនដឹងនៅហ្នឹង ឬក៏ចេញទេ ។

ដានីៈ អីចឹងសម្លាប់តាំងពីថ្ងៃ២៨ ខែ៥ ឆ្នាំ៧៥?

ហឿនៈ ថ្ងៃដែលតាមុតទៅដល់ ប្រកាសឲ្យដាក់កាំភ្លើងហើយ ថ្ងៃ២១-២២ ខែ៤ហ្នឹងទៅហើយ ទៅសម្លាប់តាំងពីថ្ងៃហ្នឹង ដាក់មេក្រូតាំងពីថ្ងៃហ្នឹង ។

ដានីៈ តាមុត គាត់នៅកោះកុង នៅណាទៀត?

ហឿនៈ អត់ដឹង ។

ដានីៈ កំពង់សោម គាត់នៅដែលអត់?

ហឿនៈ កោះកុង-កំពង់សោម ទីក្រុងខេត្តកោះកុង-កំពង់សោម ។

ដានីៈ កាលហ្នឹងអ៊ំដឹងតាមកូនអ៊ំនិយាយប្រាប់?

ហឿនៈ ដឹងតាមកូន ហើយអ្នកស្រុកគេទៅហូរហែរមកនិយាយខ្សឹប ដឹងទាំងអស់ ។

ដានីៈ ប៉ុន្តែអ៊ំអត់ដែលឃើញផ្ទាល់ភ្នែកទេ?

ហឿនៈ	អត់ទេ  អត់ដែលទៅដល់ទេ  កូនខ្ញុំនៅជាមួយវានិយាយថាឃើញគេសម្លាប់ទាំងឡានៗខ្វាច ដល់ឆ្នាំ៧៦  គេដុតកប៉ាល់ម៉ាយ៉ាគេសមួយ  អាធន់ទី៦លើសកលលោកមិនឆេះ៣ខែ  គេប្រមូលរបស់ណាសំខាន់ៗយកមកគោកអស់  ហើយគេដុតកប៉ាល់ធំខ្វាំងណាស់ថាចុះព្រលានយន្តហោះបាន  ហើយដុតនៅកណ្តាលសមុទ្រ៣ខែបានឆេះបានលិច ។

ដានីៈ	ហើយម៉េចបានអ៊ំដឹងថាគេដុតកប៉ាល់ម៉ាយ៉ាគេសហ្នឹង?

ហឿនៈ	អាហ្នឹងខ្ញុំទៅរៀនចៅហ្វាយខេត្តគេនិយាយ ។

ដានីៈ	ចៅហ្វាយខេត្តណា?

ហឿនៈ	ចៅហ្វាយខេត្តហ្នឹងឈ្មោះ  តាគាវ  ហ្នឹង ។

ដានីៈ	តាគាវ?

ហឿនៈ	បាទ!  គាត់ធ្វើចៅហ្វាយខេត្តគាត់បើកវគ្គ ។

ដានីៈ	គាត់និយាយថាម៉េច?

ហឿនៈ	និយាយថាឆ្នាំ៧៦  កប៉ាល់ម៉ាយ៉ាគេស  អាទី៦លើសកលលោកមានព្រលានយន្តហោះចុះ ហើយទាហានរាប់រយមកចតនៅកណ្តាលទន្លេ  ហើយយើងចាប់មកខុសច្បាប់គេចាប់ ហើយទាហានទាំងអស់ហ្នឹងគេយកមកកប់ក្បែរដើមឈើទាំងអស់  សម្លាប់ទាំងអស់  ហើយដុតកប៉ាល់ហ្នឹងឆេះអស់ ។

ដានីៈ	ទាហានទាំងអស់ហ្នឹងគេកប់ក្បែដើមឈើនៅណា?

ហឿនៈ	កប់ក្បែរដើមឈើមិនដឹងនៅត្រង់ណា  បើអត់ដែលទៅដល់គេថាកប់ ។

ដានីៈ	គេថាចាប់បាននៅម្តុំណា?

ហឿនៈ	ចាប់ក្នុងសមុទ្រមិនដឹងត្រង់ណា ។

ដានីៈ	តាគាវ  អ្នកនិយាយប្រាប់?

ហឿនៈ	តាគាវ  គាត់បើកវគ្គបង្រៀន ។

ដានីៈ	អ៊ំដែលជួបតាម៉ុក  ទេ?

ហឿនៈ	ជួប  ទើបតែបែកកាលមកពីដើង ។

ដានីៈ	តែកាលជំនាន់អ៊ំនៅធ្វើសមាជិកស្រុកត្រាំកក់  ដែលជួបតាម៉ុក,  តាម៉ុកមានដែលបង្រៀន មានដែលនិយាយប្រាប់ទេ?

ហឿនៈ	តាម៉ុក  អត់ដែលបានរៀនជាមួយទេ  ថ្នាក់តូចៗគេអត់ឲ្យទៅរៀនសាលាភូមិភាគផង ។

ដានីៈ	ទាល់តែថ្នាក់ណាបានគេឲ្យរៀនសាលាភូមិភាគ?

ហឿនៈ ទាល់តែគេអ្នកធំ ចៅហ្វាយស្រុក ចៅហ្វាយខេត្ត គេបានទៅចូលរៀន ខ្ញុំត្រឹមសមាជិកគេ គេអត់ឲ្យទៅរៀន រៀនត្រឹមចៅហ្វាយខេត្ត។

ដានីៈ កាលហ្នឹងប្រពន្ធកូនអ៊ំ ម្ដាយអ៊ី មកនៅក្នុងមន្ទីរស្រុកដែរ ឬយ៉ាងម៉េច?

ហឿនៈ អត់ទេ នៅផ្ទះវែកតែដី ម៉ែខ្ញុំចាស់ គេឲ្យប្រមូលបន្លែ ធ្វើបាយឲ្យសហករណ៍ហូបហ្នឹង។

ដានីៈ កាលពីអ៊ំមានប្រសាសន៍មិញថាប្រពន្ធតាមុត ឈ្មោះយាយខុម រកសម្លាប់ ចង់សម្លាប់ ម្ដាយអ៊ំហ្នឹង តាំងពីឆ្នាំណា?

ហឿនៈ ឆ្នាំ៧៦ គាត់នៅស្រុកទេ ដល់តាម៉ុក។ យាយខុមហ្នឹងសម្លាប់ក្មើតាម៉ុក ឈ្មោះជិទប់ ជា, កង ជា ដល់សម្លាប់បាត់ គេរាយការណ៍ទៅថាសម្លាប់ជិទប់ ជា បាត់។ សម្លាប់ជិទប់ ជា តាម៉ុកធ្វើមេទ្ទិញនៅទំនប់ខ្ពបតាពែក។ លើកទំនប់ហ្នឹងមនុស្សមួយខេត្ត ហើយគាត់ទៅធ្វើ មេទ្ទិញថាអាណាសម្លាប់អាជិទប់ ជា ឲ្យចៅហ្វាយស្រុកហ្នឹងរកឲ្យឃើញ បើរកមិនឃើញទេ កប់ត្រឹមកបរនោសដែកពាស់ ធ្វើមេទ្ទិញពាជង យាយខុម រត់ប្រុច រត់ទៅដល់កោះកុង ផាប់។ ផាប់ស្អុយអត់មានអ្នកណាហ៊ានដាស់ ដេកលើគ្រែ មេមនុស្សប៉ុណ្ណឹង ហើមស្អុយ យកបបរទៅក៏អត់ហ៊ានដាស់ ថ្ងៃម៉ោង១១យកបាយទៅរុយទុំៗមុខ ស្អុយហៅគេហៅឯង មកស្អុយហើយ។

ដានីៈ អ៊ីចឹងតាម៉ុក គាត់រកឲ្យគេសម្លាប់កូនគាត់ដែរ?

ហឿនៈ គាត់ថា គាត់ថាខ្លួនគាត់ឲ្យចៅហ្វាយស្រុកត្រាំកក់រកអ្នកសម្លាប់ជិទប់ ជា ឲ្យឃើញ បើរក មិនឃើញអាចៅហ្វាយស្រុកហ្នឹង តាម៉ុក គាត់កប់ត្រឹមកបរនោសដែកពាស់ និយាយ មេទ្ទិញបីដង នៅភូមិគោកត្បែង បីដងយាយខុម ភ័យរត់ទៅប្ដីគាត់នៅខេត្តកោះកុង រត់ ទៅហ្នឹង ទៅដល់ហ្នឹងផាប់ ធ្វើបាបគេ អ្ហូ!ទៅមើលក្រាំងតាចាន់ មានតែយាយខុម ហើយ និងតាជឹមហ្នឹងទេ។

ដានីៈ និយាយពីរឿងនៅត្រាំកក់វិញ នៅត្រាំកក់មានការសម្លាប់ច្រើនដែរ?

ហឿនៈ ភូមិចាស់ទាំងអស់អត់មានមនុស្ស គេថាសុទ្ធតែនិន្នាការនយោបាយ សុទ្ធតែសម្លាប់ទាំង អស់ ដូចខ្ញុំវិញគេរកតែសម្លាប់។

ដានីៈ ក្រែងតាជឹម បងប្អូនអ៊ំម៉េចបានគេរកសម្លាប់?

ហឿនៈ បានតាហ្នឹងហើយយកទៅដាក់មន្ទីរស្រុកកុំឲ្យគេមើលងាយ ទៅដល់ហ្នឹងយាយខុម ទៅរក យកសម្លាប់ទៀត។ ហើយអាជន ថាក្រែងប្អូនតាជឹម ប្អូនណាអញមិនដែលស្គាល់ជឹម ណា វានិយាយសំឡុត តាជន ហ្នឹងអ៊ីចឹង។ អាជន ហ្នឹងអនុតាជឹម។

ដានី៖ យាយខុម គាត់នៅស្រុកត្រាំកក់ដល់ឆ្នាំណាបានគាត់រត់មកស្លាប់?

ហឿន៖ គាត់ចេញពីព្រៃទៅគេចាត់តាំង តាំងពីថ្ងៃចេញពីព្រៃ។

ដានី៖ តែគាត់នៅត្រាំកក់ហ្នឹងរហូតដល់ឆ្នាំណា?

ហឿន៖ នៅស្រុកត្រាំកក់ ៧៦បានតាម៉ុក រកសម្លាប់ បានរត់ទៅ។ ៧៦ ចេញហើយតាជឹម គេឡើងធ្វើមេ។

ដានី៖ ជំនាន់តាជឹម ឡើងធ្វើមេគាត់មានសម្លាប់ច្រើនទេ?

ហឿន៖ ខ្លាំងណាស់ ទ័ពចេញមកពីកងតាវ៉ែន ចេញមកពីកង៥២០០ តាជឹម ឲ្យគេដើរពិនិត្យប្រវត្តិរូប ពិនិត្យទៅឃើញពាក់ព័ន្ធម៉ែធ្លាប់ធ្វើអីៗ ប្រពន្ធទាហាន ធ្វើប៉ូលីស គេយកទៅសម្លាប់ទាំងអស់ ហើយមកពីកងមក ប្អូនខ្ញុំជីដូនមួយ ម៉ែវាយួនដូចខ្ញុំដែរ ឪវាយួន ម៉ែវាខ្មែរ មកសុំខោខ្ញីមួយស្លៀក ស្បែកជើងគេដោះយក អាវគេដោះយក មួកគេដោះយក គ្រាន់តែចប់សង្គ្រាម។ ហើយវាដើរមកពីកោះអណ្តែតដើរមកផ្ទះ សុំសំបុត្រសុំបាយគេហូបមិនបាច់សំបុត្រទេ មានស៊ីក៏ស៊ី អត់ស៊ីអត់ទៅ វាដើរមកមួយយប់មួយថ្ងៃបានដល់ផ្ទះ មកពីព្រំដែនយួនមក។

ដានី៖ កាលជំនាន់តាជឹម ក៏សម្លាប់ច្រើនដែរ?

ហឿន៖ ទៅមើលជំរុក បើខ្ញុំភរ។

ដានី៖ សម្លាប់នៅណាទៅ?

ហឿន៖ គេបញ្ជូនមកព្រៃ គេយកសម្លាប់ក្នុងព្រៃ ដល់ហើយគេរើសក្បាលយកទៅដាក់ក្រោមដូវមៃព្រៃ ជិតហ្នឹង ក្រាំងតាចាន់។

ដានី៖ គេយកទៅសម្លាប់នៅក្រាំងតាចាន់ហ្នឹង?

ហឿន៖ ក្បាលខ្មោចយកទុកក្រាំងតាចាន់ ហើយព្រៃជាប់ក្រាំងតាចាន់នៅហៅព្រៃខ្មោចកូនក្មេងព្រៃស្រម៉រ។

ដានី៖ កាលហ្នឹងអ៊ំធ្វើនៅក្នុងសមាជិកស្រុកដែរ អ៊ំនិយាយអីចឹងអ៊ំអត់មានពាក់ព័ន្ធចាប់មនុស្សយកទៅ?

ហឿន៖ ពាក់ព័ន្ធអីខ្ញុំអត់ដឹងព្ទុ គេមិនមែនឲ្យដឹងព្ទុទេ។

ដានី៖ គេអត់ឲ្យអ៊ំដឹងទេ?

ហឿន៖ អត់ដឹងទេ។

ដានី៖ តាជីម បងប្អូនអីដែរ ម៉េចបានអីនិយាយថា មូលហេតុអីបានអីហ៊ាននិយាយប្រាប់ខ្ញុំដែលថាទាក់ទង?

ហឿន៖ រកតែសម្លាប់ខ្ញុំហ្នឹង។

ដានី៖ តាជីម ហ្នឹងរកសម្លាប់អីដែរ?

ហឿន៖ សម្លាប់ខ្ញុំ ចូលព្រៃហើយហ្នឹង ខ្ញុំរត់ចេញ គេឲ្យទ័ពតាមទៅបាញ់ខ្ញុំ គ្នា១៥នាក់ បេ២ដើមទៅឃើញខ្ញុំគេភ្ជន់ លើកបេអីចឹងគ្នា២នាក់ គ្នា១៥នាក់ផាកមើលខ្ញុំទាំងអស់។ ហើយខ្ញុំនៅជាមួយកងពលធំ តាជុំ ហ្នឹងវាអត់ហ៊ាន កងពលតាជុំ មនុស្សដូចស្រមោច។

ដានី៖ តាជីម ហើយនិងអីមានទំនាស់គ្នាពីអន្លាល់?

ហឿន៖ ចូលព្រៃ! តាជីម ចូលព្រៃ អាមួយធ្វើប្រធានមន្ទីរ តាជីម ហ្នឹងនៅជប់ ដល់រត់ចូលព្រៃគេឲ្យនៅជាមួយប្រពន្ធ។ ប្រពន្ធយួនវៃទៅបែករត់បាត់ គេយកអាយន់ ហ្នឹងទៅដាក់នៅកន្លែងទាហាន វានៅមន្ទីរគេលែងឲ្យនៅជាមួយតាជីម យកទៅដាក់ជាមួយកងទ័ព ដល់ហើយគេថាអាហ្នឹងក្បត់ឲ្យប្រពន្ធអញបាត់។ ប៉ុន្តែទៅរកវិញឃើញ ដល់រកឃើញគេប្រជុំគ្នា៥-៦នាក់ គេឯកភាពជាមួយតាជីម ហ្នឹង ខ្ញុំថាខ្ញុំអត់ឯកភាពទេ ព្រោះគេមកដល់ស្រុកគេ ប្រពន្ធគេអត់ស្គាល់អ្នកណា អត់មានញាតិមិត្ត គេទុកប្រពន្ធគេ បេះចេញពីដើមទ្រូងហើយគេរត់មកនៅជាមួយយើង គេស្រឡាញ់យើង គេយកយើងធ្វើម៉ែឪ ហើយឲ្យខ្ញុំសំរេចចិត្តតាមសម្លាប់គេ ខ្ញុំអត់ហ៊ានទេ ខ្ញុំអត់សម្លាប់ទេ គេកន្ទ្រប់ដី ស្រែកផាង។

ដានី៖ គេថាម៉េច?

ហឿន៖ ស្រែកផាង។

ដានី៖ គេស្រែកថាម៉េច ចាំទេ?

ហឿន៖ កន្ទ្រប់ដី អីចឹងតើបានអញអត់ហៅហ្វែងមកហ្នឹង អីៗអត់ចេះឯកភាពទេ និយាយអីចឹងនិយាយតែប៉ុណ្ណឹង ហើយខ្ញុំគេប្រជុំចប់ខ្ញុំមក មកដល់កន្លែងខ្ញុំដី១០គីឡូ ក្នុងព្រៃ ដល់មកដល់១០គីឡូ ខ្ញុំមកដល់បបរស៊ីហើយ នីរសារគេឲ្យមកសម្លាប់ខ្ញុំ មកដល់នីរសារហ្នឹងយកពីកំលាំងខ្ញុំទៅ មកដល់យំវ៉ូ ខ្ញុំថាឯងយំអី អន្តរអញនៅបបរស៊ីទៅ អត់ទេ តាឲ្យខ្ញុំមកសម្លាប់ពូឯងតើ តែខ្ញុំអត់ហ៊ានសម្លាប់ពូឯងទេ បើពូឯងឲ្យខ្ញុំទៅសម្លាប់តាខ្ញុំទៅឥឡូវហ្នឹងវាថាអីចឹង ថាកុំៗចងគំនុំ កុំសងឈាម ឯងទៅជាមួយអញ យប់ហ្នឹងខ្ញុំនាំគ្នារត់ទៅខាង... នៅខាងព្រៃចំការកៅស៊ូ ចំការអណ្តូងនៅខាងជើងហ្នឹង ហៅភូមិអូរសន្ទរ។

ដានី៖ ឆ្នាំណាដែលគេ?

ហឿនៈ ឆ្នាំ៨០ហើយ ខែ៧ ខ្ញុំរត់។

ដានីៈ ឆ្នាំ៨០ហើយនៅរកសម្លាប់គ្នាទៀត?

ហឿនៈ សម្លាប់! នៅក្នុងព្រៃវាសម្លាប់តែគេហ្នឹង។

ដានីៈ ប៉ុន្តែក្រែងប្រពន្ធគាត់ ប្រពន្ធអ៊ំ បងប្អូនគ្នាបង្កើត ម៉េចបានគាត់នៅមានចងគំនុំជាមួយអ៊ំ?

ហឿនៈ ព្រោះខ្ញុំអត់ឯកភាពជាមួយគាត់ ថាយកគេទៅសម្លាប់ ហើយខ្ញុំអត់ឯកភាព។

ដានីៈ ហើយអ៊ំហើយនិងគាត់អត់ត្រូវគ្នាដល់ឥឡូវ?

ហឿនៈ អត់! រកសម្លាប់៣ដង នៅហ្នឹងរកសម្លាប់៣ដង ដល់ហើយខ្ញុំឡើងភ្នំដងរែកទៅជាមួយគាត់ទៀត ទៅជាមួយគាត់សម្លាប់ខ្ញុំអត់បាន គាត់ដកសិទ្ធិខ្ញុំ គាត់ប្រាប់ថាខ្ញុំរត់ចោលជួរ ខ្ញុំទៅដេកពេទ្យហើមប៉ុណ្ណណី បត់ដៃ បត់ជើង អត់រួចទេនៅគ្រង់ភ្លឹង ដល់ហើយ តាម៉ុក ត្រូវផ្លាស់មកបើកច្រក១០០១ តាម៉ុក ចូលសួរពេទ្យថា ម៉េចមិត្តដែលអញឲ្យយកមកព្យាបាលជានៅ? ទៅជាមួយអញរួចទេ? គាត់ថាអត់ទេ នៅហើមបត់ដៃជើងអត់កើត នៅគ្រង់ភ្លឹង។ យី! ឯងតែងាប់មនុស្សហ្នឹងឯងក៏ងាប់ដែរ សំឡុតអីចឹង បានពេទ្យឲ្យខ្ញុំលេបបេអង ២-៣ដងខ្ញុំស្រកហើម។

ដានីៈ កាលហ្នឹងអ៊ំឈឺបានហើម?

ហឿនៈ ហើមទៅក្នុងហ្នឹងអត់មានបាយហូប ដល់ហូបបាយហើម ហើមបាយ ហើមធំណាស់ អង្កុញជើងអត់កើត នៅគ្រង់ភ្លឹង ហើមស្ពឹញ គ្រែមួយដេកតែឯង ហើមហើយពេទ្យអត់មើល តាជឹមទៅដកសិទ្ធិខ្ញុំ ប្រាប់ថាកុំឲ្យព្យាបាល គេអត់ឲ្យថ្នាំលេប។

ដានីៈ ឆ្នាំណាអ៊ំ?

ហឿនៈ ឆ្នាំ៨០គត់។

ដានីៈ នៅណា?

ហឿនៈ ខែ៧ហើយឡើងទៅដល់លើភ្នំដងរែក ទៅដេកពេទ្យនៅច្រក១០០១។

ដានីៈ ក្រែងច្រក១០០១ ច្រករបស់សុន សេន តើ?

ហឿនៈ ហ្នឹងហើយ ដល់តាម៉ុក ចេញមកតាសេន នៅច្រកហ្នឹង។ ដល់ខ្ញុំសុំ តាសុន សេន មកនៅជាមួយតាម៉ុក សុំគេអត់មាត់ គេអត់ថា ដល់សុំ៣-៤ដងក៏គេអត់ឲ្យ ខ្ញុំសុំថា ឥឡូវបើអត់ឲ្យខ្ញុំទៅទេ ខ្ញុំសុំរស់នៅជាមួយអ៊ំ នៅក្នុងមន្ទីរ អីចឹងគេសំរេចឲ្យខ្ញុំនៅ។ ឲ្យខ្ញុំនៅគេឲ្យនាំនារី២០០ទៅបេះស្លឹកខាន់មាប្រក់ផ្ទះ ខ្ញុំថាមិនដឹងលិចកើតឯណា ឲ្យខ្ញុំទៅ ខ្ញុំអត់ទៅ ទល់

ម៉ោង១១ ខ្ញុំនៅតែប្រកែក នៅតែដេញ ខ្ញុំអត់ទៅ គេរកមនុស្សទៅផ្ទះ។ ហើយគេឲ្យខ្ញុំធ្វើផ្ទះ ធ្វើសាលារៀននយោបាយគេ។

ដានីៈ អ៊ំមានប្រសាសន៍ថាឆ្នាំ៧៨ អ៊ំផ្លាស់មកកំពង់ចាម?

ហឿនៈ បាទ!

ដានីៈ ឆ្នាំ៧៨ ខែប៉ុន្មានដែលអ៊ំផ្លាស់?

ហឿនៈ ខ្ញុំចេញ៧៨ ខែ៨ មកដល់កំពង់ចាម។

ដានីៈ ជិតបែកហើយហ្នឹង?

ហឿនៈ បាទ! ៧៨មកបានប៉ុន្មានខែហ្នឹង ៧៩យួនចូល។

ដានីៈ កាល៧៨ ម៉េចបានអ៊ំផ្លាស់ពីត្រាំកក់មកកំពង់ចាម?

ហឿនៈ ផ្លាស់ហ្នឹង តាជឹម គេមក ហើយខ្លាចគេធ្វើបាបខ្ញុំ ខ្ញុំចេញមក ខ្លាចតាសឿន មករករឿងខ្ញុំបាន អ៊ីចឹងយកខ្ញុំមកតាមទៀត។

ដានីៈ ប៉ុន្តែកាលហ្នឹងអ៊ំហើយនិងតាជឹម ត្រូវគ្នាទេ អត់ទាន់ឈ្លោះគ្នា?

ហឿនៈ អត់អីទេ ទើបតែចូលព្រៃបានរកសម្លាប់ខ្ញុំ ហើយសម្លាប់ខ្ញុំអត់បាន ទៅសម្លាប់ប្រពន្ធអាដែលទុកប្រពន្ធភូមិរត់មកជាមួយខ្ញុំ ថាទុកយើងជាម៉ែឪរកសម្លាប់គេខ្ញុំអត់ឯកភាព ដល់ប្ដីវាខ្ញុំលួចខ្សឹបប្រាប់ថារត់ទៅគេរកសម្លាប់ហើយ យើងរត់ទៅ ប្រពន្ធនៅហ្នឹងគេឲ្យយកអង្រឹងទៅចងក្នុងព្រៃតែឯង ល្ងាចគេទៅសម្លាប់ទៅកូនមួយទៀត។

ដានីៈ អ៊ំកាលហ្នឹងខែ៨ហើយ តាជឹម គាត់ផ្លាស់ទៅកំពង់ចាម?

ហឿនៈ បាទ!

ដានីៈ តាជឹម ពីណាគេអ្នកបញ្ជូនគាត់?

ហឿនៈ តាម៉ុក។

ដានីៈ តាម៉ុកបញ្ជូនទៅ។

ហឿនៈ បាទ!

ដានីៈ តាជឹម ហើយនិង តាម៉ុក គាត់ត្រូវគ្នាយ៉ាងម៉េចបានគាត់បញ្ជូនទៅ?

ហឿនៈ អ្នកដ៏ទៃទេ អត់នៅជិតទេ នៅភូមិជាមួយគ្នា នៅជិតៗគ្នា ភូមិកំណើតតាម៉ុក នៅជាប់ភូមិគ្នា។

ដានីៈ ខែ៨ អ៊ំទៅកំពង់ចាម ចេញពីតាកែវទៅកំពង់ចាមតែម្ដង ឬក៏មានចូលនៅភ្នំពេញ?

ហឿនៈ អត់ទេ! ទៅរហូតមួយយប់ទល់ភ្លឺដល់។

ដានី៖ ទៅរហូតមួយយប់ទល់ភ្លឺដល់?

ហឿន៖ បាទ!

ដានី៖ ទៅដល់កំពង់ចាមជួបពីណាដំបូង?

ហឿន៖ អត់មានជួបទេ ទៅរហូត។

ដានី៖ ទៅរហូត?

ហឿន៖ បាទ! ឡានអត់ឈប់ភ្នំពេញផង។

ដានី៖ ជិះឡានអីទៅកាលហ្នឹង?

ហឿន៖ ឡានច្រើនណាស់កាលហ្នឹង កាលហ្នឹងឡានទាហាន លន់ នល់ នៅលើស្រុក លើខេត្តទាំងអស់។

ដានី៖ ទៅគ្នាប៉ុន្មាន?

ហឿន៖ ខ្ញុំទៅ៤០នាក់មួយឡានហ្នឹង។

ដានី៖ ៤០នាក់ បើតាមអ៊ំចាំ តាជឹម, អ៊ំ ហើយពីណាទៀត?

ហឿន៖ ច្រើនណាស់រាប់មិនអស់ទេ។

ដានី៖ ច្រើនណាស់?

ហឿន៖ បាទ! ២០០នាក់។

ដានី៖ ជិះឡានទៅឈប់នៅណាទៅ?

ហឿន៖ ឈប់នៅរោងចក្រជប់ហ្នឹងតែម្ដង ក្បែររោងចក្រហ្នឹងតែម្ដង នៅចាត់ការគេរោងចក្រហ្នឹង។

ដានី៖ ជប់ហួសទន្លេបិទទៀត?

ហឿន៖ឆ្លងពីទន្លេបិទទៅ១០គីឡូគត់ ទៅពីទន្លេបិតទៅ១០គីឡូ។

ដានី៖ ខែ៨ហ្នឹង?

ហឿន៖ ខែ៨ ឆ្នាំ៧៨។

ដានី៖ ហើយទៅដល់អ៊ំជួបពីណាគេខ្លះ?

ហឿន៖ អត់មានជួបពីណាទេ ជួបតែតាជឹម គេធ្វើមេនៅហ្នឹង។

ដានី៖ តាជឹម គាត់ធ្វើមេអីគេ?

ហឿន៖ ធ្វើគណៈក្រសួងហ្នឹង សមាជិកភូមិភាគ។

ដានី៖ ភូមិភាគអីគេកាលហ្នឹង?

ហឿនៈ	ភូមិភាគហ្នឹងគេហៅភូមិភាគបូព៌ា ហើយតាសុន សេន មេភូមិភាគ ។

ដានីៈ	ហើយអ៊ំកាលហ្នឹងជាអី?

ហឿនៈ	គេឲ្យខ្ញុំនៅឃ្លាំង ភស្តុភារ ។

ដានីៈ	ភស្តុភាររបស់?

ហឿនៈ	របស់តាជឹម ។

ដានីៈ	តាជឹម គាត់ទៅគណៈចំការកៅស៊ូនៅ?

ហឿនៈ	នៅជប់ ។

ដានីៈ	ហើយគាត់ជាសមាជិកភូមិភាគបូព៌ា?

ហឿនៈ	បាទ!

ដានីៈ	ហើយអ៊ំទទួលភស្តុភាររបស់ចំការកៅស៊ូជប់?

ហឿនៈ	បាទ!

ដានីៈ	កាលហ្នឹងអ៊ំស្គាល់ឈ្មោះតាអាន ដែលអត់?

ហឿនៈ	តាអាន តំបន់៤១ ចេញពីកំពង់ចាមមកតំបន់៤១ហ្នឹងហើយ គាត់ពីកំពង់ចាមបន្តិច គាត់ពីកំពង់ធំបន្តិច នៅហ្នឹង ហើយខ្ញុំបែកមកពីអូរត្រាវមក ខ្ញុំបែកមកលែងជួបគាត់ហើយ ។

ដានីៈ	ចុះអ៊ំស្គាល់ តាអាន តាំងពីអង្កាល់មក?

ហឿនៈ	ស្គាល់ចូលព្រៃហ្នឹងបានស្គាល់ច្បាស់ នៅជាប់ជាមួយគាត់ ។

ដានីៈ	កាលចូលព្រៃបែក៧៩ហើយ?

ហឿនៈ	បាទ!

ដានីៈ	ចុះកាលពីមុនពេលដែលមុនហ្នឹង កាលអ៊ំនៅត្រាំកក់ អ៊ំទៅខាងកំពង់ចាមអីស្គាល់គាត់នៅ?

ហឿនៈ	អត់ដែលទៅដល់ទេ ។

ដានីៈ	អត់ដែលស្គាល់គាត់ទេ?

ហឿនៈ	អត់ទេ ដល់រត់ហើយបានដឹង ។

ដានីៈ	ប៉ុន្តែដឹងថាគាត់នៅតំបន់៤១ តាំងពីអង្កាល់?

ហឿនៈ	នៅ៤១ខ្ញុំជួបកាល៧៩រត់ទៅជួបគាត់ គាត់ចាប់កំលាំងកម្មករកៅស៊ូ១០នាក់យកដាក់ក្នុងគុក ។

ដានីៈ	ដាក់គុកនៅណា?

ហឿន៖ គុកតំបន់៤១ជិតចំការលើ ដល់គេរាយការណ៍មកគេឲ្យខ្ញុំទៅសុំ ទៅដល់សុំស្គាល់តាំងពីហ្នឹង មក សុំតាអាន ហើយគេដោះឲ្យមកវិញមកថាចំការកៅស៊ូ ។

ដានី៖ រត់ឆ្នាំណាហ្នឹង?

ហឿន៖ រត់ឆ្នាំ៧៩ ។

ដានី៖ ឆ្នាំ៧៩បែកហើយហ្នឹងគាត់នៅចាប់ដាក់គុកទៀត? មុនយួនចូលដល់កំពង់ចាម?

ហឿន៖ រត់ហ្នឹងគេថាគេញយួន គេចាប់ដាក់គុក ឃុំឃាំងគេអត់ស្គាល់ ។

ដានី៖ ភូមិអីគេ?

ហឿន៖ ដាក់គុកមិនដឹងភូមិអី ខ្ញុំអត់ដឹង ។

ដានី៖ កាលហ្នឹងតាអាន គណៈតំបន់៤១?

ហឿន៖ ចៅហ្វាយខេត្តហ្នឹង ។

ដានី៖ ចៅហ្វាយខេត្ត៤១?

ហឿន៖ តួអង្គចៅហ្វាយខេត្ត ។

ដានី៖ តាអាន ហ្នឹងបានជួបគាត់ពេលហ្នឹង ហើយអនុគាត់មានដែលឃើញ ដែលអត់?

ហឿន៖ ដូចអត់មានឃើញ ឃើញតែមួយៗមេៗហ្នឹង ។ ដូចតាស៊ឹម ក៏ជួបតែតាស៊ឹម ។

ដានី៖ តាស៊ឹម អ៊ំស្គាល់គាត់តាំងពីអង្កាល់?

ហឿន៖ ស្គាល់ចូលព្រៃ បើប្រពន្ធនៅស្រុកជាមួយគ្នា ស្គាល់តាំងពីក្មេងៗ ។

ដានី៖ តាស៊ឹម ប្រពន្ធគាត់ឈ្មោះអី?

ហឿន៖ ឈ្មោះមីសេម ។

ដានី៖ ឈ្មោះ សេម?

ហឿន៖ ម៉ម សេម ។

ដានី៖ គាត់មានកូនចៅប៉ុន្មាននាក់ដែរ អ៊ំមានដឹងទេ?

ហឿន៖ អត់ដឹងទេ អត់ដឹងគេកូនប៉ុន្មាន ។

ដានី៖ ហើយតាស៊ឹម កាលហ្នឹងគាត់ធ្វើអីដែរ?

ហឿន៖ កាលហ្នឹងចៅហ្វាយខេត្តតំបន់៤៣ ។

ដានី៖ ៤៣នៅណា?

ហឿន៖ នៅខេត្តកំពង់ធំចំ ។

ដានី៖ តាស៊ឹម ហ្នឹងអ្នកស្រុកកំណើតនៅណា?

ហឿនៈ	គេថានៅកំពង់ឆ្នាំង ។

ដានីៈ	ហើយប្រពន្ធគាត់ ម៉ម សេម ហ្នឹងនៅ?

ហឿនៈ	នៅស្រុកត្រាំកក់ ។

ដានីៈ	នៅស្រុកជាមួយអ៊ំដែរ?

ហឿនៈ	ហ្នឹងហើយ ស្រុកជាមួយគ្នា ភូមិជាប់គ្នា ។

ដានីៈ	ត្រូវជា?

ហឿនៈ	ត្រូវជាជីដូនមួយខ្ញុំទៀត ។

ដានីៈ	ភូមិជាមួយគ្នាអត់?

ហឿនៈ	ភូមិតូចមួយគេកាត់ជាពីរទៅ ។

ដានីៈ	នៅភូមិអីគេ?

ហឿនៈ	ភូមិត្រពាំងគល់ ។

ដានីៈ	ឃុំត្រពាំងធំខាងត្បូង?

ហឿនៈ	ត្រពាំងធំខាងត្បូង ស្រុកត្រាំកក់ ។

ដានីៈ	ឪពុកគាត់ឈ្មោះអី?

ហឿនៈ	ឈប់ខ្ញុំរកនឹក ឈ្មោះតាដួន យាយសើម ។

ដានីៈ	សេម គាត់មានបងប្អូនប៉ុន្មាននាក់?

ហឿនៈ	ខ្ញុំភ្លេចហើយ បងវាមួយធ្វើគ្រូបង្រៀន, មីសេម, មីស៊ីម បងមីសេម, ហើយបែបមានតែ៣នាក់ ដឹងតែ៣នាក់ ។

ដានីៈ	ដឹងស៊ីម បងសេម?

ហឿនៈ	មីស៊ីម បងមីសេម ហើយមួយទៀតឈ្មោះអីស្រី ភ្លេចឈ្មោះគេទៀតហើយ ។ មីស៊ីមបងគេបង្អស់ ។

ដានីៈ	ស៊ីម គាត់នៅណាឥឡូវ?

ហឿនៈ	ស៊ីម ស្លាប់ទៀតហើយនៅតែប្តី ហើយមីស៊ន់ ពៅគេ ។

ដានីៈ	ស៊ន់ នៅណា?

ហឿនៈ	ស្លាប់បាត់ហើយ នៅតែប្រពន្ធអាណែមមួយហ្នឹង មីស៊ីម ។

ដានីៈ	សេម ឥឡូវគាត់នៅណា បើតាមអ៊ំដឹង?

ហឿនៈ មិនដឹងនៅណា ឆ្នាំដែលគេចាត់តាំងរដ្ឋអំណាច គេចាត់តាំងខ្មែរៗចេញមកក្រៅអស់មកមិនដឹងគេធ្វើអី ដល់ចូលព្រៃបានជួបប្ដីគេមានឈ្មោះ ស៊ីម ហ្នឹង ។

ដានីៈ ស៊ីម ហ្នឹងជួបគាត់នៅណា?

ហឿនៈ ជួបនៅភ្នំដងរែក អ៎! ចូលព្រៃនៅជាមួយគ្នា ចូលព្រៃជួបមីសេម, មីស៊ីម រត់តាមគ្នារហូត ដល់ឡើងភ្នំជួបគាត់ទៀត ។

ដានីៈ ដល់ជួបហើយ ស៊ីម ហ្នឹងនៅរស់ ឬស្លាប់ហើយ?

ហឿនៈ ស្លាប់ហើយ ។

ដានីៈ ស្លាប់នៅណា?

ហឿនៈ ស្លាប់នៅភ្នំក្បាលឡានឆ្នាំ៩៧រត់ឡើងភ្នំមួយសារ កើតទាចស្លាប់នៅហ្នឹង ។

ដានីៈ ស៊ីម គាត់ស្លាប់ហើយ តែសេម?

ហឿនៈ សេម នៅទេ ។

ដានីៈ នៅណាទេ?

ហឿនៈ នៅផ្ទះមួយហ្នឹង ។

ដានីៈ នៅភូមិផ្ទះមួយ?

ហឿនៈ បាទ ។

ដានីៈ ផ្ទះមួយនៅម្ដុំណា?

ហឿនៈ អត់ដឹងទេ ។

ដានីៈ បើយើងជិះទៅ យើងជិះតាមផ្លូវណាវិញ?

ហឿនៈ ទៅក្រពើពីរ វាលចំបាំងឡើងទៅដល់ផ្ទះមួយ ។

ដានីៈ ទៅតាមក្រពើពីរ?

ហឿនៈ បាទ!

ដានីៈ ក្រពើពីរយើងទៅតាមផ្លូវណា?

ហឿនៈ ទៅក្រពើពីរឡានថៃដឹកឈើឡើងភ្នំទៅត្បូងបានចុះទៅលិចជាប់ព្រំដែន ។

ដានីៈ អីចឹងបានន័យថាហ្នឹងគេហៅផ្ទះមួយៗ?

ហឿនៈ គេហៅអីចឹងតាំងពីនៅសង្គ្រាមណុះ ហៅឈ្មោះអីចឹង ។

ដានីៈ អីចឹងគាត់នៅផ្ទះមួយ?

ហឿនៈ បាទ!

ដានី៖ អីចឹងអ៊ំស្មានមើលប្រហែលប៉ុន្មានគីឡូពីនេះទៅ?

ហឿន៖ ទៅមួយថ្ងៃនោះ ។

ដានី៖ មួយថ្ងៃវាស់ល្ងាច?

ហឿន៖ បាទ! បើគេដើរទៅដល់ គេទៅមើលមីសេមហ្នឹង នៅផ្ទះនេះគេទៅមើលហ្នឹង ។

ដានី៖ គេទៅមើលអីគេ?

ហឿន៖ ទៅមើលជំងឺ កូនគាត់គេធ្វើគ្រូវហើយយកគ្រូពីនេះទៅមើល ឥឡូវគេទៅនៅព្រៃរំចេកបាត់

ដានី៖ គេដើរពីនេះទៅ?

ហឿន៖ បាទ! ដើរ ។

ដានី៖ ដើរមួយថ្ងៃ?

ហឿន៖ ដើរមួយថ្ងៃ ។

ដានី៖ បើយើងជិះឡានមិនមួយថ្ងៃទេ?

ហឿន៖ បាទ! ឡានមួយព្រឹក ។

ដានី៖ អ្នកទៅមើលគាត់ឈ្មោះអី?

ហឿន៖ នៅព្រៃរំចេក ឈ្មោះយាយណោត គ្រូស្រី ។

ដានី៖ យាយណោត គាត់នៅព្រៃរំចេក?

ហឿន៖ ផ្ទះនៅព្រៃរំចេក ។

ដានី៖ ព្រៃរំចេកនៅណាទៅ?

ហឿន៖ អត់ដែលទៅដល់ទេ ដឹងតែនៅព្រៃរំចេកហ្នឹង ។

ដានី៖ ព្រៃរំចេកនៅស្រុកសំឡូតយើងដែរ?

ហឿន៖ ស្រុកសំឡូតទល់ស្ពានដងទង់ ។

ដានី៖ ស្ពាននោះហ្នឹង?

ហឿន៖ ស្ពានដងទង់៩០ម៉ែត្រ អាហ្នឹងព្រំប្រទល់គេត្រឹមហ្នឹង ។

ដានី៖ ហ្នឹងគេហៅភូមិព្រៃរំចេក?

ហឿន៖ ហ្នឹងហើយ ភូមិព្រៃរំចេក ។

ដានី៖ ហើយយាយណោត ហ្នឹងគាត់ធ្វើគ្រូថ្នាំខ្មែរ?

ហឿន៖ ធ្វើគ្រូខាងដោះអំពើហ្នឹង ។

ដានី៖ ហើយគាត់ធ្លាប់ទៅផ្ទះ?

ហឿនៈ ធ្លាប់ទៅប៉ុន្តែគាត់ទៅឆ្ងាយ មិនដឹងគាត់នៅត្រង់ណា ។

ដានីៈ តែផ្ទះគាត់នៅផ្ទះមួយ?

ហឿនៈ ផ្ទះមួយ ។

ដានីៈ យើងទៅតាមភ្នំក្បាលឡាន ហើយ?

ហឿនៈ អត់ទេ! ទៅផ្លូវក្រោម ទៅដល់កំពង់ល្ពៅមានផ្លូវគេធ្វើថ្មីល្អ ទៅកំពង់ល្ពៅ វាលចំបាំងក្រពើពីរហើយទៅសំឡាញ ឡើងកាត់ព្រៃភ្នំទៅ ។

ដានីៈ ទៅផ្ទះមួយហ្នឹង?

ហឿនៈ ដល់មានភូមិទៀត ផ្ទះមួយហ្នឹង ។

ដានីៈ អ៊ំអត់ដឹងថាមីងសេម គាត់មានកូនចៅប៉ុន្មាននាក់ដែរ?

ហឿនៈ អត់ដឹងទេ បែកគ្នារហូត ឃើញតែម៉ែ ឃើញតែឪវា ហើយកូនអត់ឃើញ ។ សួរថាកូនចៅនៅណា នៅផ្ទះ មិនដឹងផ្ទះឯណាទៀត ។

ដានីៈ កាលហ្នឹងអ៊ំស្គាល់ឈ្មោះ កេត ទេ?

ហឿនៈ តាកេត មានតែនៅចំការកៅស៊ូហ្នឹង ។

ដានីៈ ចំការកៅស៊ូ?

ហឿនៈ ហ្នឹង តាកេត ហៅ ផន រត់ចូលព្រៃតែជាមួយគ្នា ។

ដានីៈ តាកេត ហៅ ផន?

ហឿនៈ បាទ!

ដានីៈ តាកេត គាត់នៅចំការកៅស៊ូណាទៅ?

ហឿនៈ នៅចំការកៅស៊ូចំការអណ្តូង ស្រុកស្ទឹងត្រង់ មិនដឹងស្រុកកំណើតគាត់នៅណាទេ ស្គាល់តែក្នុងព្រៃហ្នឹង ។

ដានីៈ តែតាកេត ហ្នឹងគាត់មកពីណាដែរ?

ហឿនៈ មិនដឹងគាត់នៅណាទេ ធ្វើទ័ពហើយគេចាត់តាំងឲ្យទ័ពហ្នឹងធ្វើមេៗគ្រប់កន្លែងទាំងអស់ អត់ដឹង ។

ដានីៈ អ៊ំជួបគាត់ហ្នឹងរត់ចូលព្រៃហើយ?

ហឿនៈ រត់ចូលព្រៃ ។

ដានីៈ ពេលដែលយួនចូលហ្នឹង?

ហឿនៈ ហ្នឹងហើយ ។

ដានីៈ ឥឡូវគាត់នៅណាទៅ?

ហឿនៈ អត់ដឹង បែកខ្ញុំចេញមកនេះមក ហើយគេនៅអន្លង់វែងទាំងអស់គ្នា ដល់ចេញមកគេបែកទៅណាអស់អត់ដឹង។

ដានីៈ កេត ហៅ ផន ប្រពន្ធគាត់ឈ្មោះអីទៅ?

ហឿនៈ អត់ស្គាល់ទៀត ប្រពន្ធគាត់ឃើញតែអត់ស្គាល់ឈ្មោះ អត់ស្គាល់ទេ។

ដានីៈ អីចឹងសេម ហ្នឹងក៏ត្រូវជាប់សាច់ញាតិជាមួយតាម៉ុកដែរ?

ហឿនៈ ហ្នឹងហើយ។

ដានីៈ ចុះសេម ប្រពន្ធស៊ីម សាច់ញាតិត្រូវជាក្មួយតាម៉ុក?

ហឿនៈ ហ្នឹងហើយ។

ដានីៈ ហើយអ៊ីស្គាល់ កាន ដែរ?

ហឿនៈ តាកាន ហ្នឹងរត់ចូលព្រៃជាមួយគ្នាដែរហ្នឹង។

ដានីៈ តាកាន ហ្នឹងគាត់ធ្វើ?

ហឿនៈ ធ្វើចៅហ្វាយស្រុកកងមាស ឬស្រីពាមជីកងទេ ពីរហ្នឹងច្រឡំតែគ្នា តាកាន ស្គាល់ច្បាស់ក្នុងព្រៃ ជួបគ្នាក្នុងព្រៃ មករកដកកាំភ្លើងខ្ញុំ តាជឹម ឲ្យមកដកកាំភ្លើង ខ្ញុំសួរថា អស់យួននៅដែលមកដកកាំភ្លើងហ្នឹង មិត្តឯងបំរើយួន? ខ្ញុំថាអីចឹង ខ្ញុំកាន់កាំភ្លើងការពារយួន ហើយមិត្តឯងមកដកឲ្យខ្ញុំការពារអី ឲ្យតាជឹម មកយកទៅ ខ្ញុំថាអីចឹង។ ហើយតាជឹម អត់មកយក ខ្ញុំកាន់យកទៅ ជួបតាម៉ុក ឲ្យទៅតាម៉ុក។

ដានីៈ កាន គាត់នៅណាដែលឥឡូវ?

ហឿនៈ អត់ដឹង។

ដានីៈ តែជួបគាត់នៅណា?

ហឿនៈ ជួបក្នុងព្រៃ ឡើងភ្នំដងរែកបានជួប។

ដានីៈ ឆ្នាំណាហ្នឹង?

ហឿនៈ ទៅជួបគ្នានៅអូរធំ ជួបគ្នាពេលគាត់មកដកកាំភ្លើង ជួបនៅអូរធំ ច្រក១០០១ ស្គាល់ខ្ទីៗ តិចៗទេ។

ដានីៈ ភឹម ដែលគាត់គណៈស្រុកនៅបាធាយ?

ហឿនៈ ភឹម អត់ស្គាល់ អត់ដែលឮឈ្មោះ។

ដានីៈ ចុះ ម៉ុន គណៈស្រុកជើងព្រៃ?

ហឿនៈ	តាម៉ុន ហ្នឹងចេញពីភូមិត្រពាំងធំមកដែរ តែមិនដឹងស្អីឈ្មោះ ម៉ុន ទេធ្វើចៅហ្វាយស្រុកនៅហ្នឹង ។

ដានីៈ	ចៅហ្វាយស្រុកដើងព្រៃហ្នឹង?

ហឿនៈ	បាទ!

ដានីៈ	ប៉ុន្តែសព្វថ្ងៃគាត់នៅរស់ទេ?

ហឿនៈ	បែបងាប់អស់ហើយ ងាប់ច្រើនណាស់ ។ តាម៉ុន មួយ ហើយតាម៉ន មួយ ។

ដានីៈ	តាម៉ុន មួយ, តាម៉ន មួយ?

ហឿនៈ	តាម៉ន អនុតាម៉ុន ហ្នឹង ។ តាម៉ន នៅភូមិជាមួយខ្ញុំដែរ ។

ដានីៈ	តែគាត់នៅណាដែលឥឡូវ?

ហឿនៈ	តាម៉ន ចូលព្រៃបានតែ២-៣ថ្ងៃស្លាប់បាត់ ។

ដានីៈ	បើតាម៉ុន ហ្នឹង?

ហឿនៈ	តាម៉ុន អត់ដែលជួប ។ តាម៉ន ហ្នឹង ឈ្មោះចេវ ម៉ន ទៀត តាគាត់ឈ្មោះចេវ ។

ដានីៈ	ចេវ ម៉ន?

ហឿនៈ	ចេវ ម៉ន ។

ដានីៈ	ហើយតាម៉ុន, ចេវ ម៉ុន?

ហឿនៈ	អត់ទេ អ្នកដទៃទេ អត់ជាប់សាច់គ្នាទេ គ្រាន់តែធ្វើចៅហ្វាយស្រុកជាមួយគ្នា ខ្ញុំស្គាល់ម៉នហ្នឹង ។ ។

ដានីៈ	យាយយុត ស្គាល់យាយយុតទេ?

ហឿនៈ	ស្គាល់ តែអត់ដឹងនាមត្រកូលឈ្មោះអី ។

ដានីៈ	យាយយុត ហ្នឹងគាត់ធ្វើគណៈស្រុកអីដែរ អត់ទេ?

ហឿនៈ	កាលហ្នឹងនៅកំពង់សៀមជាមួយតាស៊ុ ។ តាស៊ុ គេជាចៅហ្វាយហើយយាយហ្នឹងអនុ ។

ដានីៈ	តាស៊ុ?

ហឿនៈ	តាស៊ុ ហ្នឹងឈ្មោះ ឌិក ស៊ុ ។

ដានីៈ	ឌិក ស៊ុ ហ្នឹងនៅស្រុកកំពង់សៀម?

ហឿនៈ	នៅស្រុកកំពង់សៀមហ្នឹង អាហ្នឹងហើយមេកន្ទ្រាញ ។

ដានីៈ	សព្វថ្ងៃគាត់នៅណា?

ហឿនៈ ខ្ញុំចេញមកបែបនៅអន្លង់វែងទាំងអស់ តែអត់ទៅស្រុកទេ បងគាត់ទៅស្រុក គាស៊ី អត់ទៅ ។

ដានីៈ បងគាត់ឈ្មោះអី?

ហឿនៈ ឌិក អ៊ុ ។

ដានីៈ ឌិក អ៊ុ?

ហឿនៈ ស្លាប់ហើយ គ្រាន់តែទៅដល់ស្រុកគ្រុនចាញ់ហើមងាប់ ។

ដានីៈ ស្រុកណាគាត់?

ហឿនៈ នៅត្រាំកក់ដែរ ។

ដានីៈ តែនៅភូមិអីគេ?

ហឿនៈ ភូមិញ៉ែងញ៉ង ។

ដានីៈ ឃុំញ៉ែញ៉ង?

ហឿនៈ បាទ!

ដានីៈ ភូមិអីគាត់?

ហឿនៈ អត់ដឹងភូមិ ។

ដានីៈ ឌិក អ៊ុ ។ ហើយចុះឌិក ស៊ី ហ្នឹងប្រពន្ធគាត់ឈ្មោះអីទៅ?

ហឿនៈ អត់ស្គាល់ អត់ដែលឃើញ ជួបតែគាស៊ី មកប្រជុំ មកធ្វើការនៅស្រុកហ្នឹង ហើយមកនៅស្រុកគេជួបនឹងស្រុកគេទៀត ប្រពន្ធអត់ស្គាល់ អត់ដែលឃើញ ។

ដានីៈ អត់ដែលឃើញទេ?

ហឿនៈ បាទ!

ដានីៈ ឌិក អ៊ុ, ឌិក ស៊ី ហើយឪពុកគាត់ឈ្មោះឌិក?

ហឿនៈ ឈ្មោះឌិក ។

ដានីៈ ម្តាយ?

ហឿនៈ អត់ស្គាល់ទេ ស្គាល់តែប្រុសៗ ឃើញតែប្រុសៗ ជួបគ្នា ។

ដានីៈ ចុះខាងកំពង់ធំ?

ហឿនៈ អត់ស្គាល់ទេ អត់ដែលទៅដល់ទេ ។

ដានីៈ ចុះដែន អីដែលស្គាល់ទេ?

ហឿនៈ ណា?

ដានីៈ តាដែន?

ហឿនៈ តាដែន ហ្នឹងមុនដំបូងចូលធ្វើចៅហ្វាយខេត្ត ខ្ញុំភ្លេចទៅ តាដែន ហ្នឹង អនុតាសោម ដល់ចេញតាដែន, តាសោម ចេញទៅ បានតាគាវ, តាញ៉ែវ, តាមុត ៣នាក់ហ្នឹង។

ដានីៈ តែតាដែន គាត់ចេញទៅខាងណា ដឹងទេ?

ហឿនៈ អត់ដឹង បែកគ្នាអស់ ខ្ញុំចេញទៅស្រុកគេទៅ ហើយតាដែន គេដកយកទៅដាក់នៅភ្នំជ្រៃអូរញ៉ោ ខូចជាមួយនារីក្នុងជួរហ្នឹង ហើយគេដឹង ខូចអស់១៨នាក់នារី។ នារីហ្នឹងការឲ្យគេទៅ គេប្រាប់ប្តីគេថាខ្ញុំអត់បរិសុទ្ធទេបងអើយ ចៅហ្វាយខេត្តហ្នឹងធ្វើបាបខ្ញុំ រំលោភខ្ញុំអស់គ្នា១៨នាក់ហើយ ប្រាប់គេអីចឹង គេយកទៅដាក់ភ្នំជ្រៃអូរភ្នោឲ្យវ៉ៃចុះ។

ដានីៈ យកតាដែន ហ្នឹង?

ហឿនៈ បាទ! ហើយអ្នកតស៊ូ ហ្នឹងខ្ញុំឲ្យឡានដឹកយកទៅ។

ដានីៈ អ៊ំអ្នកឲ្យយកឡានដឹកតាដែន ហ្នឹងទៅ?

ហឿនៈ បាទ! ដឹកតាដែន ហើយគ្រូបង្រៀនមួយឈ្មោះគ្រូ អុន។

ដានីៈ គាត់ហ្នឹងសុទ្ធតែខូចសីលធម៌?

ហឿនៈ តាអុន ហ្នឹងស្លាប់បាត់ហើយ នៅសល់តែគ្រូ... បងប្អូន។ ដឹកទៅ៦-៧នាក់ តែខ្ញុំភ្លេចឈ្មោះអស់ហើយមួយឡាន យកទៅដាក់ជ្រៃអូរញ៉ោ ភ្លេចអស់ហើយ ឃើញតាដែន ហ្នឹងចៅហ្វាយខេត្តដែរមុនគេហើយជាមួយ តាសោម ចេញពីព្រៃមក។

ដានីៈ តាឈុំ?

ហឿនៈ អត់។

ដានីៈ ដែលឮឈ្មោះ?

ហឿនៈ តាឈុំ អត់។

ដានីៈ ចុះអ៊ំ យាយចែម អ៊ំស្គាល់គាត់ច្បាស់ទេ?

ហឿនៈ ស្គាល់ច្បាស់ តែមិនដឹងនាមត្រកូលគេឈ្មោះអី អត់ដឹង។

ដានីៈ កាលពីគាត់នៅខាងអន្លង់វែង យាយចែម-តាញ៉ែន គាត់មានក្នុងជាគណៈតំបន់អីនៅ?

ហឿនៈ នៅស្រុកអន្លង់វែង ខេត្តមានគេធ្វើចៅហ្វាយខេត្តទៀត។

ដានីៈ យាយចែម ផ្លាស់ពី?

ហឿនៈ ផ្លាស់ពីអន្លង់វែងមកធ្វើចៅហ្វាយខេត្តជាមួយតាទិត បាត់ដំបង់នេះ។

ដានីៈ នៅជាមួយតាទិត បាត់ដំបង?

ហឿនៈ បាទ!

ដានីៈ ដឹងថាគាត់នៅកន្លែងណាដែរ?

ហឿនៈ នៅស្រុកព្រះនេត្រព្រះ តាទិត នៅខេត្ត ។

ដានីៈ ម៉េចបានអ៊ំដឹងថាគាត់នៅព្រះនេត្រព្រះ?

ហឿនៈ ចុះនៅស្រុកជាមួយគ្នា ទៅកំពង់ចាមរៀនសូត្រជួបគ្នាទៀត ។

ដានីៈ គាត់ធ្លាប់ទៅកំពង់ចាមដែរ?

ហឿនៈ កាលហ្នឹងគាត់នៅស្រុកទៅជួបកំពង់ចាម ស្គាល់តាំងពីហ្នឹង ។

ដានីៈ ម៉េចបានគាត់ទៅកំពង់ចាម?

ហឿនៈ កាលនៅស្រុក ដល់ខ្ញុំទៅកំពង់ចាមលែងជួបតាំងពីហ្នឹងមក គាត់នៅបាត់ដំបង លែងជួបហើយ ដល់ចូលព្រៃជួបឃើញទៀត ស្គាល់តាំងពីហ្នឹងមក ។ កាលនៅស្រុកគាត់ទៅធ្វើការនៅក្នុងស្រុកជួបព្រឹក-ល្ងាច ដល់បែកមកនៅអន្លុងវែងលែងជួបគាត់ទៀត ដល់ចូលព្រៃជួបទៀត ។

ដានីៈ កាលទៅកំពង់ចាម?

ហឿនៈ កំពង់ចាម អត់ជួបទេ នៅឆ្ងាយណាស់ ។

ដានីៈ ចុះម៉ិញអ៊ំថាទៅជួបគ្នានៅកំពង់ចាម?

ហឿនៈ ខ្ញុំច្រឡំមាត់ទេ ។

ដានីៈ ជួបកាលនៅក្នុងតាកែវ, ក្នុងព្រៃ?

ហឿនៈ នៅតាកែវជួប ។

ដានីៈ កាលគាត់នៅអន្លុងវែង?

ហឿនៈ ដល់ចូលព្រៃទៅនៅជំរំជាមួយគ្នាទៀត ។

ដានីៈ ចុះតាទិត អ៊ំធ្លាប់ជួបគាត់ទេ?

ហឿនៈ តាទិត នៅភូមិជាមួយគ្នា ឃុំជាមួយគ្នា ជួបតាំងពីនៅលោកសង្ឃ ស្គាល់រហូត ។

ដានីៈ ដល់គាត់ធ្វើការអ្វី? កាលដំបូងគាត់នៅត្រាំកក់ដែរ?

ហឿនៈ នៅត្រាំកក់ ស្គាល់គាត់មិនដឹងធ្វើអ្វីនៅស្រុកណាទេ ដល់ឡើងមកផ្លាស់តាប្រាក់, តាដែន, ផ្លាស់ តាគាវ បានយាយហ្នឹងទៅនៅហ្នឹង ។

ដានីៈ ពីណាយាយណា?

ហឿនៈ យាយបែម ។ នៅហ្នឹងបានប៉ុន្មានថ្ងៃតាម៉ុកឲ្យមកពាយ័ព្យហ្នឹងមកទៀត ។

ដានី៖ ចុះតាទិត?

ហឿន៖ តាទិតនៅផ្ញើចៅហ្វាយខេត្តបានប៉ុន្មានថ្ងៃ។

ដានី៖ នៅផ្ញើចៅហ្វាយខេត្ត?

ហឿន៖ ដល់ផ្លាស់៧៦មកបានឲ្យតាគិត។ អត់ទាន់ទេ ៧៦ តាទិត ចេញមកតាប្រាក់។ តាប្រាក់ចូលទៅបានប៉ុន្មានថ្ងៃគេញើងទៅបាត់ទៀតទៅ បានចូល តាទិត តាទិតចូលទៅ តាទិតចេញមក បាននែ តាគិត តាគិតចេញមក បានមិនដឹងអ្នកណាទៀតខ្ញុំចេញមកក្រៅស្រុកដែរ។

ដានី៖ អីចឹងគាត់នៅរយៈពេលខ្លីៗទេ?

ហឿន៖ ខ្លីៗណាស់ មេគេវល់តែដកនេះដាក់នោះ។

ដានី៖ យាយថែម គាត់នៅមួយរយៈខ្លីដែរ?

ហឿន៖ ខ្លីដែរហ្នឹង។

ដានី៖ យាយថែម ចេញទៅបានគេដាក់តាប្រាក់?

ហឿន៖ តាប្រាក់។

ដានី៖ តាប្រាក់ ចូលទៅគេចាប់ដែរ?

ហឿន៖ ចាប់ទៀត។

ដានី៖ ចាប់យកទៅសម្លាប់អី?

ហឿន៖ សម្លាប់ សម្លាប់ទាំងអស់។

ដានី៖ ឆ្នាំណាដែលអ៊ំចាំទេ?

ហឿន៖ សម្លាប់នៅព្រៃខ្មោចកូនក្មេង ព្រៃស្រម័រ ក្បាលដាក់នៅក្រាំងតាចាន់ហ្នឹង។

ដានី៖ ឆ្នាំណាហ្នឹង?

ហឿន៖ តាប្រាក់ សម្លាប់នៅព្រៃខ្មោចកូនក្មេង យកក្បាលដាក់ក្រាំងតាចាន់ហ្នឹង ជង្រុកក្បាលខ្មោចនៅហ្នឹង។

ដានី៖ ឆ្នាំណាដែលហ្នឹង?

ហឿន៖ សម្លាប់ខ្លាំង៧៦-៧៧-៧៨។

ដានី៖ ដល់ពេលតាប្រាក់ ហ្នឹងទៅបានគេដាក់តាទិត ហ្នឹងចូល?

ហឿន៖ ដាក់តាទិត ចូល។

ដានី៖ តាទិត ហ្នឹងនៅបានយូរទេ?

ហឿនៈ	នៅបាន២-៣ខែហ្នឹងចេញមកបាត់ ដល់តាគិត ចូលទៅអត់បាន១ខែផងគេដកមកទឹកខ្មៅ ២៥មកបាត់ ។

ដានីៈ	ដល់តាគិត ចេញមកអ្នកណាចូលធ្វើជំនួស?

ហឿនៈ	កាលហ្នឹងខ្ញុំចេញដែរអត់ដឹង ចៅហ្វាយខេត្តហ្នឹងអត់ដឹង ។

ដានីៈ	កាលជំនាន់ហ្នឹងឲ្យតែប្រជាជនជាប់ស្រឡាយជាយួនគេសម្លាប់ហើយ?

ហឿនៈ	សម្លាប់ ភូមិចាស់មានតែភូមិអត់មានមនុស្សទេ ។

ដានីៈ	ម៉េចបានគេសម្លាប់យួន?

ហឿនៈ	អាខ្លះមានម៉ាស៊ីនស្រូវមួយគេថាអនុធន គេសម្លាប់ទាំងពូជ ។ អាខ្លះខ្មែរក្រហមអួតប្រកាស ថា អត់មានចោរ តែចោរលួចវិទ្យុគេបាត់ គេថាឲ្យតាចាយ អីចឹង តាចាយដើរទៅធ្វើការ ក្នុងភូមិ ស្រាប់តែឃើញវិទ្យុអាកូនយាយហ្នឹងប្រពន្ធ ឃើញវិទ្យុហ្នឹងសួរថា ឯងបានវិទ្យុមក ពីណា ទិញពីណា? របស់ម៉ែ ម៉ែឯងថាបាត់ ហើយឯងយករបស់ម៉ែឯងមក ម៉ែឯងថា ខ្មែរក្រហមអួតថាអត់មានចោរ ចោរលួចវិទ្យុបាត់ ឥឡូវឯងចោរ ចាប់ទាំងម៉ែ ចាប់ទាំងឪ បងប្អូនវា២នាក់ សម្លាប់ទាំង៤នាក់ ។

ដានីៈ	ពីណាគេបាត់?

ហឿនៈ	ទៅប្ដឹងតាចាយ តាចាយថាចោទខ្មែរក្រហម ធ្វើបាបអញ អីចឹងអញយកឯងទាំងអស់ ទាំងសំបុក ។ យាយដូ, តាសី ២នាក់ប្ដីប្រពន្ធ ហើយអាគ្រាំ២នាក់ប្ដីប្រពន្ធ ហើយអាបាន ២នាក់ប្ដីប្រពន្ធ គេយកទៅទាំងសំបុក ។

ដានីៈ	មួយសំបុកតែម្ដង?

ហឿនៈ	វា៦នាក់ ។

ដានីៈ	ពីណាគេបាត់វិទ្យុ?

ហឿនៈ	យាយដូ, តាសី ហ្នឹង ។

ដានីៈ	បាត់វិទ្យុទៅប្ដឹងតាចាយ?

ហឿនៈ	ហ្នឹងហើយ អត់បាត់ទេ យកផ្ញើរកូនថាចោរលួច ដល់តាចាយ ដើរធ្វើការឃើញកូនមាន វិទ្យុសួរថាឯងទិញឯណា អ៊ឺ! របស់ម៉ែ វាថារបស់ម៉ែ ។ ម៉ែឯងចោទអញថាខ្មែរក្រហម អត់មានចោរ ឥឡូវចោរលួច ឯងហ្នឹងហើយចោរ ដល់ថាអីចឹងគ្នា៣នាក់វាមាន៦នាក់ ។

ដានីៈ	មួយសំបុកហ្នឹង?

ហឿនៈ មួយសំបុកហ្នឹង ៣គ្រួសារ ទាំងម៉ែ ទាំងឪ ទាំងកូនតូច កូនធំ កូនគាត់តែ២នាក់អ្នកមាន មានណាស់ ដល់យកបាត់ទៅ ។

ដានីៈ ឆ្នាំណា?

ហឿនៈ សម្លាប់ព្រៃខ្មោចកូនក្មេងហ្នឹងទាំងអស់ ។

ដានីៈ នៅព្រៃខ្មោចកូនក្មេងតែយកទៅសម្លាប់ឆ្នាំណា?

ហឿនៈ ឆ្នាំ៧៥ គេដើរចាត់តាំងរដ្ឋអំណាច គេដើរទៅឃើញ ។

ដានីៈ តាចាយ គាត់នៅរស់ទេ សព្វថ្ងៃ?

ហឿនៈ ស្លាប់អស់ហើយ ស្លាប់តាំងពី៨៩ ចេញមកពីអូរត្រាវមកស្លាប់នៅកំពង់ល្ពៅ ។

ដានីៈ កំពង់ល្ពៅនៅណាទៅ?

ហឿនៈ នៅជិតនេះ រំលងស្ពានដល់ហើយ ។

ដានីៈ អ៊ីចឹងបើយើងទៅផ្ទះមួយទៅតាមកំពង់ល្ពៅ?

ហឿនៈ ទៅកំពង់ល្ពៅមានផ្លូវគេទៅថ្លុងទៅកើតចេះ ។

ដានីៈ ទៅកើតគេហៅអីគេ?

ហឿនៈ ទៅកើតគេហៅស្ទឹងតូច ទៅដល់វាលចំបាំង ចេញពីវាលចំបាំងទៅដល់ក្រពើពីរ ដល់ក្រពើ ពី-សំឡាញ សំឡាញហើយឡើងភ្នំទៅត្បូងលែងដឹងហើយ ផ្លូវឡាន ។

ដានីៈ តែបើយើងទៅដល់កន្លែងអ្នកស្រុក អ្នកភូមិគេដឹង?

ហឿនៈ សួរដឹងទាំងអស់ ផ្ទះមួយណា ស្គាល់មីសេម១ ស្គាល់ទាំងអស់ ។ សួរតែមីសេម-មីស៊ីម ហ្នឹង ។

ដានីៈ បាទ!

ហឿនៈ ស្គាល់ទាំងអស់ ។

ដានីៈ ខ្ញុំអរគុណអ៊ំច្រើនដែលផ្តល់បទសម្ភាសន៍ជាមួយខ្ញុំនេះ ព័ត៍មានអ៊ំសំខាន់ ល្អច្រើនណាអ៊ំ បើថ្ងៃពេលដែលខ្ញុំស្តាប់ ខ្ញុំចង់សរសេរអ៊ី សួរនាំអ៊ំទៀត អ៊ំអត់មានប្រកាន់អីទេ?

ហឿនៈ អត់ទេ ។

ដានីៈ ខ្ញុំអរគុណអ៊ំ ។

ហឿនៈ អរគុណ ។

ចប់

សម្ភាសន៍លើកៈ ទី២

អ៊ុល ហឿន ភេទប្រុស អាយុ៧៥ឆ្នាំ

ស្រុកកំណើតនៅភូមិត្រពាំងប្រីយ៍ ឃុំត្រពាំងធំខាងត្បូង ស្រុកត្រាំកក់ ខេត្តតាកែវ

សព្វថ្ងៃរស់នៅតាសាញដើង ឃុំតាសាញ ស្រុកសំឡូត ខេត្តបាត់ដំបង

មុខងារសម័យខ្មែរក្រហមៈ «សមាជិកស្រុកត្រាំកក់»

ថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៣

សម្ភាសន៍ដោយៈ ឡុង ដានី

០១:៥៨:២១

៦៨ ទំព័រ

ដានីៈ បាទ! អ៊ីខ្ញុំចង់សួរបន្ថែមតិចទាក់ទងពីតាមុតណា៎ ដែលអ៊ីថាចង់! ល្ងាចមិញវាយប់ជ្រៅហើយ វាងយប់ហើយក៏អត់បានសួរបន្ថែម ចឹងចង់សួរអ៊ីបន្ថែមលើកទី២ ។ អ៊ីកាលពីតាមុត អ៊ីមានប្រសាសន៍ថា កាលពីថ្ងៃ២០ដាងខែប៉ុន្មានគាត់?

ហឿនៈ ថ្ងៃ២១ ខែ៨ តាម៉ុកចាត់តាំងឲ្យនាំកំលាំងទ័ពហ្នឹងទៅនៅខេត្តកោះកុង កំពង់សោមទៅនៅថ្ងៃ២១ ខែ៨ ខ្ញុំនៅចាំអត់ភ្លេចទេ ។

ដានីៈ ២១ ខែ៨ តាម៉ុកអ្នកចាត់តាំងទៅ?

ហឿនៈ តាម៉ុកអ្នកចាត់តាំងទៅឲ្យនាំកំលាំងតាមុតទាំងអស់ទៅគ្រប់គ្រងចៅហ្វាយខេត្តនៅខេត្តកោះកុង ។

ដានីៈ កោះកុង ឬក៏កំពង់សោម?

ហឿនៈ កំពង់សោមហ្នឹង កោះកុង, កោះកុង និងកំពង់សោមហ្នឹងតែមួយ ពីហ្នឹងទៅគេហៅប្រកកោះកុងដែរ ពីប៉ៃលិនទៅហ្នឹង តាមុតនៅឈរនៅហ្នឹង គេហៅថាគណៈប្រកកោះកុង ។

ដានីៈ បាទ! ប៉ុន្តែគណៈប្រកកោះកុង ប៉ុន្តែខ្ញុំចង់ដឹងថាថ្ងៃ២១ ខែ៨ឆ្នាំ៧៥ គាត់នៅខាងកំពង់សោម កោះកុង?

ហឿនៈ ថ្ងៃ២១ ខែ៨ ៧៥ហ្នឹង គាត់នៅជាចៅហ្វាយខេត្ត ខេត្តតាកែវ ។ តាម៉ុកចាត់តាំងពីតាកែវឲ្យនាំកំលាំងឲ្យទៅនៅឈរជើងនៅខេត្តកោះកុងកំពង់សោមនេះ ។

ដានីៈ គាត់ធ្វើអីកាលហ្នឹងនេះ?

ហឿនៈ ធ្វើចៅហ្វាយខេត្តដដែល នៅតាកែវគាត់នៅមេទ័ពខាងខេត្តហ្នឹង ។ តាមុំកចប់សង្គ្រាមចប់ភ្លាមថ្ងៃ ទី២១ចាត់តាំងឲ្យនាំកំលាំងទៅ ។

ដានីៈ អីចឹងគាត់ពុំមែននៅខាងកងពលទេ?

ហឿនៈ កងពលធំ!

ដានីៈ កងពលខាងអីគេកាលហ្នឹង?

ហឿនៈ ខាងទ័ព! តាមុតហ្នឹងនៅខេត្តតាកែវកងពលធំហ្នឹងហើយ ។

ដានីៈ ទៅខាងកោះកុង ខាងកំពង់សោមហ្នឹងក៏កងពលដែរ?

ហឿនៈ កងពល! ចៅហ្វាយខេត្តហើយ ឡើងចៅហ្វាយខេត្តហើយ គាត់នៅក្តាប់ទ័ពហើយ ទាំងជើងទឹក ទាំងជើងគោកទាំងអស់ ។

ដានីៈ ទាំងជើងទឹក ទាំងជើងគោកទាំងអស់?

ហឿនៈ បាទ! នៅលើមុតហ្នឹង ។

ដានីៈ ហើយអ៊ីចឹងកាលហ្នឹងកូនអ៊ំឃើញគេសម្លាប់ វាយ៉ាងម៉េចខ្លះទៅអ៊ំ?

ហឿនៈ ទៅដល់ទាហាន ប្រជាជននៅពេញប្រទេស អត់ទាន់មានដាក់កាំភ្លើង ដាក់អាវុធអីទេនៅស្ពាយគ្រប់គ្នាទាំងអស់ ដល់គេយកឡានគេចងមេក្រូដើរប្រកាសថា ឲ្យកងទ័ពសាធារណៈអីគេនោះ យកកាំភ្លើងទៅគរមួយកន្លែងហើយរៀនអីវ៉ាន់ ផ្ទះនៅឯណាគេដឹងទៅហ្នឹងតាមផ្ទះបងប្អូន គេដឹកទៅ ។ ដល់គេរៀបកាំភ្លើងប្រមូលយកទៅគរមួយកន្លែងហើយអីវ៉ាន់គរហើយ គេថាឡើងឡានមក ។ ឡើងឡានមកមិនយកទៅដល់ស្រុកដល់ភូមិ យកទៅព្រៃ ។

ដានីៈ ព្រៃណា?

ហឿនៈ ព្រៃចំការកៅស៊ូ, មិនចំការកៅស៊ូទេ ចំការដំណាំហូបផ្លែ ឈើហូបផ្លែ ។ ទៅដល់ដាក់ប្រវ៉ាក់ជើងឲ្យកាប់រណ្តៅ កាប់រណ្តៅគ្នា១០នាក់ ២០នាក់កាប់រណ្តៅជុំវិញដើមឈើហ្នឹងហើយកប់ ។ បើកាប់បានរណ្តៅគេបាញ់សម្លាប់កប់ហ្នឹង កប់ចឹងទាំងអស់ហើយវាមិនអស់មនុស្ស ។ កប់ចម្ការក្រូច ចម្ការ ធុរេន ចម្ការស្វាយ ចម្ការដូង ដល់ធ្លាក់ភ្លៀងម្តងផាប់ផាប់ មនុស្សអត់ទាន់អស់ ។

ដានីៈ ធ្លាក់ភ្លៀងម្តងផាប់ម៉េច ធ្លាក់ភ្លៀងម្តងធី?

ហឿនៈ ដើមឈើហ្នឹង ឡើងពណ៌ស្វាយទាំងអស់ ហើយពីពណ៌ស្វាយរង្គោះស្លឹកផាប់ ផាប់ទាំងអស់ ។

ដានី៖ ហេតុអីបានស្លាប់?

ហឿន៖ ស្វាញប្តុសបើកប់ដុំវិញដើម វាដាច់ប្តុស ដាច់អីទៅវាប្រែ វាស្លាប់ ស្លាប់ធ្លាក់ស្លឹកស្លាប់ទាំងអស់គ្រប់រណ្តៅ។

ដានី៖ អាកន្លែងគេកប់មនុស្សស្លាប់ទាំងអស់។

ហឿន៖ ស្លាប់ទាំងអស់ កប់ប៉ុន្មានដើម ស្លាប់រាប់រយហិចតាទៅណា មនុស្សច្រើនណាស់ ខេត្តហ្នឹង មនុស្សពេញបន្ទាយទាំងអស់។

ដានី៖ ច្រើនចឹង? សម្លាប់ហ្នឹងច្រើន?

ហឿន៖ ច្រើនរាប់ពាន់ រាប់ម៉ឺន សុទ្ធតែទាហាន ប្រជាជននៅក្នុងហ្នឹង សម្លាប់ទាំងអស់។

ដានី៖ ហើយកាលហ្នឹង អ៊ំអត់បានឃើញទេ?

ហឿន៖ ខ្ញុំអត់បានឃើញទេ កូនខ្ញុំឃើញចឹង វារត់មកប្រាប់។

ដានី៖ រត់ពីកំពង់សោមមក កូនអ៊ំនៅជាមួយ?

ហឿន៖ នៅជាមួយតាមុតហ្នឹង។

ដានី៖ កងទ័ពជើងទឹក ជាមួយតាមុត?

ហឿន៖ អត់ជើងទឹកទេ វានៅជើងគោកដែរ។

ដានី៖ គាត់នៅកងអីដែរអ៊ំ?

ហឿន៖ កាលហ្នឹងនៅកងការពារតាមុតហ្នឹងផ្ទាល់តែម្តង។

ដានី៖ កងការពារតាមុត កូនអ៊ំឈ្មោះបារាំង?

ហឿន៖ ខ្ញុំហៅវាតែអាបារាំង ឯក បារាំង។

ដានី៖ ឯក បារាំង ប៉ុន្តែក្នុងសម័យហ្នុងគេហៅចឹងដែរ?

ហឿន៖ គេហៅដូចគ្នា។

ដានី៖ ហៅបារាំងៗចឹង?

ហឿន៖ បាទ! ហៅតែ អាបារាំង។

ដានី៖ រត់ទៅប្រាប់អ៊ំនៅឆ្នាំណាដែរទៅ?

ហឿន៖ វាមក៧៥ វាទៅដល់បាន២,៣ខែវាឃើញដាក់ស្តែង វាភ័យវាខ្លាច វារត់មកប្រាប់។ ខ្ញុំថាហ្អែងកុំមាត់ប្រយ័ត្នគេដឹង គេចាប់ហ្អែងទៀតណា ទ្រាំខាំមាត់ខាំក កុំមាត់កុំនិយាយអីកូន កុំឲ្យគេដឹង ហើយឲ្យវាទៅវិញទៅ ទៅវិញ ៧៦មកទៀត។

ដានី៖ មកទៀតហើយនិយាយថាម៉េចទៅ?

ហឿនៈ និយាយដូចគ្នាចឹង ថាឪអើយខ្ញុំភ័យខ្ញុំចង់រត់មកផ្ទះ ថាអត់បានទេ តែរត់មកគេតាមមកចាប់ទាំងហ្វូងទាំងអញទៀត កុំមកកូននៅហ្នឹងហើយ ។ រហូតដល់វាថាធ្វើបាបគេ កាប់សម្លាប់គេទាំងអស់ អត់មានរួចមួយ អត់មានទៅណាទេ ថាយកទៅស្រុកយកទៅភូមិគេឲ្យឡើងឡានជិះ មិនជិះទៅតាមផ្លូវ ជិះទៅចូលព្រៃចម្ការអណ្តូង ចម្ការដូង ចម្ការស្វាយ ចម្ការធូរេន ចម្ការអីទាំងអស់ ។ យកទៅដល់ដាក់ច្រវ៉ាក់ទាំងអស់ ដាក់ជាប់គល់ឲ្យកាប់រណ្តៅ កាប់រណ្តៅហើយ ល្ងមបានគេដាក់ទម្លាក់ហ្នឹង ។

ដានីៈ ពីណាគេដឹកនាំទៅ អ្នកដឹកនាំទេសម្លាប់?

ហឿនៈ អ្នកដឹកនាំ អត់បានសួរបញ្ជាក់វាទេ ព្រោះក្នុងហ្នឹង ខ្វះអីអ្នកដឹកនាំ មាននាំបើកឡានទៅ ។

ដានីៈ បាទ! ប៉ុន្តែអ៊ំថាតាមុត គាត់ធ្វើប្រធាន ហីអ្នក!

ហឿនៈ ហ្នឹងហើយ មេធំហើយ!

ដានីៈ បន្ទាប់ពីតាមុតមក?

ហឿនៈ បន្ទាប់ពីតាមុត មានតាញ៉ាន់ អ្នកមេចាត់ចែងខាងសម្លាប់ហ្នឹងហើយ ។

ដានីៈ តាញ៉ាន់ហ្នឹងអ្នកចាត់ចែងខាងសម្លាប់?

ហឿនៈ បាទ!

ដានីៈ កាលហ្នឹង កូនអ៊ំនិយាយប្រាប់ ឬក៏អ៊ំដឹងថា?

ហឿនៈ វាមកនិយាយប្រាប់ ហីអ្នកជិតខាងក៏និយាយដូចគ្នា មិនតែកោះកុង កំពង់សោម តាកែវក៏ដូចគ្នាដែរ ធ្វើចឹង! សម្លាប់រណ្តៅអាបេដែលវាទម្លាក់រាប់ឆ្នាំ ទម្លាក់កប់ពេញៗកំពុងៗហើយអាតូចៗអត់ដែលកប់ទេ វាបោះទៅមុនគេ វាយអាធំៗក្រោយ គេមិនវាយទៀតគេធ្វើដង ធ្វើពីចំពាមនេះមួយៗទៅ ដាក់ឈើទទឹងហើយចងលួសប្រាំង ចងដូចខ្សែនោះអីចឹង ហីគេចងកូនតឹងសម្រាប់ទាញអីចេះ យកទៅដល់ គេជ្រាទៅក្រោយអីចេះហើយគេងើយកអីចេះ គេរឹតខ្សែប្រាំងម៉ូតូហ្នឹង តែមួយស្នាប់ទេ តែ៥នាទីមួយៗទម្លាក់ហើយ ។

ដានីៈ ទម្លាក់នៅណាហ្នឹង?

ហឿនៈ នៅជុំវិញតាកែវ អន្លក់តាសោមក៏ធ្វើដូចគ្នា តែអីចឹង ។

ដានីៈ ឆ្នាំណាអាហ្នឹង?

ហឿនៈ រំដោះអន្លក់តាសោម ដូចជា៧៨ហ្នឹងហើយ រំដោះបានហើយចេះតែវាយរុលរហូតដល់ភ្នំពេញ ។

ដានី៖ ចុះតាំងពី៧៤មក ដែលមានសម្លាប់ទេ?

ហឿន៖ សម្លាប់តាំពី៧០មក ៗ ៧០ គាមុតមេទ័ពវាយបែកបន្ទាយណា បញ្ជូនមកទាំងខ្មែរៗ យកឲ្យប្រពន្ធគាត់ នគរបាលខេត្ត ហើយលេខាស្រុក ។

ដានី៖ យកឲ្យប្រពន្ធគាត់ពីណាគេ?

ហឿន៖ ព្រៀក ខុម ហ្នឹង!

ដានី៖ ព្រៀក ខុម ហ្នឹង កាលហ្នឹងប្រពន្ធគាត់ធ្វើអីគេ?

ហឿន៖ ប្រពន្ធគាត់ចៅហ្វាយស្រុកផង ចៅហ្វាយខេត្តផង មេនគរបាលធំខេត្ត ។

ដានី៖ មេនគរបាលធំខេត្ត ពីណាគេ ខុម ហ្នឹងដែរ?

ហឿន៖ យាយ ខុម ហ្នឹងហើយ មានតាដឹម ហ្នឹង ពីរនាក់ហ្នឹងដល់កដូចគ្នា មេឃាតករតែថ្មើរហ្នឹងគេដើរចាប់ ចាប់សម្លាប់ ។

ដានី៖ កាលជំនាន់ហ្នឹង តាដឹម ក៏នៅក្នុងហ្នឹងដែរ?

ហឿន៖ គណៈស្រុក! អនុ យាយខុម ហ្នឹង ។ សម្លាប់នោះសម្លាប់ អត់មានសល់ទេ ។

ដានី៖ ចឹង! នៅកំពង់សោមកោះកុងហ្នឹង កូនអ៊ំនិយាយថាគេយក ដូចថាទាហានសាធារណៈរដ្ឋខ្មែរ ប្រជាជនដែលរស់នៅក្នុងទីក្រុងហ្នឹង យកមកនៅកន្លែងចម្ការ...?

ហឿន៖ ចម្ការដំណាំឈើហូបផ្លែ ។

ដានី៖ ហើយគេដាក់ច្រវ៉ាក់ ហើយគេឲ្យកាប់រណ្ដៅ ហើយគេវាយ?

ហឿន៖ កាប់ ដាក់ជើងគ្រប់ទាំងអស់ហើយឲ្យកាប់រណ្ដៅ ។

ដានី៖ គេវាយ គេយកអីវាយទៅ?

ហឿន៖ គេវាយបាញ់សម្លាប់ ចំពុះទង់ចាក់សម្លាប់ទៅ សុទ្ធតែធ្វើចឹងដូចគ្នា តាកែវក៏ធ្វើអីចឹងតាមខ្ញុំដឹង ។

ដានី៖ ហើយតាកែវអ៊ំឃើញថាគេ!

ហឿន៖ គេចងឈើទទឹងហើយខ្មែរទម្លាក់ហើយ គេចងកូនគីងមួយទទឹងប្រវែងហ្នឹងហើយសម្រាប់ទាញចេះ ។

ដានី៖ ពីណាគេអ្នកទាញហ្នឹង កាលហ្នឹងអ៊ំ?

ហឿន៖ ហ៊ឺអត់ដឹងទេ កងទ័ពគេធ្វើ គ្រាន់តែឮគេនិយាយអីចឹង ។

ដានី៖ ទាញហ្នឹង ទាញនៅកន្លែងព្រៃ?

ហឿន៖ ព្រៃឲ្យតែមានរណ្ដៅអាចេពេញៗទាំងអស់ ។

ដានី៖ ចឹង?

ហឿន៖ បាទ!

ដានី៖ ចុះតាមុតក្រៅពីអ៊ីចឹង ដែលកូនអ៊ីប្រាប់ហ្នឹង មានដឹងអីផ្សេងទៀតទាក់ទងហ្នឹងរឿង មាស មុត ហ្នឹង?

ហឿន៖ កាលឆ្នាំ៧០ ចូលមកដល់រៀបចំចាត់តាំង រដ្ឋអំណាចខ្មែរក្រហមហ្នឹងហើយ គេដើរចាប់ហើយ ។

ដានី៖ គេដើរចាប់អ្នកណា?

ហឿន៖ ចាប់ដូចថាជំទប់ មេឃុំ មេភូមិហ្នឹង ទាហាន ប៉ូលីស គ្រូបង្រៀន ថាសុទ្ធតែអនុធនថ្នាក់ អ្នកមានមាស៊ីនស្រូវ គេចាប់ហើយអត់មានលែងអត់មានអី ចាប់នាំយកទៅព្រៃយកសម្លាប់តែម្តង ។ ចាប់ៗទាល់តែភូមិមួយៗស្ងាត់សូន្យអត់មានមនុស្ស ហើយឪពុកម្តាយដូចថាទាហានទ័ព លន់ នល់ ហ្នុង ឪពុកម្តាយហ្នឹងក៏គេយកទៀត ។ ចឹងណាបានថាស្ងាត់ភូមិទាំងអស់ហើយយប់ឡើងត្រជាក់ខ្លួនអស់ហើយ មិនដឹងជាថ្ងៃណាគេចាប់ដែរ ភ័យដូចគ្នា ហ្នឹងរឿងតាមុតហ្នឹង ។ តាំងពីចេញពីព្រៃមកតាំងមន្ទីរនៅត្រពាំងក្រោមជិតស្រែខ្ញុំហ្នឹង ភ្នែកមើលឃើញទាំងស្រស់ ហីគេរើសក្បាល គេរើសតែមួយកន្លែងក្បែរក្រាំងតាចាន់ហ្នឹង យកទៅដាក់នៅជង្រុក ទទឹង!

ដានី៖ ប៉ុន្តែតាមុត គាត់កាលនៅតាកែវពីឆ្នាំ៧០ គាត់ចាប់ជំទប់, មេឃុំ, គ្រូបង្រៀន អនុធនអីហ្នឹង កាលហ្នឹងអ៊ីបានឃើញផ្ទាល់ភ្នែកដែរអត់?

ហឿន៖ ចាប់បណ្តើរចូរផ្ទះខ្ញុំយកមកចង ចងបណ្តើរទាំងខ្សែៗហ្នឹង ។

ដានី៖ អាហ្នឹងអ៊ីឃើញតែម្តង?

ហឿន៖ ឃើញហ្នឹងភ្នែកតែម្តង ។

ដានី៖ អាហ្នឹងឆ្នាំ៧០មក?

ហឿន៖ ៧០ចាប់មួយបន្តតាំងពីរដ្ឋអំណាច តាំងពីជំនាន់ ប្រធានភូមិប្រធានឃុំ ពីជំនាន់សង្គមរាស្ត្រនិយម ជំនាន់សម្តេចឪរហូតមកដល់សាធារណៈ គេចាប់ពួកអស់ហ្នឹងហើយ គ្រូបង្រៀនក៏ជំនាន់សង្គមរាស្ត្រនិយមហ្នឹងដែរ ចាប់ទាំងអស់ គេថាអនុធន ។

ដានី៖ ចុះអ៊ីហីតាមុត ស្គាល់គ្នាច្បាស់ដែរ?

ហឿន៖ ខ្ញុំស្គាល់ច្បាស់ តែគេអត់សូវស្គាល់ខ្ញុំទេ ទើបមកស្គាល់ច្បាស់ ខ្ញុំមកនៅហ្នឹង ប៉ុន្តែគាត់ដើរចូលផ្ទះខ្ញុំ ផ្លូវចេញពីព្រៃមន្ទីរគាត់ មកចូលផ្ទះខ្ញុំ... ។

ដានី៖ តាមុតស្រុកកំណើតគាត់នៅឯណា?

ហឿន៖ បាទ?

ដានី៖ មាស មុត ហ្នឹង ស្រុកំណើតគាត់នៅឯណា?

ហឿន៖ ស្រុកឈូក ខេត្តកំពត ប៉ុនដឹងស្អីទេ! ស្រុកឈូកនៅក្បែរជើងវត្តអីគេហៅព្រៃទទឹង មែនទេខ្ញុំភ្លេច! មិនដឹងជាភូមិអីឃុំអីទេ ដឹងតែស្រុកឈូក ។

ដានី៖ ហើយដល់ពេល បើគាត់ផ្លាស់មកខាងកំពង់សោមខាងកោះកុងហ្នឹង ក្រៅពីកូនអ៊ំនិយាយប្រាប់មានរឿងអី ដែលអ៊ំដឹងក្រៅពីហ្នឹងទៀតដែរអត់?

ហឿន៖ អ៊ំដឹងតែរឿងគេធ្វើបាប ប៉ូលីស ទាហាននៅក្នុងបន្ទាយ ទាំងប្រជាជនអីទាំងអស់ ដឹងតែប៉ុណ្ណឹងទេ ។

ដានី៖ ចុះអ៊ំខ្ញុំចង់បន្ថែមទាក់ទងអំពីកូនតាម៉ុក ហើយនិងកូនប្រសារតាម៉ុកណា?

ហឿន៖ បាទ!

ដានី៖ មាស មុត ប្រពន្ធគាត់?

ហឿន៖ ព្រៀក ខុម ។

ដានី៖ ព្រៀក ខុមហ្នឹង កូនបង ស្រី! ។ បាទ! ហើយកូនទី២របស់តាម៉ុក?

ហឿន៖ ឈ្មោះ យាយហូ ។

ដានី៖ យាយហូ?

ហឿន៖ ព្រៀក ហូ ដែរ ។

ដានី៖ ចុះប្ដីគាត់ឈ្មោះអី?

ហឿន៖ ឈ្មោះ តាវិន តាម៉ុកសម្លាប់, តាវិន កងពលធំ ។

ដានី៖ តាវិន?

ហឿន៖ ឈ្មោះវិន ។

ដានី៖ អីវិនដែរអ៊ំដឹងទេ?

ហឿន៖ អត់ដឹងទេ!

ដានី៖ អ្នកស្រុកណាតាវិន ហ្នឹង?

ហឿន៖ តាម៉ុកអ្នកសម្លាប់ យកតាំភ្លើង យកអីលក់ឲ្យថៃ ទិញអង្ករទិញស្បៀងមកឲ្យទ័ពហូប ហើយដល់ហើយតាម៉ុកខឹង យកស្រីយកអីទៅលក់ឲ្យថៃ ។

ដានី៖ យកអី យកស្រី?

ហឿនៈ	មនុស្សស្រីដែលរត់តាមគាត់ហ្នឹង បានអីចិញ្ចឹមទ័ព ទ័ពគាត់ចូលព្រៃស្ទឹកឈើរង្គោះទាំងអស់ សុទ្ធតែទ័ពបានអី ចឹងគាត់យកកាំភ្លើងគាត់ យកនារីៗទៅលក់យកលុយទិញអង្ករឲ្យទ័ព ដល់តាម៉ុកដឹង តាម៉ុកសម្លាប់ ។

ដានីៈ	នៅឆ្នាំណាហ្នឹង?

ហឿនៈ	អាហ្នឹងឆ្នាំ៧៥,៧៦ ហ៉េ៩០,៩១ឡើងភ្នំដងរែក អត់មានទាន់បារាំងទទួលស្គាល់ ផ្តល់ស្បៀង ផ្តល់អី គេម្ចាស់ការ ។

ដានីៈ	៧៩អី ឬក៏យ៉ាងម៉េច? ព្រោះ៧៩ យើងបែកយួនចូល ។

ហឿនៈ	ខ្ទង់៩១, ៩២ ហ្នឹង ជិតនេះហើយហ្នឹង ។

ដានីៈ	ជិតអ៊ុនតាក់ជិតចូលហើយមកហ្នឹង?

ហឿនៈ	ជិតចូលហើយ តែវាអត់បានចូល បានជាគាត់យកមនុស្សទៅដូរយកអង្ករយកស្បៀងមកចិញ្ចឹមទ័ព ។

ដានីៈ	បាទ! ចុះឈ្មោះវិនហ្នឹង កាលពីសម័យពីឆ្នាំ៧០,៧៥,ចិតអីហ្នឹងគាត់នៅណាទៅ?

ហឿនៈ	គាត់នៅឯណាទេ អត់ដឹង!

ដានីៈ	អត់ដែលស្គាល់គាត់ទេ?

ហឿនៈ	អត់ដែរស្គាល់គាត់ទេ ដល់ឡើងព្រៃបានឃើញពួកខ្ញុំដើរ ថាអេ៎! ពួកឯងទៅឯណា ខ្ញុំថាដើររកអង្គការ អង្គរក៏រកដែរ បាត់អង្គការ ចឹងឯងមកតាមអញ ហើយឯងនៅអង្គភាពណា ខ្ញុំថានៅកម្មករកៅស៊ូជប់ គាត់ថាអើមកតាមគាត់មក ហើយខ្ញុំអត់មកតាម គាត់នៅជិតៗគ្នាហ្នឹង ។

ដានីៈ	បាទៗ! ហើយចឹងតាវិនហ្នឹង កាលពីនៅត្រាំកក់ហ្នឹង អឹមអត់ដែរស្គាល់គាត់ទេ?

ហឿនៈ	អត់ដែរ ឮឈ្មោះ!

ដានីៈ	ប៉ុន្តែគាត់បានកូនតាម៉ុកតាំងពីកាល? កូនឈ្មោះ ព្រៀក ហូ?

ហឿនៈ	កូនហ្នឹងក៏អត់ដឹង ស្រាប់តែឃើញយាយហូហ្នឹងហើយក៏មួយឈ្មោះ អាបឿ កូនប្រុសហើយវាមកដេរមីកាច្រិចនេះថា ឪផែញហើយ ដែលសម្លាប់ឪអញ អញអត់សុខចិត្តទេ អញនៅសងឈាមទាល់តែបាន ។

ដានីៈ	ឪផែញណា?

ហឿនៈ	អាចៅ! ឈ្មោះ អាបឿ ។

ដានីៈ	គាត់ថាឲ្យតាម៉ុក?

ហឿន៖ ខឹងៗ សម្លាប់ឪវា ។

ដានី៖ បឿហ្នឹង! នៅឯណាឥឡូវ, នៅណាបឿហ្នឹង?

ហឿន៖ ឥឡូវទៅនៅឯព្រៃរំចេក អាបត់ផ្លូវទៅចេះ នៅពីខាងលិចផ្លូវ ។

ដានី៖ មកដេថ្មីៗនឹង?

ហឿន៖ បាទ?

ដានី៖ មកដេរពីអន្លុង់?

ហឿន៖ មកដេរផ្ទះវានៅនេះ ឈ្លោះគ្នាហ្នឹង ។

ដានី៖ ពីអន្លុង់? យូរនៅ?

ហឿន៖ អាហ្នឹងឆ្នាំ២០០០ហើយនឹង ។

ដានី៖ ហ៊ូ! ឆ្នាំ២០០០ហើយ, ប៉ុន្តែតាម៉ុកនៅមិនទាន់ស្លាប់ទេ?

ហឿន៖ នៅអត់ទាន់ស្លាប់ទេ ។

ដានី៖ គាត់ថាតាម៉ុក អ្នកសម្លាប់ឪគាត់?

ហឿន៖ វាដឹង! គេនិយាយគ្រប់មាត់ ។

ដានី៖ ហើយហូ នឹងកូនទី២ ទី៣?

ហឿន៖ ទី៣យាយហូ ហើយមីកាហ៊ាញ ។

ដានី៖ កាហ៊ាញ?

ហឿន៖ កាហាញ ហើយបានឈ្មោះ អាគ្រូហ្នឹងឆែបមាត់ ។

ដានី៖ បាទ! ទី៣នឹងឈ្មោះ ហ៊ាញ?

ហឿន៖ ហ៊ាញ ។

ដានី៖ ព្រៀក ហ៊ាញ ដែរ?

ហឿន៖ ហ្នឹងហើយ! សុទ្ធតែព្រៀកហើយ កូនតាម៉ុក ។

ដានី៖ ព្រៀក ហ៊ាញ ហ្នឹង ប្តីគាត់ឈ្មោះអី?

ហឿន៖ ឈ្មោះ បូរាណ ។

ដានី៖ ឈ្មោះ បូរាណហេ៎?

ហឿន៖ ឪវាឈ្មោះ តាឆែម មេខ្មែរក្រហម ។

ដានី៖ បូរាណនឹងឪឈ្មោះ ឆែម?

ហឿន៖ ខែមៗ! មេខ្មែរក្រហមចំហើយអាហ្នឹង ។

ដានី៖ ខែមហ៎?

ហឿន៖ បាទ! ខែម ។

ដានី៖ គាត់នៅឯណាឥឡូវហ្នឹង ស្រុកកំណើតគាត់នៅឯណា?

ហឿន៖ នៅភូមិវត្តដំណាក់ត្រាច ស្រុកត្រាំកក់ហ្នឹងដែរ ឃុំត្រពាំងធំត្បូងដែរ ។

ដានី៖ បូរាណហ្នឹង?

ហឿន៖ បូរាណហ្នឹង កូនគាត់ ហើយកូនប្រសារតាម៉ុកហ្នឹងឡើងកងពលធំ ដល់ចូលព្រៃ ។

ដានី៖ អីចឹងកាលអឹនៅត្រាំកក់ បូរាណហ្នឹងធ្វើអីទៅ?

ហឿន៖ បូរាណហ្នឹងគេធ្វើជាប្រធានមន្ទីរតាម៉ុក ។

ដានី៖ ប្រធានមន្ទីរ?

ហឿន៖ បាទ! ប៉ុនវាស្លាប់ហើយ ។

ដានី៖ ហើយបូរាណហ្នឹង ធ្វើប្រធានមន្ទីរតាំងពីណាមក?

ហឿន៖ ខ្ញុំដឹងវាធ្វើប្រធានមន្ទីរ៧៥,៧៦ ហ្នឹង ខ្ញុំលែងដឹងហើយ វាដឹកជញ្ជូនយកគ្រាប់មកដាក់នៅភូមិខ្ញុំ ឈ្មោះភូមិត្រពាំងព្រៃ ហ៊ូត្រពាំងជ្រៃ គ្រាប់នោះគ្រាប់ គ្រាំងធំនោះធំៗ ដាក់ជញ្ជូនបីខែ រៀបបីខែបានហើយ ប្រជាជនបីភូមិរៀប យប់ឡើងរៀប ។ កាំភ្លើងតូចកាំភ្លើងធំសុទ្ធ តែអា១៣០,១៥៥ យកមក ។

ដានី៖ បូរាណហ្នឹង ប្រធានមន្ទីររបស់តាម៉ុក នៅតាកែវ?

ហឿន៖ បាទ! គេទទួលគ្រប់ផ្នែកទាំងអស់ ។

ដានី៖ ចុះពេលតាម៉ុកគាត់មកបាត់ដំបងមកអីទៅ បូរាណគាត់មានឡើងធ្វើអីទៀតដែរអត់?

ហឿន៖ អត់ទេ! គាត់នៅតែចាត់ចែងប្រធានមន្ទីរ ។

ដានី៖ អត់មានផ្លាស់ទៅណាទេ?

ហឿន៖ អត់ទេ! ទល់តែយួនចូលស្រុក បានរត់ចូលព្រៃ ។

ដានី៖ ចូលព្រៃទៅហើយឡើងស្អីវិញទៅ?

ហឿន៖ ចូលព្រៃគេកាន់កងពល ។

ដានី៖ កងពលនៅឯណាទៅ?

ហឿន៖ កងពលលេខប៉ុន្មានក៏អត់ដឹង គេនៅខាងច្រកកោះកុង ខ្ញុំនៅភាគខាងជើង ។

ដានី៖ ហ៊ូ! បូរាណនៅច្រកកោះកុង?

ហឿន៖ បាទ!

ដានី៖ ចុះវិន?

ហឿន៖ វិនហ្នឹង ឡើងទៅនៅភាគខាងជើងដែរ ។

ដានី៖ ខាងជាមួយតាម៉ុក?

ហឿន៖ ហ្នឹងហើយ នៅជាមួយតាម៉ុក ។

ដានី៖ ភាគខាងជើងណា ១០០៣?

ហឿន៖ ខាងភូមិភាគឧត្តរហ្នឹង ម្តុំភ្នំដងរែកហ្នឹងទាំងអស់ ។

ដានី៖ ប៉ុន្តែបូរាណគាត់អត់ទៅហ្នឹងទេ?

ហឿន៖ បូរាណអត់ដែលទៅដល់ទេ ។ នៅតែម្តុំនេះ តាម៉ុកត្រូវការអី គេជិះឡានថៃមកហ្នឹង មកធ្វើការនៅហ្នឹង ។

ដានី៖ ចុះបូរាណហ្នឹងគេនៅរស់ ឬក៏ស្លាប់បាត់ហើយ ។

ហឿន៖ ស្លាប់ហើយ! ស្លាប់កំពុងវាយ កំពុងត្រៀមយួនបាញ់ផាប់ទៅ ។

ដានី៖ ឆ្នាំណា?

ហឿន៖ ឆ្នាំ៧០ ហ្ញ៉ូណែ៩០ខ្ទង់៩៨, ៩៩ហើយ ។

ដានី៖ ៩៨, ៩៩ យើងសមាហរណ៍កម្មហើយហ្នឹង? ៨០ទេអី? យើង៩៦នេះនៅសំឡូតគេសមាហរណ៍កម្មហើយហ្នឹង?

ហឿន៖ អត់ទាន់!

ដានី៖ អ៊ុន គាក់ចូលមកនៅ?

ហឿន៖ នៅទេ! អត់ទាន់មានអ៊ុនគាក់ចូលមកទេ ។

ដានី៖ អ៊ុនគាក់ចូលមកឆ្នាំ៩១, ៩២ គាត់ស្លាប់មុនអ៊ុនគាក់មក?

ហឿន៖ ស្លាប់មុនហ្នឹង! គាត់ឡើងពីស្រុកមកដាន់ខ្សែត្រៀមយួន យួនបាញ់ស្លាប់ ។

ដានី៖ ចឹងតាំងពីជំនាន់៨០ដាង មើលទៅ?

ហឿន៖ ៨០ដាងហ្នឹងហើយ ។

ដានី៖ ៨០ប៉ុន្មានទៅ?

ហឿន៖ អត់ចាំដែរ!

ដានី៖ មិញកូនទី៣ឈ្មោះ ហ៊ាញ, ព្រៀក ហ៊ាញ ហើយកូនទី៤គ្រូ?

ហឿន៖ ទី៤ឈ្មោះ អាគ្រូ អាណែបមាត់ហ្នឹង ។

ដានី៖ ស្រី ឬប្រុស?

ហឿនៈ ស្រី! គេហៅតាអាគ្រូៗផែបមាត់ៗ

ដានីៈ ប៉ុនទី១ក៏ស្រី ទី២ក៏ស្រី ទី៣ក៏ស្រី ទី៤ក៏ស្រី?

ហឿនៈ បាទ! ស្រីទាំងអស់ៗ

ដានីៈ គ្រូហ្នឹង ប្ដីគាត់ធ្វើអី?

ហឿនៈ គ្រូហ្នឹងអត់ស្គាល់ទេ! ប្ដីអត់ដែលឃើញទេ អាគ្រូខ្ញុំឃើញនៅជាប់ជិតភូមិហ្នឹងមួយឆ្នាំ ហើយពីហ្នឹងទៅគេបែកទៅណាទៅណីបាត់ឆ្ងាយ លែងស្គាល់ហើយៗ

ដានីៈ បន្ទាប់ពីគ្រូមកកូនគាត់ ពីណាទៀតទៅ?

ហឿនៈ អស់ហើយៗ មានតែយាយហ៊ាញប្រពន្ធអាភាណ យាយហូ យាយខុម បួននាក់ហ្នឹងៗ

ដានីៈ ចុះថាឈ្មោះច្រិចម៉េចហ្នឹង ថាកូនម៉េចទេ?

ហឿនៈ មីច្រិចហ្នឹងកូនពៅ, មីច្រិចហ្នឹងៗ

ដានីៈ មីច្រិចហ្នឹងកូនពៅ របស់តាម៉ុក?

ហឿនៈ កូនពៅ ទើបការឆ្នាំ៨៨ ការនៅប្រាច់ៗ

ដានីៈ ច្រិចហ្នឹងកូនពៅគាត់?

ហឿនៈ ពៅគាត់!

ដានីៈ ឈ្មោះ ខុមទី១ ទី២ឈ្មោះហូ ទី៣ឈ្មោះហ៊ាញ ទី៤ឈ្មោះគ្រូ ទី៥ឈ្មោះច្រិចៗ ច្រិចហ្នឹង ការ៨៨? ប្ដីគាត់ឈ្មោះអី?

ហឿនៈ ឈ្មោះគឺ ជនជាតិៗ

ដានីៈ ជនជាតិអីគេទៅ?

ហឿនៈ អត់ដឹងជនជាតិអីទេ ចោះត្រចៀក ពាក់ក្អកប៉ុនៗមេដៃ នៅត្រចៀកៗ

ដានីៈ ឥឡូវហ្នឹងក៏ចឹងដែរ?

ហឿនៈ ម៉ែឪអាគីហ្នឹង! អាគីអត់ចោះត្រចៀកចឹងផងៗ

ដានីៈ អាគីហ្នឹងនៅឯណាឥឡូវ?

ហឿនៈ នៅជិតនេះដែរៗ

ដានីៈ គីហ្នឹងធ្វើអីដែរ?

ហឿនៈ អត់មានធ្វើអីទេ! ជនជាតិ តាម៉ុកហៅមកផ្សំផ្គុំឲ្យកូនគាត់ទៅៗ

ដានីៈ អត់មានតួនាទីអីធ្វើ?

ហឿនៈ អត់! ដល់ការហើយក៏អត់មានតួនាទីអី រវល់តែរបះរបើកអាផ្ទៃក្នុងផង អាក្រៅផង អត់មានធ្វើអីទេ រហូតទល់បែកគ្នាទៀត ។

ដានីៈ អត់ដឹងជនជាតិអីទេ កូនប្រសារ?

ហឿនៈ អត់ដឹងជនជាតិអី ។

ដានីៈ ចឹងកឺ ហើយនឹងច្រិច ហ្នឹងគាត់នៅសំឡូតតែម្នាក់ឯង?

ហឿនៈ នៅពីរនាក់ប្តីប្រពន្ធគ្រួសារគាត់ ។

ដានីៈ ប៉ុន្តែបង១គាត់ផ្សេងទៀត មិញដូចឈ្មោះខុម ខុមគាត់ស្លាប់ហើយ, ឈ្មោះហូ ,ហ៊ាញប្តី, គ្រូ?

ហឿនៈ ហូនៅ, ហ៊ាញប្តីស្លាប់ហើយ, យាយហូប្តីស្លាប់ គ្រូអត់ដឹង ប៉ុនដឹងតែឈ្មោះកូន ។

ដានីៈ ហ្នឹងនៅណា? ពួកគាត់នៅឯណា?

ហឿនៈ អត់ដឹងទេ ។

ដានីៈ អត់ដឹងនៅឯណាទេ?

ហឿនៈ អត់!

ដានីៈ ចុះមួយទៀតដែលអ៊ំប្រាប់ខ្ញុំពីម្សិលថាឈ្មោះ តាវ៉ែន១ ក្រែងកូនប្រសារគាត់?

ហឿនៈ តាវ៉ែនហ្នឹង ប្តីមីកាហូហ្នឹងតើ, វ៉ែនហ្នឹងមិនកូនប្រសារតាម៉ុកដែរ ។

ដានីៈ បាទ!

ហឿនៈ ហ្នឹងហើយ ប្តីមីការហូហ្នឹងហើយ មិនមែនមីកាហូទេ មីគ្រូ ។

ដានីៈ គ្រូ!

ហឿនៈ បាទ! ហ្នឹងហើយ តាវ៉ែន១ ហ្នឹងខ្ញុំភ្លេច ។

ដានីៈ ភ្លេច! ប្តីគ្រូ!

ហឿនៈ ប្តីវាឈ្មោះ តាវ៉ែនប្តីមីគ្រូ ហ្នឹង ចេះតែរកនឹកអត់ឃើញ ។

ដានីៈ តាវ៉ែនគាត់ធ្វើអី ពេលអ៊ំនៅត្រាំកក់ហ្នឹង?

ហឿនៈ កាលហ្នុងកងពល, កងពលតូច ប្រចាំការនៅកំពង់អំពិល នៅជាប់ផ្សាររមេយ ការពារព្រំដែនទឹក ។

ដានីៈ ហ៎ូ! ចឹងកំពង់អំពិលខាងគីរីវង្ស?

ហឿនៈ ខាងស្រុក១០៧ ស្រុក១០៧ហ្នឹង មុំជុំវិញតាកែវ កំពង់អំពិល កំពង់យោលសុទ្ធតែនៅលើតាវ៉ែននៅកងជើងទឹក ។

ដានីៈ ១០៥ នៅត្រាំកក់?

ហឿនៈ ត្រាំកក់! ១០៥ ត្រាំកក់, ១០៦ អង្គរជ័យ, ១០៧ ជុំវិញតាកែវ, ១០៨ កោះអណ្តែត, ១០៩ គិរីវង្ស មានតែ៥ស្រុកហ្នឹង។

ដានីៈ ចឹងជុំវិញហ្នឹងស្រុកទ្រាំង?

ហឿនៈ កាលហ្នឹងអត់មានស្រុកទ្រាំងទេ ទៅភាគខាងស្អី!

ដានីៈ ចុះ១០៧ ទៅស្រុកអី?

ហឿនៈ អាហ្នឹងស្រុក ដាក់១០៧ហ្នឹង អត់ដឹងស្រុកអីផង។

ដានីៈ បាទ! ប៉ុន្តែតាវ៉ែនបន្ទាប់ពីយើងរំដោះឆ្នាំ៧៥ គាត់ធ្វើប្រធានកងពលនៅហ្នឹង?

ហឿនៈ ៧៥ខ្ញុំទៅជួបទៅសុំដូរស្រូវ នៅខាងត្បូងភ្នំបូរី នៅជាប់កំពង់អំពិលហ្នឹង ផ្ទះគាត់នៅក្នុងបឹង។

ដានីៈ ប៉ុន្តែគាត់នៅធ្វើប្រធានកងពល?

ហឿនៈ មេកងពលធំហ្នឹង!

ដានីៈ កងពលធំរបស់ភូមិភាគ?

ហឿនៈ អត់ធំទេ! តូចទេនិយាយប្រឡំ កងពលនៅលើគាត់។

ដានីៈ មានតែមួយទេកងពលនៅនិរតី?

ហឿនៈ កងពលមានតាមុតហ្នឹងមួយ តាវ៉ែនហ្នឹងកងពលតូច តាមុតកងពលធំនៅហ្នឹង។

ដានីៈ ប៉ុន្តែតាមុតគាត់ចេញមកនៅខាង?

ហឿនៈ ចេញទៅកោះកុងកំពង់សោម នៅតាវ៉ែននៅហ្នឹង។

ដានីៈ តាវ៉ែននៅហ្នឹងរហូត?

ហឿនៈ នៅរហូតដល់យួនចូលស្រុក បានគាត់រត់ចេញ រត់ចូលព្រៃ។

ដានីៈ បាទ! គាត់អត់មានរត់ទៅណាទៀតទេ។

ហឿនៈ អត់ទេ! ចូលព្រៃហើយឈឺស្លាប់ទៅទៀតទៅ។

ដានីៈ តាវ៉ែនហ្នឹងឈឺស្លាប់ក្រែងអីទៅមើលគាត់នោះ?

ហឿនៈ ឋីមិនមើល! នៅជិតគ្នាហ្នុង។

ដានីៈ នៅឯណា?

ហឿនៈ នៅភ្នំដងរែក នៅលើទន្លេល្អៅ ស្លាប់នៅពេទ្យ ដេករលួយខ្នងនៅតែឆ្អឹង។

ដានីៈ ដេកយូរហ៎?

ហឿនៈ ដេកយូ! ឈឺយូរ កម្មពៀរ ។

ដានីៈ កម្មពៀរយ៉ាងម៉េច?

ហឿនៈ សម្លាប់គេខ្លាំងពេក ។

ដានីៈ សម្លាប់នៅឯណា?

ហឿនៈ សម្លាប់កងទ័ព ។

ដានីៈ កងទ័ពនៅណាទៅជំនាន់ ប៉ុល ពត?

ហឿនៈ ទ័ពដែលនៅកំពង់អំពិលហ្នឹង បញ្ជូនមកក្រោយដូចពិនិត្យប្រវត្តិរូបទៅវាអត់ច្បាស់ គេឲ្យតែខោខ្មៅ ដូចពីម្សិលមិញ សុំអាវ សុំមួកគេពាក់មកផ្ទះអត់ឲ្យ សុំតែសំបុត្រ សុំបាយគេស៊ីក៏មិនឲ្យ ឲ្យមកតែខោខ្មៅ ដើរមកមួយយប់មួយថ្ងៃ ដល់ផ្ទះម៉ោង១០យប់ ពីព្រំដែនវៀតណាមមក ។ សម្លាប់ទ័ពសម្លាប់ក្នុងកងទាំងអស់ ហឺអាសល់ដែលអត់សម្លាប់ ២០០នាក់ឲ្យមកវិញ ប្អូនជីដូនមួយខ្ញុំមួយមកដល់ផ្ទះម៉ោង១០យប់ កងតាវ៉ែន ។

ដានីៈ ចឹង! ដល់ពេលគាត់ឈឺៗ អីដែរស្លាប់ហ្នឹង?

ហឿនៈ ឈឺអត់មានដឹងថាឈឺស្អី ឈឺអាចម៍អត់ដឹង នោមអត់ដឹង ដេកតែអាចម៍ដេកតែនោមនៅតែហ្នឹង ។

ដានីៈ ដើរអត់រួចទេ?

ហឿនៈ ដើរអត់រួចផង ។

ដានីៈ ធាត់ ឬស្គម?

ហឿនៈ ស្គម! រាគហូរដល់ស្លាប់ ។

ដានីៈ ចុះប្រពន្ធមាននៅមើលដែរ?

ហឿនៈ ប្រពន្ធនៅមើលហ្នឹង នៅដេកពេទ្យជាមួយគ្នាហ្នឹង ហើយតាម៉ុកក៏នៅជិតហ្នឹង ។

ដានីៈ តាម៉ុកអត់មើលទេ?

ហឿនៈ អត់ដែលមកមើលផង ។

ដានីៈ ចុះគេឮល្បីថាតាម៉ុកសម្លាប់ដែរ ឬអត់ទេ?

ហឿនៈ សម្លាប់តាវិនហ្នឹង ហឺអាណាមួយទៀត អត់ទេ សម្លាប់តែកូនហ្នឹងមួយ ។

ដានីៈ ចឹង! តាវ៉ែនហ្នឹងអត់ទេ?

ហឿនៈ តាវ៉ែនអត់ទេ! ឡើងភ្នំអត់បានសម្លាប់ណាគេ ប៉ុន្តែទៅបាញ់ទាប្រជាជន ។

ដានីៈ បាញ់អីគេ?

ហឿនៈ បាញ់ទា!

ដានីៈ ពីណាបាញ់?

ហឿនៈ តាវ៉ែនហ្នឹង! ទាគេ គេទប់ទំនប់ឲ្យទាលេង មនុស្ស ២,៣ ភូមិក្បែរទំនប់ហ្នឹង គេពួតដៃគ្នាលើកទប់ទំនប់ ។ ដល់ទប់ទំនប់តាវ៉ែនទៅត្រួតត្រាថាកុំឲ្យលែងទា ហើយប្រជាជនថា ខ្ញុំទប់ឲ្យទាលេងតើ! ដល់ថាអីចឹង តាវ៉ែនយកឡានគាត់អាហ្ស៊ីបជិះទៅបាញ់ បាញ់ផាប់ទាំងអស់លើកបោះដាក់ឡាន អារត់ទៅផ្ទះចូលទ្រុង ទៅបាញ់នៅក្នុងទ្រុងទៀត ។

ដានីៈ គាត់បាញ់ត្រង់?

ហឿនៈ បាញ់កាំភ្លើង ចុះទា គាត់មិនមែនអ្នកបាញ់ទេ អ្នកការពារគាត់ទៅបាញ់ទាំងអស់ក្បែរៗផ្ទះខ្ញុំ ខ្ញុំនៅអូរហ្នឹងដែរ ។

ដានីៈ អូរណា?

ហឿនៈ អូរហ្នឹងអត់មានឈ្មោះ ស្រុកថៃ ដីថៃ ។

ដានីៈ ដីថៃ ប៉ុន្តែកាលគាត់ស្លាប់ហ្នឹង នៅក្បែរទន្លេល្អៅ នៅពេទ្យ?

ហឿនៈ ស្លាប់នៅពេទ្យទន្លេល្អៅ គេថាពេទ្យក-៧ ។

ដានីៈ ដូចជាកូនតាម៉ុក ដូចពេល ហូ ហ្នឹងប្តីគាត់ឈ្មោះវិន ដល់ពេលតាម៉ុកបាញ់ស្លាប់ទៅគាត់យកប្តីទៀតដែរអត់?

ហឿនៈ អត់! អត់មានអាណាយកនៅទល់តែឥឡូវ ។

ដានីៈ ចុះគ្រូហ្នឹង! ឈ្មោះ គ្រូ ឬគ្រួ?

ហឿនៈ អាគ្រូហ្នឹងមនុស្សស្រី ប៉ុនវាឆែបមាត់ ។

ដានីៈ ហើយមានយកប្តីទៀតអត់ បន្ទាប់ពីតាវ៉ែន?

ហឿនៈ អត់ៗ! ទល់ឥឡូវហ្នឹងដែរ ។ យាយហូ ក៏អត់, មីកាហ៊ាញនោះក៏អត់ ។ ប្តីហ្នឹងផាប់អត់មាននរណាស្រឡាញ់ទៀតទេ គេស្អប់អត់តាម៉ុក ហើយកូនមីកាច្រិច ក្រមុំ៤ នៅទាំងអស់ទៀត ។

ដានីៈ ឥឡូវហ្នឹង?

ហឿនៈ បាទ! នៅធំៗ គេស្អប់តាម៉ុក ខ្សែតាម៉ុក ។

ដានីៈ នៅនេះគេស្រលាញ់តាម៉ុកដែរអត់? ក្រៅនៅសំឡូតនេះ គេស្រលាញ់ គេចូលចិត្តតាម៉ុកដែរអត់?

ហឿនះ អត់មាននរណាដែរនិយាយរឿងតាម៉ុកថាស្អប់ថាស្រលាញ់អត់ ប៉ុន្តែកូនចៅ តាម៉ុក គេស្អប់ គេអត់យកហ្នឹង មកពីគេស្អប់ ។

ដានីះ ចុះអ៊ីស្អប់តាម៉ុកដែរ?

ហឿនះ ខ្ញុំអត់មានដែរស្អប់ ទៅសុំពូថៅបានមួយ នៅប្រើទាល់តែឥឡូវ ។

ដានីះ អត់មានស្អប់អីគេទេ?

ហឿនះ អត់!

ដានីះ ស្រលាញ់គាត់ទេ?

ហឿនះ ស្រលាញ់ក៏អត់ ស្អប់ក៏អត់ ។

ដានីះ ម៉េចបានអត់ស្រលាញ់ អត់ស្អប់ គាត់យ៉ាងម៉េចបាន?

ហឿនះ ស្អប់គាត់ថា ពេលដែលឲ្យទ័ពចុះទៅក្នុង ហើយផ្ទះគាត់នៅជំនៀរភ្នំដីរាបក្រោម ហើយផ្លូវជំនៀរភ្នំលើខ្ពស់មើលទៅឃើញដំបូលលីមៗ ដល់ហើយឃើញទ័ពចុះទៅ គាត់រៀបចំឲ្យចុះ ប៉ុនគាត់ជេរ គាត់ថាពួកអាហ្វែងកុំហក់ តាម៉ុក ហើយពត នៅរស់ ហ្វែងកុំហក់នៅលើមុខ មានតែមួក នៅលើមួកមានតែមេឃទេ ហ្វែង កុំបាច់ហក់ ថាចឹង គេបាញ់បាញ់មួយបង់ម្នាក់ និយាយពីផ្ទះខ្ញុំទៅឃើញសុះពេញរនូបែក ។

ដានីះ នៅឯណាហ្នឹង?

ហឿនះ នៅភូមិប្រាច់ ។

ដានីះ នៅប្រាច់?

ហឿនះ នៅលើភ្នំតាចក់ ។

ដានីះ ឆ្នាំណា?

ហឿនះ អាហ្នឹង៨៨ ។

ដានីះ ៨៨?

ហឿនះ បាទ! ខ្ញុំចាំ ដឹកខ្ញុំពីអូរគ្រាវ ទៅដាក់ប្រាច់ ។

ដានីះ កាលអ៊ីនៅធ្វើគណៈស្រុកត្រាំកក់ កូនចៅអ៊ី កូនអ៊ីម្នាក់នោកងទ័ពជើងទឹក ឈ្មោះ បារាំង ហើយកូនផ្សេងៗទៀតនៅឯណា?

ហឿនះ អាទី២ៗ វាចូលមកនៅភ្នំដងរែក ឥឡូវបាត់ទៀតហើយ ។

ដានីះ អត់ទេ! បានន័យថាអ៊ីនៅត្រាំកក់ណា កាលនៅត្រាំកក់ កូនអ៊ីនៅឯណា?

ហឿនះ កូនខ្ញុំអាបងគេនៅជាមួយខ្ញុំ ។

ដានី៖ មិនមែននៅជាមួយតាមុតទេ?

ហឿន៖ អត់ទេ! ដល់អាបារាំង បានវាទៅជាមួយតាហ្នុង ។

ដានី៖ អូ! កាលពេលរំដោះឆ្នាំ៧៥អឹនៅត្រាំកក់ កូនបងនៅជាមួយអឹ គាត់ធ្វើអីហ្នឹង?

ហឿន៖ នៅជាមួយអឹដែរ ចូល៧៥ជាងហើយ បានវាទៅ តាមុតមកឃើញហៅវាទៅ ។

ដានី៖ ហៅវាទៀត!

ហឿន៖ ហៅទៅនៅជាមួយតា ។

ដានី៖ ឈ្មោះអីទៅ?

ហឿន៖ ឈ្មោះអាបារាំង ។

ដានី៖ បារាំងហ្នឹង កូនបងគេបង្អស់?

ហឿន៖ កូនប្រុសអាឃឿន អាឃួន, អាបារាំងបន្ទាប់អាឃួន ទី៣ហើយ ។

ដានី៖ កូនបងគេឈ្មោះឃួន?

ហឿន៖ ឈ្មោះ ឃឿន ។

ដានី៖ ឃឿនគាត់នៅឯណា?

ហឿន៖ ឃឿនហ្នឹង នៅជាប់ជាមួយខ្ញុំ ។

ដានី៖ នៅជាមួយខ្ញុំរហូតដល់ អឹទៅកំពង់ចាម?

ហឿន៖ ដល់ខ្ញុំទៅកំពង់ចាម គេបញ្ជូនឲ្យវាធ្វើទ័ពភាគ ទ័ពភាគតាម៉ុកហ្នឹង ។

ដានី៖ ដល់ពេលកាលគាត់នៅជាមួយអឹនៅត្រាំកក់គាត់ធ្វើអ្វី?

ហឿន៖ កូនខ្ញុំអត់មានធ្វើអីផង តូចៗដែរ ។

ដានី៖ កាលហ្នុង ក្រែងបងគេម៉េចតូច?

ហឿន៖ តូច!

ដានី៖ ចុះបារាំង ម៉េចបានទៅធ្វើជាមួយ...?

ហឿន៖ អាបារាំង៧៥ហើយ គ្រាន់តែអាយុ១១ឆ្នាំ គេយកទៅ ហើយឈប់ទៅ ។

ដានី៖ ១១ឆ្នាំ ម៉េចបានដឹងរឿងគេសម្លាប់?

ហឿន៖ ចុះឃើញហ្នឹងភ្នែក ។

ដានី៖ ចុះម៉េចទៅផ្ទះរកឃើញ បើនៅអាយុទើបតូចមួយ?

ហឿនៈ	កាលហ្នឹងឡានចេញចូលទាំងយប់ទាំងថ្ងៃ ទៅកោះកុងកំពង់សោម កន្លែង គាមុត ហ្នឹង អាខ្លះទៅរកឡាន អាខ្លះទៅរកអីយកមកប្រើ ឡានស្រុកត្រាំកក់ ឡានច្រើនជាងឡានខេត្តទៅសុំ ។

ដានីៈ	បាទចឹងឈ្មោះឃឿន គាត់នៅជាមួយអ៊ំនៅត្រាំកក់នៅធ្វើអីគេ?

ហឿនៈ	នៅធ្វើនិរសារត់សំបុត្រតាម!

ដានីៈ	និរសារត់សំបុត្រឲ្យពីណាគេ?

ហឿនៈ	យកទៅតាមឃុំ គ្រប់ឃុំ ។

ដានីៈ	និរសា ឃឿន អីចឹងនិរសារត់សំបុត្រឲ្យអ៊ំ ឬក៏ឲ្យគណៈ មន្ទីរស្រុកទាំងមូល?

ហឿនៈ	អត់ទេ! ខ្ញុំចាត់តាំងវាឲ្យរត់ ធ្វើសំបុត្រឲ្យដូចថាត្រូវការឲ្យឃុំមកយកសម្ភារៈនៅឯស្រុក សរសេរសំបុត្រ១៥សំបុត្រហ្នឹងឲ្យទៅគ្រប់ឃុំទាំង១៥ហ្នឹង ។

ដានីៈ	ជិះអីទេ?

ហឿនៈ	មានតែកង់ទេកាលហ្នឹង ។

ដានីៈ	អត់មានសេះជិះទេ?

ហឿនៈ	អត់មានទេ!

ដានីៈ	កាលហ្នឹងគាត់អាយុប៉ុន្មាន?

ហឿនៈ	អាឃឿនហ្នឹង អាយុ១៣ ហើយ ។

ដានីៈ	ឃឿនហ្នឹង?

ហឿនៈ	អាឃឿនហ្នឹង អាបារាំង១១ ហើយអាឃួន១២ជាងហើយ ។

ដានីៈ	ឃួនគាត់ធ្វើអី កាលហ្នឹង?

ហឿនៈ	អត់ធ្វើអីទេ ។

ដានីៈ	នៅជាមួយអ៊ំដែរ?

ហឿនៈ	កាលហ្នុងវានៅមន្ទីរស្រុកខាងជួសជុលឡាន ធ្វើឡាន ។

ដានីៈ	មន្ទីរស្រុកត្រាំកក់ជាមួយហ្នឹងដែរ?

ហឿនៈ	បាទ! នៅក្នុងមន្ទីរហ្នឹងជាមួយគ្នា ។

ដានីៈ	ខាងជួសជុលឡាន ។

ហឿនៈ	បាទ! ខាងជួសជុលឡាន ។

ដានីៈ	បារាំងហ្នឹង ឥឡូវគាត់ស្លាប់ហើយ?

ហឿនៈ វាងាប់ក្នុងព្រៃ ។

ដានីៈ ឆ្នាំណា?

ហឿនៈ ឆ្នាំ៧៩ហ្នឹងរត់ចូលព្រៃហើយ បានបាត់ដំណឹង ។

ដានីៈ ៧៩ហ្នឹងហេ៎?

ហឿនៈ បាទ!

ដានីៈ បាត់ទៅ?

ហឿនៈ បាត់លែងដឹងដំណឹង ។

ដានីៈ ចុះឈ្មោះឃឿន?

ហឿនៈ ឈ្មោះឃឿននៅ! ប៉ុនឥឡូវលែងប្រពន្ធនៅនេះ ទៅបាត់វាយថ្ងៃ៦,៧កក្កដាហ្នឹងទៅបាត់រហូតទៅ ។

ដានីៈ បាត់រហូតអត់ដឹងទៅណាទេ?

ហឿនៈ ដឹងថានៅរស់មកម្តង មកម្តងវាយកប្រពន្ធមួយទៀត អាប្រពន្ធហ្នុងងាប់ទៅវាទៅយកមួយទៀតជិតហ្នឹងហើយបាត់ឈ្មោះរហូត ទាក់ទងលែងតូ ។

ដានីៈ អត់ដែលមកជួបអីទេ?

ហឿនៈ អត់! មកម្តង លែងមករហូតទៅ ។

ដានីៈ គាត់មានដឹងដំណឹងថានៅណា?

ហឿនៈ អត់ដឹង! បាត់មិនដឹងវាទៅ... ។

ដានីៈ ហ្នឹងឈ្មោះឃឿន ចុះឃួន?

ហឿនៈ ឃួនកាលហ្នឹងនៅជួសជុលឡាន ។

ដានីៈ ជួសជុលឡាន?

ហឿនៈ ជួសជុលឡាននៅក្នុងស្រុក ។

ដានីៈ ជួសជុលឡាននៅត្រាំកក់ដែរ ហើយគាត់ទៅណាដែរឥឡូវ ។

ហឿនៈ ឥឡូវខ្ញុំនៅរតនៈគិរី ។

ដានីៈ នៅរតនៈគិរី ។

ហឿនៈ គេយកប្រពន្ធគេលាវនៅរតនៈគិរី គេទើបតែទៅពាឆ្នាំទាំងឆ្នាំហ្នឹង ។

ដានីៈ គាត់ទើបតែទៅពាឆ្នាំនេះទេ?

ហឿនៈ បាទ!

ដានី:	ប្រពន្ធលោកគាត់យកតាំងពីអន្កាល់?

ហឿន:	យកឆ្នាំ៨៤ យកហើយ៨៤ ។

ដានី:	ពីមុនហ្នឹងអត់ទាន់មានប្រពន្ធទេ?

ហឿន:	អត់! ក្មេងៗ ។

ដានី:	បាទ!៣នាក់ ។ ចុះកូនប៉ុន្មាននាក់ទៀតនោះ?

ហឿន:	កូនខ្ញុំ៦នាក់ ៧នាក់អាបារាំងហ្នឹងងាប់បាត់ ។

ដានី:	ចុះប្អូនបារាំងអីហ្នឹងនៅ?

ហឿន:	ប្អូនហ្នឹងនៅស្រីនៅនេះ ។

ដានី:	ប៉ុន្តែកាលជំនាន់អ៊ឹនៅត្រាំកក់គាត់ធ្វើអី?

ហឿន:	អត់មានធ្វើអីទាំងអស់តូចៗ គេឲ្យដើររើសអាចម៍គោ វាអត់ទៅដើររើសកើតទៀត ។

ដានី:	នៅជាមួយអ៊ី ឬក៏នៅជាមួយម្តាយ?

ហឿន:	នៅជាមួយម៉ែវា អត់មែននៅជាមួយខ្ញុំទេ ។

ដានី:	ចុះអ៊ីប៉ុន្មានថ្ងៃបានទៅជួបប្រពន្ធម្តង?

ហឿន:	អ្ហូ! ទៅផ្ទះម្តងៗ ទាល់តែសុំច្បាប់គេ ហ៊ីខ្មាស់អៀនអត់សុំ ១ខែ ១ខែជាងបានទៅលេង សួរសុខទុក្ខប្រពន្ធកូន ។

ដានី:	បាទ! ក្រែងជំនាន់ហ្នុងគេ ថ្ងៃ១០ ថ្ងៃ២០,៣០អីគេឲ្យឈប់អី?

ហឿន:	អត់ទេ! បើទៅធ្វើស្រែប្រាំងវិញ៦ខែ ភ្លូវដីលិចទឹករាស់ហើយបានគេឲ្យមកផ្ទះវិញទាំងអស់ ទឹកឡើងលិចហើយ អាហ្នឹងបានមក ។

ដានី:	កូនតូចៗនៅជាមួយម្តាយ?

ហឿន:	នៅជាមួយម្តាយ ។

ដានី:	នៅសាលាស្រុកត្រាំកក់តែ២នាក់ទេ?

ហឿន:	តែ២នាក់ ។

ដានី:	តែកូនបងគេឈ្មោះ ឃឿន ហើយហ្នឹងឃួនៗ ឃួនគាត់នៅខាងជួសជុលឡាន ឃឿន គាត់អ្នកនិរសាររត់សំបុត្រ ។

ហឿន:	បាទ!

ដានី:	គាត់រត់សំបុត្ររហូតដល់ពេលណា?

ហឿន:	រត់រហូតដល់ខ្ញុំទៅស្រុកគេ គេបញ្ជូនវាទៅកងតាម៉ុកបាត់ ថាឡើងកងភាគណុះ ។

ដានីៈ ពេលលោកអ៊ំទៅកំពង់ចាម ទៅខាងចម្ការកៅស៊ូ ឃឿន គេបញ្ជូនទៅកងទ័ពភាគនៅតាកែវ?

ហឿនៈ ហ្នឹងហើយ! ដឹងវាទៅច្រកណាទៅ។

ដានីៈ ចុះឃួន?

ហឿនៈ អាឃួនដល់ខ្ញុំទៅដើង វាទៅជាមួយគ្នា។

ដានីៈ ទៅកំពង់ចាមជាមួយគ្នា?

ហឿនៈ បាទ! ទៅជាមួយគ្នា វារត់ចូលព្រៃចូលជាមួយខ្ញុំរហូត ដល់ចេញមកវិញ ឆ្នាំ២០០០។

ដានីៈ ចុះអ៊ំកាលទៅកំពង់ចាម ប្រពន្ធអ៊ំកូនចៅ ឪពុកម្ដាយ បងប្អូនអីទៅជាមួយអ៊ំទាំងអស់?

ហឿនៈ ទៅៗតែគ្រួសារខ្ញុំ ឪពុកម្ដាយនៅស្រុកកំណើតនៅណោះ។

ដានីៈ បាទ! ចឹងអ៊ំ ប្រពន្ធអ៊ំ កូនប៉ុន្មាននាក់ទៅជាមួយ?

ហឿនៈ ទៅ៤នាក់ ស្រី២ ប្រុស២។

ដានីៈ ទៅឃួនហ៊ីហ្នឹងកូនតូចៗ?

ហឿនៈ បាទ! អាឃួន មីការឿន, មីការ៉ន, អានៅ។

ដានីៈ បួននាក់ហ្នឹង?

ហឿនៈ បាទ!

ដានីៈ ឃឿនទៅធ្វើទ័ពភាគ បារាំងគាត់នៅជាមួយតាមុត ចឹងតែ៦នាក់ហ្នឹង?

ហឿនៈ ៧នាក់ផង!

ដានីៈ ចឹងទៅជាមួយអ៊ំ៥នាក់ ព្រោះនៅបែកតែ២ទេ?

ហឿនៈ បាទ! ចឹងហើយ។

ដានីៈ ពេលនៅកំពង់ចាមនៅជាមួយគ្នា លែងបែកគ្នាហើយ?

ហឿនៈ គេនៅមន្ទីរដែរ ខ្ញុំនៅភស្តុភាទៅ។

ដានីៈ ចឹងអ៊ំនៅខាងភស្តុភាចម្ការកៅស៊ូ ឬក៏ចម្ការ?

ហឿនៈ ចម្ការកៅស៊ូជប់ហ្នឹង។

ដានីៈ ហើយអ៊ំស្រីគាត់នៅមន្ទីរ...?

ហឿនៈ មន្ទីរឃ្លាំងជាមួយគ្នាហ្នឹង ខាងដាំបាយ ដាំទឹកអីហ្នឹង។

ដានីៈ ខាងដាំបាយ ដាំទឹកអីហ្នឹង! ហើយចុះកាលហ្នឹងទៅជាមួយតាដឹមដែរ?

ហឿនៈ ទៅជាមួយ!

ដានី៖ តាជឹម គាត់នៅមាំគ្រួសារគាត់ដែរ?

ហឿន៖ នៅទាំងអស់ ទាំងប្រពន្ធទាំងកូនគេទាំងអស់។

ដានី៖ ប្រពន្ធតាជឹមត្រូវជាបងស្រីប្រពន្ធរបស់អ៊ំ ប្រពន្ធតាជឹមគាត់ឈ្មោះអី?

ហឿន៖ បាទ! ឈ្មោះហ៊ាង។

ដានី៖ ឈ្មោះហ៊ាង?

ហឿន៖ បាទ! យាយហ៊ាង។

ដានី៖ ហើយប្រពន្ធអ៊ំឈ្មោះអី?

ហឿន៖ គេហៅកំណើតឈ្មោះហឿន ដល់ហៅក្រោយ ដាក់ឈ្មោះក្នុងអត្តសញ្ញាណប័ណ្ណ ដាក់ ជា នី។

ដានី៖ ប៉ុន្តែមុនឈ្មោះ ហឿន ទេ?

ហឿន៖ ជា ហ៊ាង, ជា ហឿន ពីរនាក់អ្នកហ្នឹង។

ដានី៖ អ៊ូ! ប្រពន្ធអ៊ំឈ្មោះ ជា ហឿន ហើយប្រពន្ធតាជឹម ឈ្មោះ ជា ហ៊ាង!

ហឿន៖ បាទ!

ដានី៖ តាជឹម គាត់នៅប្រពន្ធហើយនិងកូនគាត់ដែរ?

ហឿន៖ បាទ!

ដានី៖ ឪពុកម្តាយ គាត់អត់នៅទេ?

ហឿន៖ ឪពុកម្តាយគាត់ស្លាប់បាត់អស់មុនហ្នឹង។

ដានី៖ ចុះតាជឹម កូនចៅគាត់ប៉ុន្មាននាក់ដែរ?

ហឿន៖ ផាប់បាត់អស់ហើយ។

ដានី៖ ច្រើន?

ហឿន៖ បាទ!

ដានី៖ ប៉ុន្មាននាក់ទៅ?

ហឿន៖ ចាំខ្ញុំរាប់! មួយស្រីឈ្មោះ មីការី, រីហើយ អាចេត, អាចេតហើយ អាណាត, អាណាត ហើយអាភ្លោះ អាធូ អាភ័ក្រ្ត ៥នាក់។ អាធូ អាភ័ក្រ្តហើយ អាហួច អាណាវ ៧នាក់, ស្រីតែមួយទេ។

ដានី៖ គាត់នៅទាំងអស់ ហីអ៊ំមានប្រសាសន៍ពីម្សិលថា តាជឹមគាត់លែងប្រពន្ធគាត់?

ហឿន៖ លែងហើយ លែងតាំងពីឆ្នាំ៨០ ខែ៧។

ដានីៈ	គាត់លែងតាំងពីឆ្នាំ៨០ ខែ៧ ហេតុអ្វីបានគាត់លែងប្រពន្ធ?

ហឿនៈ	ប្រពន្ធហ្នឹងរត់បែកគ្នាមកស្រុកមក មកនៅស្រុក ដល់ហើយគាត់តាមរកប្តីទៅឃើញនៅលើភ្នំដងរែកហ្នឹងវិញ គេយកគ្នាហើយ ។

ដានីៈ	ប្រពន្ធដើមត្រឡប់មកស្រុកវិញ ឬក៏នៅលើភ្នំហ្នឹង?

ហឿនៈ	ត្រឡប់មកស្រុក! ទៅដល់ផ្លូវឆែប នៃសាលាខេត្តឆែបហ្នឹង ទៅដល់បែកគ្នាយួនវាយគេចាប់យាយគាត់បានបញ្ជូនមកខេត្តឆែបហ្នឹងមក ខេត្តស៊ឹងត្រែង, ខេត្តស៊ឹងត្រែងហ្នឹងយួនយកមកដល់ផ្ទះ យកមកដល់ផ្ទះ ដល់ឡើងភ្នំដងរែកវិញ ទៅជួបប្តីឆ្នាំ៨៥ ។

ដានីៈ	៨០ប៉ុន្មាន?

ហឿនៈ	៨៥ទៅជួបប្តីនៅភ្នំដងរែកវិញ ។

ដានីៈ	ដល់ពេលជួបប្តីក៏លែងគ្នាទៅ?

ហឿនៈ	គេលែងគ្នា ។

ដានីៈ	បានន័យថាបែកគ្នាឆ្នាំ៨០ ពេលដែលយួនចាប់បាន ចាប់បានឆ្នាំប៉ុន្មាន?

ហឿនៈ	ឆ្នាំ៨០ ខែ៧ឡើងភ្នំដងរែកហ្នឹង ។

ដានីៈ	ដល់ពេលចឹងបែកគ្នាពេលហ្នឹងហើយ?

ហឿនៈ	បែកគ្នាតាំងពីហ្នឹងរហូត ។

ដានីៈ	បែកអីចឹងទៅ យួនចាប់បានប្រពន្ធកូនទាំងអស់?

ហឿនៈ	បាទ!

ដានីៈ	ចាប់បានតែប្រពន្ធ ហឺកូន?

ហឿនៈ	ចាប់ទាំងកូនទាំងអីទាំងអស់ម៉ាសំបុកហ្នឹង ។

ដានីៈ	រួចតែតាជឹមតែមួយទេ?

ហឿនៈ	រួចតែតាជឹម, តាជឹមទៅដល់លើភ្នំយកស្រីតាំងពីបាត់ប្រពន្ធ ។

ដានីៈ	ដល់ពេលទៅដល់លើភ្នំ បានយកប្រពន្ធមួយទៀត?

ហឿនៈ	បាទ!

ដានីៈ	ដល់ពេលចឹងទៅ គាត់អត់រាប់អានប្រពន្ធដើមកូនចៅអីគាត់អត់នេះទេ?

ហឿនៈ	អត់! ខ្ញុំទោសម្រុះសម្រួល! ខ្ញុំថាឥឡូវ ខ្ញុំសុំនិយាយជាមួយអឹងឯង បើអឹងឯងជ្រុលជាយកប្រពន្ធមួយទៀតទៅហើយ ឥឡូវប្រពន្ធដើមក៏មកដល់ហើយ ឥឡូវខ្ញុំថាឲ្យអឹងឯងរែកកុំឲ្យអឹងឯងពាន់ ធ្វើម៉េចឲ្យរែក តែពាន់អត់បានទេ ហើយគាត់មិនរែកដូចខ្ញុំប្រាប់ តំណាងតា

ម៉ុក ក៏មកប្រជុំជាមួយបង្រួបបង្រួមថាឲ្យវែកកុំឲ្យពន់ដូចគ្នាចឹង ហើគេអត់វែក គេលេង តែពន់ ។

ដានី៖ លេងតែពន់ហ្នឹង បានន័យថាម៉េច?

ហឿន៖ គេមិនវែក គេពន់ គេយកតែមួយ មិនយកទាំងពីរ ។

ដានី៖ ប្រពន្ធគាត់ក្រោយអត់ឲ្យយកទៀត ឬក៏យ៉ាងម៉េច?

ហឿន៖ អត់យក អត់មាត់រក អត់ដែលមកជិត អត់ដែលមកសួរកូនចៅអី អាហ្នឹងបានថា ។

ដានី៖ ហើយប្រពន្ធគាត់ក្រោយនៅឯណា?

ហឿន៖ ប្រពន្ធក្រោយរត់ចូលព្រៃជាមួយគ្នាហ្នឹង ស្រុកគេនៅកំពង់ចាម ។

ដានី៖ អីចឹងប្រពន្ធដើមគាត់ឥឡូវនៅស្រុកកំណើត ឬនៅ?

ហឿន៖ ឥឡូវប្រពន្ធនៅនេះ នៅភូមិជាមួយគ្នានេះ ។

ដានី៖ នៅភូមិជាមួយអ៊ីដែរ?

ហឿន៖ បាទ!

ដានី៖ នៅភូមិ អានេះ!

ហឿន៖ ភូមិតាសាញដើង ។

ដានី៖ ភូមិតាសាញដើង កូនចៅក៏នៅហ្នឹងដែរ?

ហឿន៖ នៅទាំងអស់មួយសំបុកហ្នឹង ។

ដានី៖ តាជីម ហីប្រពន្ធដើម កូនចៅគាត់មុនគាត់អត់រាប់រកទេ?

ហឿន៖ អត់! អត់មាត់រកម៉ង មកម្ដងៗមកជាន់កយកតែលុយទៅចិញ្ចឹមប្រពន្ធចុង ។

ដានី៖ គាត់នៅនោះអត់មានលុយដែរ?

ហឿន៖ អត់! ធ្វើអីបាន ។

ដានី៖ ក្រែងគាត់ធ្វើធំដែរនៅនោះ?

ហឿន៖ អត់ធ្វើអីផង!

ដានី៖ តាជីមគាត់អត់ធ្វើអីទេឥឡូវ?

ហឿន៖ អត់មានធ្វើអីរលីង ។

ដានី៖ គាត់នៅស្រះឈូក ឬនៅ...?

ហឿន៖ ឥឡូវគាត់នៅស្រុកប្រាសាទហ្នឹង ដឹងភូមិអី! ដឹងថានៅក្នុងស្រុកប្រាសាទហ្នឹង ។

ដានី៖ បាទ! ចុះអ៊ីកាលពេលអ៊ីទៅដល់ខាងចម្ការកៅស៊ូជប់អ៊ី កាលហ្នុងអ្នកដឹកនាំគេនៅខាងកំពង់ចាមចាស់ៗនៅសេសសល់អ៊ីដែរ ឬអត់ទេ?

ហឿន៖ កាលអ្នកដឹកនាំចាស់ហ្នុង ដែលទៅនៅចម្ការកៅស៊ូជប់ហ្នុងទៅអត់ទាន់ផង ទៅដល់ឃើញគ្នាឯងដែលទៅពីស្រុកហ្នឹង សោភីម កុយធួន គេថា គេបាញ់ស្លាប់ទៅ អត់មានឃើញអីទេ ឃើញតែ គេប្រាប់ថារណ្តៅៗដូងហ្នឹង សុទ្ធតែខ្មោច គេតែចឹងៗ គេថារណ្តៅខ្មោចហើយគេកាប់សម្លាប់ទាំងឡានៗ គេថាចឹង ឃើញតែរណ្តៅមែនៗ

ដានី៖ ចុះអ៊ំ! តាដឹមអីទៅ កាលហ្នុងប្រជាជនអីនៅច្រើនដែរអត់ទេ?

ហឿន៖ ទៅឯនោះ?

ដានី៖ កាលទៅដល់ជប់ហើយ?

ហឿន៖ ទៅដល់ជប់កម្មករនៅ៥ម៉ឺន ហៅធ្វើមេទ្វិញ ឡើងទៅឃើញបាក់ស្មារតីឃើញសម្បើមពេកៗ ហឹដល់ហើយខែបុណ្យខួប ខែ៩គេការៗ ការ៤០០នាក់ វាមានពី៤ទៅដល់៨ទៅ៨០នាក់ៗ ដល់ចប់លែងមកប្រឡូំគ្នា អាខ្លះបាត់អាខ្លះឃើញ អាខ្លះអត់ៗ

ដានី៖ បែករបៀបម៉េច?

ហឿន៖ បាត់ប្រពន្ធ បាត់គូស្នេហ៍គេហ្នឹងៗ

ដានី៖ ម៉េចបានប្រលែងម៉េច?

ហឿន៖ ចុះគ្រាន់តែថាចប់ហើយ ឥឡូវបិទអគ្គប្រជុំហ្នឹង គេលែងចេញវិមក អាខ្លះគោងដៃគ្នាជាប់អាខ្លះអត់គោងជាប់វាបាត់ទាំងអាអ្នកការទាំងអាអ្នកទៅចូលរួមការវាមនុស្សច្រើនៗ

ដានី៖ ចុះការហ្នឹង ការប៉ុន្មានរយគូ?

ហឿន៖ ៤០០គូៗ

ដានី៖ ខែ៩ ឆ្នាំណា?

ហឿន៖ ឆ្នាំ៧៩ៗ

ដានី៖ ៧ ៩ខែណា?

ហឿន៖ អត់ទាន់ដល់៧៩ទេ, ឆ្នាំ ៨០ខែ៩ៗ

ដានី៖ ខែ៩ ឆ្នាំ៧៨?

ហឿន៖ ឆ្នាំ៧៨!

ដានី៖ ចុះអ៊ំទៅទើបបានតែមួយខែហ្នឹង?

ហឿនៈ ខ្ញុំទៅ៧៨ ខែ៨ ហីទៅបាន១ខែហ្នឹង យួនចូលហ្នឹងរត់ចោលទៅ មិនទាន់បានធ្វើអី ដឹងអីអត់ ។

ដានីៈ ចុះកាលហ្នឹងយើងទៅចឹង យើងទៅពីខាងតាកែវទៅ តាម៉ុក មានដាក់ផែនការអីថាទៅខាងនោះ ក្បត់អី យ៉ាងម៉េចៗ?

ហឿនៈ អត់ទេ! ទៅដល់នោះទទួលផែនការពី តាសុន សេន ហ្នឹងហើយ ។

ដានីៈ ទទួលផែនការពីតាសុន សេន វិញ?

ហឿនៈ ខ្ញុំដែលឃើញសារាចរណ៍ តាសុន សេន ហ្នឹងឆ្នាំ៧៨ ខែ៨ហ្នឹង ខ្ញុំទៅដល់ ឃើញគេសារាចរណ៍ គេសរសេរថា "សូមមិត្តបោសសំអាតខ្មាំងឲ្យអស់ជាបន្ទាន់ តាមភូមិ តាមសហករណ៍ តាមសហជីព ខ្មាំងនៅច្រើនណាស់" ហត្ថលេខាសមមិត្តយាង ។

ដានីៈ សមមិត្តអី?

ហឿនៈ សមមិត្តយាង ។

ដានីៈ មិត្តខៀវ ឬក៏មិត្តយាង?

ហឿនៈ យាង ។ ឃើញគេដាក់"ង" ។

ដានីៈ "យ" ដាក់ "ា", "ង" ។

ហឿនៈ ហត្ថលេខាសមមិត្តយាង គណៈមន្ទីរ៨៧០ ខ្ញុំឃើញតែប៉ុណ្ណឹង ហើយមានទាន់ណាគេធ្វើអី...ដូចសារាចរណ៍ យួនចូលព្រឹប ថ្ងៃ៣១ចូលដល់ជប់ ។

ដានីៈ ដល់កន្លែងហ្នឹង យើងអត់ទាន់បានចាប់អី?

ហឿនៈ អត់មានធ្វើអីបានទេ មានទាន់បានធ្វើអីទេ ខ្ញុំអី ។

ដានីៈ តាជឹមទៅដល់ហ្នឹង ក៏គាត់អត់ទាន់បានធ្វើអីដែរ?

ហឿនៈ អត់បានធ្វើអីទាំងអស់ហ្នឹង គ្រាន់តែធ្វើមេទ្ទិញតែម្តងហើយបែករហូត?

ដានីៈ ហើយចុះមានជម្លៀសប្រជាជនអីចេញពីហ្នឹង ឲ្យមកខាង?

ហឿនៈ ជម្លៀសមកពេញទន្លេបិទ ឡានហោះយួនមកទម្លាក់អាធុងសាំងធំៗមូលៗ កប់ៗប្រវេតប្រវ៉ាត់ឆេះផាប់ប្រជាជន...អស់រលីងនៅកំពង់ផែទន្លេបិទហ្នឹង ។

ដានីៈ ជម្លៀសមក ពីណាគេដាក់ផែនការឲ្យជម្លៀសប្រជាជនចេញពីខាងនោះមក ។

ហឿនៈ កាលហ្នុឹង តាជឹមគាត់អត់ទ័ព ឃើញទ័ពនាំមកដល់ទន្លេបិទ ។

ដានីៈ អីចឹងមិនមែនតាជឹម មិនមែនអីអ្នកបញ្ជាឲ្យជម្លៀសទេ ខាងកងទ័ពទេ?

ហឿនៈ អត់ទេ! តាសុន សេនហ្នឹង ជម្លៀសតាំងពីព្រំដែនស្វាយរៀង ស្វាយអីមក ។

ដានីៈ	កាលហ្នឹងតាសុន សេន គាត់នៅឯណា?

ហឿនៈ	កាលហ្នឹង គាត់នៅស្រុកត្បូងឃ្មុំ នៅទីតាំងគាត់ធំនៅហ្នឹង ។

ដានីៈ	ត្បូងឃ្មុំនៅស្វងអីចឹង?

ហឿនៈ	នៅស្វងត្បូងឃ្មុំ កន្លែងគាត់នៅត្បូងឃ្មុំ ។

ដានីៈ	តា សុន សេន គាត់ធ្វើអីកាលហ្នឹង?

ហឿនៈ	គណៈភូមិភាគដដែរហ្នឹង ។

ដានីៈ	គណៈភូមិភាគណា?

ហឿនៈ	កាលហ្នឹងនៅកំពង់ចាម ភូមិភាគបូព៌ាហ្នឹង ប៉ុនគាត់ដាក់ឈ្មោះគាត់ គណៈមន្ទីរ៨៧០ ហើយគាត់ចេញសារាចរណ៍ឲ្យគេសម្ងាប់ ។

ដានីៈ	គាត់មិនមែនមេទ័ពទេ?

ហឿនៈ	អត់ទេ! អត់ទ័ពទេ ខាងស៊ីវិលទេ ។

ដានីៈ	ពីណាគេអគ្គបញ្ជាការទ័ពកាលហ្នឹង មេទ័ពធំ?

ហឿនៈ	កាលហ្នឹងឈ្មោះ តាពីន ។

ដានីៈ	តាពីន ហ្នឹង!

ហឿនៈ	តាពីនហ្នឹង សមាជិកភូមិភាគដង កងពលធំដង ។

ដានីៈ	កងពលលេខប៉ុន្មាន?

ហឿនៈ	អត់ដឹង! គ្រាន់តែទៅដល់អត់ដឹង ។

ដានីៈ	ដឹងថា តាពីន ហ្នឹង គាត់សមាជិកភូមិភាគ ហីកងពលធំ! ហីលេខាភូមិភាគ?

ហឿនៈ	លេខាភូមិភាគមាន តាសុន សេន ។

ដានីៈ	ហើយអនុ?

ហឿនៈ	កាលហ្នុំងមានពីរនាក់ តាកែ ពក ហ្នុំងមិនដឹង បែបអនុ តាសុន សេន ហ្នឹងទេ ព្រោះ គាត់គណៈភូមិភាគបូព៌ាហ្នឹង តាកែ ពក ហើយបានតា សុន សេន គាត់ធំជាងណា ។

ដានីៈ	ហើយចុះ តាជឹម?

ហឿនៈ	តាជឹម ជាប់សមាជិកភូមិភាគហ្នឹងដែរ ប៉ុនគាត់ជាគណៈក្រសួង ជប់ហ្នឹងដងចម្ការអណ្តូង ហ្នឹងដង វា២កន្លែង ។

ដានីៈ	ចម្ការអណ្តូងមកខាងណោះវិញ?

ហឿនៈ	បាទ!

ដានី៖	ក្រែងឈ្មោះ កេត ហៅ ឆន ហ្នឹង គាត់ធ្វើគណៈនៅ...?

ហឿន៖	នៅចម្ការកៅស៊ូចម្ការអណ្តូង ។ តាជីមចេញទៅចាត់តាំង តាឆន ហៅ កេត ហ្នឹង ។

ដានី៖	អ៊ីចឹងពេលទៅដំបូង អ៊ំអីទៅចម្ការអណ្តូង?

ហឿន៖	ខ្ញុំអត់ទៅដល់ហ្នឹងទេ ។

ដានី៖	តាជីមទៅហ្នឹង?

ហឿន៖	ទៅនៅចម្ការអណ្តូងហ្នឹងបានប៉ុន្មានខែហ្នឹង ដល់មានបញ្ហា តាកុយ ធួន អីមានបញ្ហា បាន គេធ្វើបាញ់ស្លាប់រត់ចូលព្រៃអស់ទៅ គេយកតាជីមហ្នឹងពីចម្ការអណ្តូងមកនៅជប់នេះ វិញ ។

ដានី៖	អ៊ីចឹងតាជីម គាត់ទៅមុនអ៊ំ?

ហឿន៖	ទៅមុនៗ! ទៅមុនជិតមួយឆ្នាំ ។

ដានី៖	ទៅមុនជិត១ឆ្នាំ?

ហឿន៖	បាទ!

ដានី៖	អ៊ីចឹងទៅមុនជិត១ឆ្នាំ តាជីមទៅមុនហ្នឹង គាត់ទៅនៅឯចម្ការអណ្តូង?

ហឿន៖	នៅចម្ការអណ្តូង ។

ដានី៖	ហើយទៅនៅចម្ការអណ្តូងពេលដែលខែ៨ ឆ្នាំ៧៨ គាត់ទៅជប់?

ហឿន៖	ទៅនៅជប់ ។

ដានី៖	ទៅនៅជប់ហ្នឹង អ៊ំទៅនៅ គាត់ទៅនៅជប់?

ហឿន៖	កាលគាត់ទៅនៅជប់ហើយ ខ្ញុំអត់ទាន់ទេ ដល់តាម៉ុកឲ្យគេរកកំលាំងក្នុងត្រាំកក់ហ្នឹងឲ្យបាន ២០០នាក់យកទៅគ្រប់គ្រងនៅចម្ការកៅស៊ូជប់ហ្នឹង មាន៩មូលដ្ឋាន ៩ស្រុកដែរ ។

ដានី៖	ពេលតាម៉ុកឲ្យរកចឹងពីណាឲ្យរក តាជីម ឬក៏?

ហឿន៖	គ្រប់ឃុំ សុំគេតាមឃុំ ដល់បាន គេរាយការណ៍ទៅតាម៉ុក តាម៉ុកឲ្យឡានមកដឹកយកទៅ ហើយខ្ញុំសុំគេទៅ គេអត់ឲ្យទៅ ខ្ញុំលួចឡើងឡានរត់ទៅ ។

ដានី៖	ពីណាគេអត់ឲ្យទៅ?

ហឿន៖	សុំចៅហ្វាយស្រុកតាអួចនេះ កាលហ្នឹងគាត់មកនៅស្រុកហ្នឹងហើយ សុំអត់ឲ្យទេ ថាហែ្វង ទៅ អញបានអាណា អញពឹងហែ្វង ហ្វែងទៅចោលអញ អញធ្វើម៉េច ។ គាត់អត់ឲ្យទៅ អត់ឲ្យទៅ ខ្ញុំលួចឡើងឡានទៅដែរ ។

ដានី៖	ទៅមួយគ្រួសារអ៊ីម៉ង?

ហឿនៈ ទៅមួយគ្រួសារខ្ញុំ ។

ដានីៈ តាជឹម កាលហ្នឹងគាត់ស្មើរអីឲ្យទៅ?

ហឿនៈ អត់ទេ! ខ្ញុំលបរត់ទៅក្រោយ ។

ដានីៈ អីចឹងតាជឹម គាត់ទៅតាំងពីឆ្នាំ៧០ប៉ុន្មានទៅ?

ហឿនៈ ៧៦ គាត់ទៅនៅចម្ការអណ្ដូងហ្នឹងហើយ ដល់៧៨គាត់ចេញពីចម្ការអណ្ដូងគាត់ចាត់តាំង គេឲ្យនៅជំនួសគាត់ហើយ គាត់ទៅជប់ទៅ ។

ដានីៈ អីចឹងតាជឹមទៅតាំងពីជំនាន់ជាមួយតាអាន តាអី?

ហឿនៈ ហ្នឹងហើយ! ទៅជាមួយតាអាន យាយថែម យាយ យុត, តាទិត ជំនាន់ហ្នឹងយាយ ថែម តាទិត ។

ដានីៈ យាយថែម តាទិត គាត់មកនៅខាង?

ហឿនៈ មកនៅខេត្តបាត់ដំបង យាយថែមនៅស្រុកណាទេ អត់ចាំទេ ។

ដានីៈ ហើយតាជឹម ត្រកូលគាត់ឈ្មោះអី?

ហឿនៈ ត្រកូលគាត់ឈ្មោះព្រាប ។

ដានីៈ ព្រាប ជឹម?

ហឿនៈ ប៉ុន្តែទៅនៅចម្ការកោស្ទូគេហៅថា តាផាន់ៗ ។

ដានីៈ តាផាន់?

ហឿនៈ បាទ!

ដានីៈ នៅចម្ការកោស្ទូគេហៅគាត់ តាផាន់ៗ វិញ?

ហឿនៈ បាទ! អត់មាននាមត្រកូលទេ ។

ដានីៈ ប្រពន្ធក្រោយគាត់នៅហ្នុង អត់ដឹងឈ្មោះអី?

ហឿនៈ អត់ទេ! ដឹងនៅកំពង់ចាម អត់ដឹងឃុំស្រុកណាទេ ។

ដានីៈ ដល់ពេលអ៊ីទៅជប់អី ទៅជួបគាត់ គាត់រាក់ទាក់អ៊ីហោ?

ហឿនៈ តាជឹមហ្នឹង?

ដានីៈ បាទ!

ហឿនៈ អត់អីទេ ដូចបងប្អូននៅពីដើមអីចឹង ។

ដានីៈ អ៊ីទើបតែឈ្លោះជាមួយគាត់ពេល...?

ហឿនៈ ឈ្មោះចូលព្រៃ គាត់រកសម្លាប់ខ្ញុំ ពេលខ្ញុំអត់ឯកភាព គាត់សម្លាប់គេ ខ្ញុំថាកុំសម្លាប់គេ ខ្ញុំអត់ឯកភាពទេ គេមកស្រុកគេប្រពន្ធអត់មានស្គាល់នរណាម្នាក់ គេបេះប្រពន្ធគេចេញពីទ្រូង គេរត់មកតាមយើង គេយកយើងធ្វើម៉ែធ្វើឪហើយ បានគេមក ហីសម្លាប់គេ ខ្ញុំអត់ពេញចិត្តទេ ។ កន្ទ្រប់ដីស្រែកញ៉ាំងដូចដីអីចឹង ហីគេថាអីចឹងហើយបានអញអត់យកឯងមក សុំមកក៏អត់ទៅ វាថាតាំងពីហ្នឹងមក ។

ដានីៈ ចុះគាត់ កាលគាត់មកដំបូង ទៅ៧៦ អ៊ីសូមគាត់ទៅជាមួយដែរ?

ហឿនៈ កាល៧៦ហ្នឹង គាត់ឲ្យគេហៅខ្ញុំ ហីឲ្យអានិរសាគាត់ហៅ ហីខ្ញុំថា អញមិនដឹងទៅម៉េចទេ បើគេទៅគេអត់ហៅអត់ប្រាប់អីចឹង អញអត់ទៅទេ ហីមិនដឹងថាអាហ្នឹងតាហ្នឹងប្រើឲ្យមកហៅឯណា ខ្ញុំអត់ដឹង ហីដល់គាត់ចេញមកនៅចម្ការតស៊ូ គេរកមនុស្ស២០០នាក់ បានខ្ញុំលួចឡើងឡានទៅ សុំគេ គេអត់ឲ្យទៅ ។

ដានីៈ តាអួចអត់ឲ្យទៅ?

ហឿនៈ អត់ឲ្យទៅ គាត់ថាហែងទៅ អញនៅជាមួយអាណា អញបានអាណាធ្វើការជាមួយ នៅតែឯង ។

ដានីៈ ចុះអ៊ីកាលពីម្សិល អ៊ីនិយាយពីរឿងប្រវត្តិព្រះអង្គម្ចាស់ជារាដេប៉ូ កាលហ្នឹងអ៊ីដឹងយ៉ាងម៉េចខ្លះទាក់ទង...?

ហឿនៈ ខ្ញុំដឹង! ខ្ញុំនៅសាលាស្រុកត្រាំកក់ ផ្ទះថ្មគេដុតឆេះបាញ់ខ្ទេចអស់ហើយ ដល់ខ្ញុំនៅវត្តធម្មយុត្តខាងលិច ប្រហែល១០០ម៉ែត្រហ្នឹង ។

ដានីៈ ១០០ម៉ែត្រពីសាលាស្រុក!

ហឿនៈ ១០០ម៉ែត្រពីផ្សាររួមស្រុកហ្នឹង ដល់អីចឹង ស្អែកឡើង ព្រឹកឡើងខ្ញុំចេញមកកន្លែងផ្លូវបំបែក នៃទីរួមស្រុកចាស់ហ្នឹងណា ឃើញបាចត្រាក់ពេញដី បាចក្រាក់ខ្ញុំទៅលើកមើលឃើញព្រះអង្គម្ចាស់ជារ៉ាដេប៉ូ អំពាវនាវឲ្យប្រជាពលរដ្ឋ នៃគាំទ្រសម្តេចសីហនុ ។

ហឿនៈ ឆ្នាំណាហ្នឹង?

ដានីៈ អាហ្នឹង៧៦!

ហឿនៈ ៧៦បាចត្រាក់ពេញវាលហ្នឹងទាំងអស់ ។

ដានីៈ ៧៦ពេលរំដោះទីក្រុងភ្នំពេញហើយ ឆ្នាំ៧៥ហើយហ្នឹង?

ហឿនៈ រំដោះហើយ! ៧៦ហើយហ្នឹង ។

ដានីៈ ៧៦នៅត្រាំកក់ហ្នឹង?

ហឿនៈ បាទ!

ដានីៈ ជិតវត្តធម្មយុត្ត?

ហឿនៈ ក្នុងស្រុកត្រាំកក់ចាស់នៅផ្សារអង្គតាសោម មុខផ្សារអង្គតាសោមហ្នឹង សាលាស្រុកចាស់ ។

ដានីៈ បាទ! ដល់ទៅមើលត្រាក់ហ្នឹង ដាក់ព្រះអង្គម្ចាស់ដារ៉ាដេប៉ូឲ្យគាំទ្រសម្ដេចសីហនុ!

ហឿនៈ ហ្នឹងហើយ ឲ្យគាំទ្រសីហនុ ។

ដានីៈ ហើយម៉េចទៀតទៅអ៊ី?

ហឿនៈ ភ្លេចអស់ហើយ មើលបានតែ២, ៣មាត់ អត់សូវហ៊ានមើល ដល់ហើយគេឲ្យពួកយុវជនស្រុកទៅរើសដុតចោលអស់ទៅ អត់មានយកអីមួយ ។

ដានីៈ ហើយម៉េចទៀតទៅ?

ហឿនៈ ហើយពីហ្នឹងទៅខ្ញុំអត់ដែលដឹងគាត់នៅណាអីណាទៅណាទេ ដល់តែខ្ញុំទៅជប់ហ្នឹង ដល់ទៅជប់ហ្នឹងខែ៩ គាដឹមហ្នឹងឲ្យខ្ញុំមករៀនសាលាភូមិភាគ គាកែ ពក ហ្នឹង ។

ដានីៈ នៅឯណា?

ហឿនៈ កំពង់ចាម ។

ដានីៈ មករៀននៅសាលាភូមិភាគជាមួយ កែ ពក!

ហឿនៈ មករៀននៅសាលាភូមិភាគនៅកំពង់ចាមក្បែរមាត់ទឹក ហីដល់អីចឹងខ្ញុំទៅជួប គាស៊ី ទៅពីស្រុកជាមួយគ្នា ។

ដានីៈ គាស៊ី ថាទៅគណៈស្រុកកំពង់សៀមហ្នឹង?

ហឿនៈ ហ្នឹងហើយ គណៈស្រុកកំពង់សៀមហ្នឹង គាត់ថាអើយ អញពិបាកព្រះអង្គម្ចាស់ដារ៉ាដេប៉ូ គេយកឲ្យអញជួយវែកដី ឲ្យវែកដីមិនវែក ដាំបាយឲ្យស៊ីស្លត្រកួនឲ្យស៊ីគេអត់ស៊ី អញសែងចុះសែងឡើងអត់ដើរទៀត ទៅណាសែងៗអញពិបាកអញ វាយចោលបាត់ ។ វាយចោលហ្នុង ឆ្នាំហ្នុងគាត់និយាយដឹងខែណា!

ដានីៈ គេវាយចោលឆ្នាំណា?

ហឿនៈ អត់ដឹងទេ! គាត់ជួបខ្ញុំខែ៩, ៧៨ ។

ដានីៈ ប៉ុន្តែបើតាមមើលគេវាយចោលមុនហ្នឹង មុនខែ៩,៧៨?

ហឿនៈ គេវាយពីមុនហ្នឹងទៀត បានទៅជួបគេនិយាយប្រាប់ ។ ដល់ឡើងក្នុំដងវែកជួប គាស៊ីហ្នឹងទៀតទៅនិយាយអាហ្នឹងដដែលទៀត ។

ដានីៈ គាត់និយាយថាម៉េចទៀត?

ហឿនៈ និយាយថា ពិបាកចិត្តដែល ដារ៉ាដេប៉ូ ដើរមិនដើរ បាយទឹកឲ្យស៊ីមិនស៊ី ទៅណាសែង ទៅណាសែងគាត់ពិបាក គាត់វាយចោល ។

ដានីៈ វាយចោលនៅឯណាគាត់មានប្រាប់ទេ?

ហឿនៈ អត់ដឹងទេ! នៅស្រុកកំពង់សៀម ខ្ញុំនៅត្រាំកក់នេះអត់ដឹងទេ... ។

ដានីៈ ឈ្មោះតាស៊ី អោក ស៊ី ហ្នឹង អ្នកវាយ?

ហឿនៈ ដឹងគាត់អ្នកវាយ ឬក៏គាត់ប្រើគេ!

ដានីៈ គាត់ថាម៉េច ដារ៉ាដេប៉ូ ទៅណាប្រើគេឲ្យសែង?

ហឿនៈ ទៅណាមកណាសែងអត់ដើរ បាយឲ្យហូបអត់ហូប បាយសម្លត្រកួនសម្លព្រលិតអី គាត់ អត់ចេះហូប គេថាដឹងចិញ្ចឹមម៉េច បើឲ្យវែកដីក៏អត់វែក ឲ្យធ្វើអីក៏អត់ធ្វើ គាត់ខ្ជិលទុក គាត់លួចសម្លាប់ចោលបាត់ ។

ដានីៈ តាស៊ី?

ហឿនៈ បាទ! អាហ្នឹងខ្ញុំចាំពាក្យគាត់ប្រាប់ខ្ញុំ២ដង ។

ដានីៈ គាត់ប្រាប់២ដង ប្រាប់មួងខែ៩ ឆ្នាំ៧៨ពេលអឹមករៀនជាមួយ កែ ពក!

ហឿនៈ ៧៩ ខែ៨ មកជួបគ្នានៅកំពង់ចាម គាត់និយាយប្រាប់ ។

ដានីៈ ចុះអឹនៅខាងបូព៌ា ម៉េចមករៀនសូត្រជាមួយ កែ ពក នៅភូមិភាគកណ្តាលវិញ?

ហឿនៈ កាលហ្នឹងនៅជប់ខែ៩ហ្នឹង ។

ដានីៈ ប៉ុន្តែតា កែ ពក គាត់នៅខាងកណ្តាលទេ?

ហឿនៈ អត់មានមកនៅតាកែវទេ នៅរៀនសាលាភូមិភាគខេត្តកំពង់ចាមហ្នឹង ។

ដានីៈ បាទ! កំពង់ចាម ខេត្តហ្នឹងយើងឆ្លងទន្លេមកមួយចំហៀង?

ហឿនៈ ឆ្លងពីទន្លេបិទមក!

ដានីៈ ក្រែងមួយចំហៀងពីខាងណុះភូមិភាគបូព៌ា ខាងកើតទន្លេណា?

ហឿនៈ ភូមិភាគបូព៌ា! ប៉ុន្តែ តាកែ ពក ហ្នឹងនៅគ្រប់គ្រង់ក្រុងកំពង់ចាមហ្នឹង ។

ដានីៈ បាទ! ប៉ុនអីចឹង តាកែ ពក ហ្នឹងគាត់កាន់២អីចឹង?

ហឿនៈ ដឹងអាម៉េចទេ បើអត់សួរដឹងដែរ ។

ដានីៈ នៅភូមិភាគបូព៌ាផង ហីហ្នឹងភូមិភាគកណ្តាលផង?

ហឿនៈ អត់ទេ!

ដានីៈ ភូមិភាគខគួរ?

ហឿនៈ ភូមិភាគខគួរគេផ្សេង, ភូមិភាគបូព៌ាតាកែ ពក ហីហ្នឹងតាសុន សេន នៅប្រចាំការនៅហ្នឹង ។

ដានីៈ អ៊ូៗ! បាទយល់ហើយអ៊ឹ ។ អីចឹងពេលមករៀនហ្នឹង តាស៊ី គេនិយាយប្រាប់?

ហឿនៈ និយាយប្រាប់ខ្ញុំម្តង ឡើងភ្នំដងរែកឆ្នាំ៨០ ៃ២៨ គាត់និយាយប្រាប់ម្តងទៀតទៅជួបគ្នានៅលើភ្នំ ។

ដានីៈ គាត់គ្រាន់តែប្រាប់ថា ពិបាកពេកវាយចោលទៅ?

ហឿនៈ ពិបាកសែង ពិបាកឲ្យបាយហូប ឲ្យធ្វើការអត់ធ្វើ ។

ដានីៈ នៅកំពង់សៀមហ្នឹង?

ហឿនៈ បាទ!នៅស្រុកកំពង់សៀមហ្នឹង ប៉ុនដឹងគេសម្លាប់ណាអីណា គេគ្រាន់តែនិយាយអត់ប្រាប់កន្លែងសម្លាប់ទេ ។

ដានីៈ ខ្ញុំចង់ដឹងរឿងហ្នឹងច្រើនដែរ! បើចង់ដឹងរឿងហ្នឹង ទាល់តែជួប តាស៊ី ណ៎?

ហឿនៈ តាស៊ី មិនដឹងនៅរស់ ឬក៏ងាប់ ប៉ុនបែកគ្នាមកគាត់នៅក្មេង ប្អូនខ្ញុំទៀត ។

ដានីៈ ប៉ុន តាស៊ី ស្រុកកំណើតគាត់នៅឯណា?

ហឿនៈ នៅព្រៃញ៉ង មិនដឹងភូមិអីទេ ដឹងថាឃុំព្រៃញ៉ងហ្នឹង ហីបងគាត់តាអ៊ីនោះក៏នៅព្រៃញ៉ងហ្នឹងដែរ ។

ដានីៈ តាស៊ី មានបងប្រុសឈ្មោះ តាអ៊ី ។

ហឿនៈ សុទ្ធតែ អោក អ៊ី, អោក ស៊ី ទាំងអស់ ។

ដានីៈ អោក អ៊ី! តាស៊ី មានបងប្រុសឈ្មោះ អ៊ី នៅឃុំព្រៃញ៉ង ។

ហឿនៈ ប៉ុនខ្ញុំថានៅអន្លង់វែងហើយ អត់ទៅស្រុកទេ!

ដានីៈ ប៉ុន្តែយើងគ្រាន់តែចង់ដឹង បើចង់ដឹងគាត់យើងទៅរកពីស្រុកមក ថានៅរស់អី! ឪពុកម្តាយគាត់ កូនតាអោក ឬឪពុក?

ហឿនៈ ដឹងតាគាត់ ឬក៏ឪគាត់ បើអត់ស្គាល់ដែរ ។

ដានីៈ បើអាចទៅសួររក ទៅសួរនៅម្តុំណា នៅព្រៃញ៉ង អាចស្គាល់?

ហឿនៈ ព្រៃញ៉ង! សួរក្នុងឃុំព្រៃញ៉ង ។

ដានីៈ ប៉ុន្តែសួរនៅក្នុងភូមិណា ម្តុំណា?

ហឿនៈ អត់ដឹង, ដឹងគាត់នៅភូមិណាអត់ដឹង ដឹងតែគាត់នៅឃុំព្រៃញែង ខ្ញុំទៅជួបគាត់ប៉ុន្មានដង ឃើញតែគាត់នៅឃុំព្រៃញែងហ្នឹង ។

ដានីៈ នៅសាលាឃុំហ្នឹងតែម្តង?

ហឿនៈ បាទ! ទៅជួបតែកន្លែងសាលាឃុំគាត់ ។

ដានីៈ គាត់ធ្លាប់ធ្វើគណៈឃុំនៅហ្នឹង ឬក៏អី?

ហឿនៈ នៅ! នៅតាំងពីឆ្នាំ៧០មក ។

ដានីៈ អីចឹងទៅសួរហ្នឹងថា តាស៊ី គាត់ធ្លាប់ធ្វើគណៈឃុំហ្នឹង គេស្គាល់ហើយណ៎?

ហឿនៈ ស្គាល់ទាំងអស់ ឪគាត់យកមកទុកដូវបំបែកគូស ។

ដានីៈ ឪគាត់ថី?

ហឿនៈ អត់ស្គាល់ឈ្មោះទៀត ។

ដានីៈ បាទ! អឺ ។ ចុះហេតុអីបានជា តាម៉ុក គាត់បញ្ជូនអ្នកតាកែវ ដូចថាទៅខាងកំពង់ចាម ទៅកន្លែងផ្សេងៗអីចឹង អឹដឹងថាមូលហេតុអីបានគាត់បញ្ជូនទៅ?

ហឿនៈ រឿងហ្នឹងចេះ គេយកតែកំលាំងគេហៅថាឃុំមូលបង្អែក ស្រុកមូលបង្អែក បង្អែករបស់ខ្មែរក្រហម ម្លោះហើយគេចម្រាញ់ចេញតែពីហ្នឹងទៅគ្រប់ខេត្ត គ្រប់ស្រុកទាំងអស់ យកតែពី១០៥ហ្នឹង ។

ដានីៈ ១០៥ហ្នឹង គេហៅថាស្រុកបង្អែក?

ហឿនៈ ហ្នឹងហើយ ស្រុកបង្អែករបស់តាម៉ុក មានភូមិមូលដ្ឋានបង្អែករបស់តាម៉ុក ត្រពាំងគល់ ត្រពាំងប្រើយ៍ហ្នឹង សរុបរួមទាំងឃុំ ទាំងស្រុកទៀត ។ ស្រុកមូលដ្ឋានបង្អែក ចុះបើ៧០ មកអត់ដែលទាហាន ដែលស្ទីឡើងទៅដល់ទេ ទ័ពពេញទាំងអស់ ។

ដានីៈ តាម៉ុកអ្នកចាត់ចែង ឬក៏តាប៉ុល ពត, តានួន ជាអីគាត់ម៉េច មានដឹង?

ហឿនៈ ចាត់ចែងនៅកន្លែងណា?

ដានីៈ ឧបមាថាពេលដែលថ្នាក់អ្នកដឹងនាំ ចេញពីខាងស្រុកត្រាំកក់ ខាងស្រុកតាម៉ុកអីទៅទាំងអស់ម៉ាស្រុកសោះ យើងទៅដឹកនាំទូទាំងប្រទេស ។

ហឿនៈ អត់ទេ! អាហ្នឹងតែទៅនៅស្រុកណា បើថាមេឃុំ មេស្រុកហ្នឹងគេទៅពីត្រាំកក់ដូចគ្នា គេចាត់ចែងអ្នកមេឃុំហ្នឹងទៅ ។ ដូចតាជឹមទៅពីត្រាំកក់ហ្នឹងទៅ ទៅដល់ តាពក នៅពីលើ តា សុន សេន នៅពីលើ គេចាត់ចែងទៅ អត់មាន តាម៉ុកទេ តាម៉ុកគាត់ដើររះពេញដីពេញប្រទេស ។

ដានី៖ ប៉ុន្តែក្រែងតាម៉ុក គាត់អ្នកបញ្ជូនឲ្យទៅ ឬអត់ទេ?

ហឿន៖ បញ្ជូនឲ្យទៅ យកទៅបំពេញបន្ត្រប់កំលាំងដែលគេបាត់បង់ហ្នឹង ។

ដានី៖ ប៉ុន្តែអ៊ីមានដឹងថា តាម៉ុក អ្នកបញ្ជូនទៅ តាម៉ុកមាននិយាយប្រាប់ថាម៉េច ថាយើង...?

ហឿន៖ គ្រាន់តែសុំកំលាំង១០០ ដល់ប្រមូល៤, ១០ថ្ងៃបាន រាយការណ៍ទៅថាបានកំលាំងបានគ្រប់ហើយខ្លះប៉ុន្មាននាក់ៗអីចឹងទៅ ហើយគាត់ថា អីចឹងបើបានអញយកឡានទៅដឹក គាត់និយាយតែប៉ុណ្ណឹង យកឡានទៅដឹកយកទៅប្រគល់ដល់កន្លែងដែលត្រូវទៅហ្នឹង តាម៉ុក អត់ដែលទៅប្រជុំ អត់ដែលទៅរៀនសូត្រអី អត់ដែល... ។

ដានី៖ ប៉ុន្តែបើតាមអ៊ីដឹង ដោយសារតែនៅស្រុក១០៥ហ្នឹងជាមូលដ្ឋានបង្អែករបស់ តាម៉ុក បានគេបញ្ជូនឲ្យទៅដឹកនាំច្រើន?

ហឿន៖ ទៅតែពីស្រុកត្រាំកក់ហ្នឹង ទៅទាំងអស់គ្រប់ខេត្តទាំងអស់ ។

ដានី៖ អីចឹងទាំងក្មេងស្រី ក្មេងប្រុស ទាំងចាស់ធំអី សុទ្ធតែមានតួនាទីហើយកាលហ្នុង?

ហឿន៖ កាលហ្នឹងអត់ទេ! មិនមានទេ ទាល់តែបញ្ចេញទៅបានដល់ស្រុកគេបានមានតួនាទី បើថានៅស្រុកនេះអត់មានអី ។

ដានី៖ បាទ! នៅស្រុកនេះប្រជាជនធម្មតា នៅផ្ទះធម្មតា ប៉ុន្តែដល់ពេលគេបញ្ជូនទៅ ដឹងថាអ្នកដែលបញ្ជូនពីត្រាំកក់ទៅកាន់ស្រុកភូមិផ្សេងៗដឹងតែមានតួនាទីហើយណ៎?

ហឿន៖ កាលទៅពីផ្ទះអត់មានអីទេ ដល់ទៅដល់នោះលែងដឹងហើយ សុទ្ធតែបើថាមេឃុំទៅដល់នោះឡើងស្រុកហើយ តែប៉ុណ្ណឹងទេ គេចាត់តាំងកន្លែងគេហ្នុងទៀត ហីទៅមហាជន ទៅដល់នោះចូលជនបង្គោល ជនសម្ព័ន្ធស យុវកកអីគេ គេចាត់តាំងនៅនោះហើយ អាហ្នឹងតាម៉ុកលែងដឹងហើយ ។

ដានី៖ តាម៉ុកអត់ដែលទៅខាងហ្នុងទេ?

ហឿន៖ អត់ទេ! ទៅជួបតាសុន សេន ទៅជួបតែញឹក ទៅប៉ុន្តែគាត់អត់ចូលទៅកម្មករជប់ជង ។

ដានី៖ ចុះអ៊ីបាទ! ខ្ញុំចង់សួរអ៊ីទាក់ទងហ្នឹងជីវិត ក្រោយពេលដែលយួនចូល ឆ្នាំ៧៩ ពេលហ្នឹងយ៉ាងម៉េចដែរអ៊ី? ដូចថាជីវិតអ៊ី គ្រួសារអ៊ីអ៊ីយ៉ាងម៉េចរត់អីឆ្ងងកាត់ ហើយជួបពីណាខ្លះអីដែរកាលហ្នឹង?

ហឿន៖ រត់ៗសំដៅព្រៃអត់មានជួបណាទេ គ្រាន់តែដឹងថាយួនចូលដល់ភ្នំពេញហើយតាជីមហ្នឹងរំសាយកំលាំងថាបងប្អូនណាផ្ទះណាទៅហ្នឹងទៅឡានហ្នឹងយកជិះទៅ ឡានចែកម្នាក់មួយៗ

យកទៅហើយ មាននរណាយកឡាន ឡាននៅគេចោលនៅកំពង់ថ្ម ស្រុកសន្ទុកហ្នឹង នៅទាំងអស់ ឡានរាប់ពាន់ ឲ្យយកឡានក៏អត់យកដែរ ដើររត់ ។

ដានី: ៧៩ហ្នឹង ពេលយួនចូលមក តាជឹមគាត់ប្រជុំរំសាយអង្គភាពហើយអីចឹង?

ហឿនៈ អត់បាច់ប្រជុំទេ គ្រាន់តែពួចឹង ភ័យតក្កមា ដើរប្រកាសថាបងប្អូនទាំងអស់យើងត្រូវរំសាយកំលាំងទាំងអស់ បងប្អូនណាទៅស្រុកណានៅណាទៅកន្លែងហ្នឹង ហើយឡានហ្នឹងចេះតែយកជិះៗទៅ ឡាននៅគរពេញស្រុកសន្ទុកហ្នឹង នៅកំពង់ថ្មហ្នឹង អត់មាននរណាគេយកឡាន ។ ហើយកម្មករជម្លៀសមកនៅណែនដី រត់ចោលកម្មករទៅចូលព្រៃ ។

ដានី: ដល់ពេលចឹងអ៊ីម៉េចទៅ ដល់ពេលថាចឹងអ៊ីយ៉ាងម៉េច អ៊ីភៀសខ្លួនអីទៅណា ទៅណាខាងណាៗ ចេញពីទីណាទៅណា?

ហឿនៈ ខ្ញុំយំអត់ចេញទឹកភ្នែក! ដល់ខ្ញុំទៅតោងឡាន តា ជឹម ហ្នឹង គេថាអត់ឲ្យទៅទេ ចុះបែកកង់ឡានអញ! ហ៊ីខ្ញុំដឹងចុះទៅណា ហ៊ីប្រពន្ធខ្ញុំគេឡើងឡានជាមួយប្រពន្ធតា ជឹម ហ្នឹងទៅបាត់ហើយ ខ្ញុំបែកត្រឹមហ្នឹងហើយ! ជិះឡានទៅដល់ស្រុកសណ្ដាន់ ខេត្តកំពង់ធំ បានជួបយាយខ្ញុំទៀត ជួបគេឲ្យមកផ្ទះទៀត ហើយខ្ញុំថា ខ្ញុំអត់ទៅទេ ខ្ញុំខ្លាចយួនធ្វើបាបគេថាពុះដើមស្វាធ្វើគ្រាប់តអាំងលើប្រឡាយ ។

ដានី: ថាម៉េច?

ហឿនៈ គេថា យួន ពុះគ្រាប់តដើមស្វាធ្វើអាំងមនុស្សលើប្រឡាយ ។

ដានី: ពីណាអ្នកនិយាយអីចឹង?

ហឿនៈ ប្រជាជនអ្នករត់ថាអីចឹង ថាទាំងអស់យាយខ្ញុំក៏គេថាអីចឹងក៏រត់ដូចគ្នាហ្នឹង ។

ដានី: អីចឹងយកដើមស្វាហ្នឹងធ្វើគ្រាប់តអាំងមនុស្សនៅលើប្រឡាយ?

ហឿនៈ បាទ! គេថាពុះគ្រាប់តអាំង ។

ដានី: ដល់ពេលអីចឹងគេថាគ្រប់គ្នាអីចឹង ឬមេៗធំៗអ្នកប្រាប់?

ហឿនៈ អត់មានមេទេ អ្នករត់ដូចគ្នាហ្នឹង អ្នករត់ទៅគេថាតែអីចឹង ថាគេតម្រង់ជួរហើយយួនពុះគ្រាប់តដើមស្វាអាំងហើយ គេចេះតែថា មេរត់ មេអត់មានថា ។

ដានី: គេថាអីចឹងអ៊ីភ័យជឿតាមគេតែម៉ង?

ហឿនៈ ខ្ញុំជឿតាមគេរត់ទាំងអស់ម៉ាស្រុកគ្រាំកក់អត់មានពីណាទៅផ្ទះមួយ ចូលព្រៃទៅផាប់គរដើងពេញព្រៃដាច់បាយដាច់ទឹក ។

ដានី: បើសិនជាកុំរត់ក៏អត់មានអីដែរ?

ហឿនៈ អត់មានពីណាធ្វើអី នៅតាមួយនៅប្រមូលសំភារៈសហករណ៍ដាក់ពេញផ្ទះ យួនមកអត់ធ្វើអី ។

ដានីៈ អឺមួយទៀតទាក់រឿងអាចាមអារាមដែរ ខ្ញុំអត់បានដឹងច្បាស់ គេថាជិនាន់ហ្នឹង ពេលឆ្នាំយួនជិតចូល ខាងខ្មែរក្រហមគេមានផែនការប្រុងធ្វើទំបញ្ចុកអីដាក់ថ្នាំពុលអីសម្លាប់ប្រជាជន អឺមានដឹងរឿងហ្នឹងទេ?

ហឿនៈ អត់ដែលដឹងទេ អត់ដែលឮទេ ។

ដានីៈ ថាជីករណ្តៅអីសម្រាប់កប់មនុស្សកប់អី?

ហឿនៈ ហ្នឹងក៏អត់ អត់មានតែម៉ង ។

ដានីៈ ចឹងអត់ដែលឮទេ?

ហឿនៈ អត់ដែលឮទេ បើឮតែមួយថ្ងៃឮដល់ហើយ តែមួយថ្ងៃឮដល់ជប់ ដឹងម៉េចក៏លឿនម៉្លេះ ។

ដានីៈ ចឹងគ្រប់គ្នាតែម៉ងថាពុះគ្រប់គ?

ហឿនៈ បាទ! អ្នករត់ដូចស្រមោច ថាហ្នឹងអីចឹង បានជារត់ ។

ដានីៈ អឺ, អឺស្រីកូនចៅនៅជុំគ្នារហូតរត់ឡើងភ្នំអត់បែកគ្នាទេ?

ហឿនៈ រត់ពីជប់ជាមួយខ្ញុំ ជិះឡានចិន យាយខ្ញុំជិះឡានចិន ឡានចិនមាន៦០នាក់ជិះឡានយាយខ្ញុំ១០នាក់ ដល់រត់មកវានៅទទឹងផ្លូវអីចឹង រត់នៅទទឹងផ្លូវអីចឹង អាមួយនៅចំហៀងអីចេះ អាឡានចិនមកនៅពាំងផ្លូវហ្នឹង ហើយវាឡើងបើកមួកកូនខ្ញុំ កូនខ្ញុំមានគ្រាប់បែកឈើមួយគ្រាប់ គ្រាប់បែកដងឈើ វាបើកគ្រប់ដកទម្លាក់ អានៅទទឹងហ្នឹងវាវិលទៅ វិលទៅអាឡានភ្ញៀវហ្នឹងបើកគេចរត់រួច ដល់គេចរត់រួចយួនបាញ់អាឌូសេតនៅលើរថក្រោះហ្នឹង ត្រូវចិនបោះដៃផុតនេះ ។

ដានីៈ ត្រូវចិន?

ហឿនៈ ត្រូវចិន ភ្ញៀវចិន ពេទ្យទៀត ។

ដានីៈ អីចឹងកាលហ្នុងនៅជប់ហ្នឹងមានចិននៅដែរ?

ហឿនៈ មានចិន៦០នាក់ នៅធ្វើរោងចក្រ ។

ដានីៈ ដល់ពេលយួនតាមទាន់កូនអឺមានគ្រាប់បែក?

ហឿនៈ កូនខ្ញុំមានគ្រាប់បែកមួយ គ្រាប់បែកដងឈើ ។

ដានីៈ ពេលទម្លាក់គ្រាប់បែកទៅយួនរត់ទៅ?

ហឿន៖ ទម្លាក់គ្រាប់បែកវាផ្ទុះក្នុងឡានហ្នឹង ផ្ទុះក្តាំងអារថក្រោះហ្នឹងវិលទៅ វិលទៅវាលែងទៅណា អាមួយទៅមុខហ្នឹងវានៅហ្នឹង អានេះបើកជៀសគេច គេចអាខ្លះសេតវាដាក់ ។

ដានី៖ ដល់ពេលផ្ទុះគ្រាប់បែកហ្នឹងអត់មានត្រូវពីណាទេ ត្រូវរបួសអីទេ?

ហឿន៖ ផ្ទុះក្នុងរថក្រោះហ្នឹង ចូលក្នុងរត់ក្រោះ ។

ដានី៖ ទម្លាក់ចូលក្នុងរថក្រោះ?

ហឿន៖ បាទ!

ដានី៖ កូនអីយ៉ាងម៉េចបាននឹកឃើញទម្លាក់គ្រាប់បែក?

ហឿន៖ ចុះវានៅលើដំបូលឡាន ជិះលើដំបូលឡានភ្លៀវហ្នឹង ដល់ចឹងបានរត់រួច ហើយចិនហ្នឹងទៅជិះឡានហោះកំពង់ចាម ទៅដល់ទាក់ទងតាមទូរលេខសួរថាម៉េចគាត់មានកម្លាំងនៅថានៅទេ ឥឡូវដល់ណាហើយ ថាដល់ព្រំដែនចិនហើយ ថាតែប៉ុណ្ណឹងស្លាប់ ។

ដានី៖ ស្លាប់យ៉ាងម៉េច?

ហឿន៖ ចិនហ្នឹងមិនត្រូវស្លាប់ ផ្ទុះពីនេះប៉ុនណេះ ត្រូវពីនេះទៅធ្លាយនោះ គាត់អង្គុយមុខទៅនេះយួនបាញ់ពីកើត ។

ដានី៖ ត្រូវតែម្នាក់ហ្នឹងទេ?

ហឿន៖ ត្រូវតែម្នាក់ ។

ដានី៖ ឈ្មោះអីដែលត្រូវហ្នឹង?

ហឿន៖ ទៅស្លាប់លើព្រំដែនប្រទេសចិននោះ ។

ដានី៖ អ្នកត្រូវរបួសហ្នឹងគេជិះយន្តហោះពីកំពង់ចាមទៅ?

ហឿន៖ បាទ! ទៅដល់ឡើងយន្តហោះទៅ ។

ដានី៖ ទាំង៦០នាក់ហ្នឹង ឡើងយន្តហោះទាំង៦០នាក់?

ហឿន៖ ទៅទាំងអស់ ខ្ញុំថាឯងប្រឆេះឡានឲ្យភ្លៀវឡើងអស់ចាំចេញ ឲ្យយាយអញជិះហ្នឹងផងហើយខ្ញុំប្រុយទៅ ហើយអារថក្រោះហ្នឹងនឹង១១ ប៉ុងឆេះម៉ត់ ខ្ញុំរត់រួច ហីគណៈក្រសួងគាត់ គាត់ស៊ីញ៉ូភ្លើងម៉ូតូ ខ្ញុំស៊ីញ៉ូដែរ ។

ដានី៖ គណៈក្រសួង តា ជឹម ហ្នឹង?

ហឿន៖ តា ជឹម ហ្នឹងហើយ គាត់រត់មុនខ្ញុំ ។

ដានី៖ ប៉ុន្តែចិនដែលត្រូវរបួសមកឡើងជិះយន្តហោះពីកំពង់ចាមហ្នឹង មកដល់ក្រុងកំពង់ចាមហ្នឹងជិះយន្តហោះពីព្រលានយន្តហោះកំពង់ចាមហ្នឹង?

ហឿនៈ ជិះពីកំពង់ចាមហ្នឹងទៅស្រុកចិននោះ ចេញទៅដើងអីចេះ ថាតែ៥ម៉ោងទេ ។

ដានីៈ ប៉ុន្តែយ៉ាងម៉េចបានអ៊ីដឹងថា ម្នាក់ដែលត្រូវរបួសនឹងស្លាប់?

ហឿនៈ ចុះនៅជាមួយយាយខ្ញុំ ជិះឡានជាមួយយាយខ្ញុំ ។

ដានីៈ ស្លាប់ពេលដែលជិះឡានហ្នឹងទៅ?

ហឿនៈ អត់ស្លាប់ទេ ជិះយន្តហោះទៅប្រទេសចិនវិញ ទៅដល់លើព្រំដែនចិនបានគាត់ដាច់ខ្យល់ហ្នឹងទូរស័ព្ទទាក់ទងដាប់ ។

ដានីៈ ទូរស័ព្ទទាក់ទងជាមួយពីណា?

ហឿនៈ ទាក់ទងជាមួយភ្ញៀវចិនហ្នឹង ទូរស័ព្ទ តា ម៉ុក ហ្នឹង តា សុន សេន, តា កែ ពក ហ្នឹង សុទ្ធតែមានទូរលេខគេ ។

ដានីៈ អ៊ីឮថាដាច់ខ្យល់ស្លាប់?

ហឿនៈ កាលហ្នឹងខ្ញុំទៅដល់ចម្ការកៅស៊ូចម្ការអណ្តូងគេថា អ៊ូ! ភ្ញៀវចិនយើងស្លាប់ហើយទៅដល់លើព្រំដែនគាត់ដាច់ខ្យល់ ។

ដានីៈ អីចឹងពេលដែលយួនចូលហ្នឹង អ៊ំនៅចម្ការអណ្តូងនៅឡើយទេ?

ហឿនៈ នៅ! នៅជប់ហ្នុងកំពុងតែជប់លៀង ថ្ងៃ៣១ ឆ្នាំ៧៨ ។

ដានីៈ ថ្ងៃ៣១ ឆ្នាំ៧៨?

ហឿនៈ បាទ! ដល់ស្អែកឡើងបាន៧៩ យួនចូលដល់ម៉ោង៥កន្ទះល្ងាចហ្នឹង ក្នុងថ្ងៃ៣១កំពុងតែជប់លៀងហ្នឹង ។

ដានីៈ រត់ប្រជិតៗគ្នាចឹង?

ហឿនៈ បាទ!បាញ់ពួកបម្រើភ្ញៀវសុទ្ធតែអាវសងាប់...ងាប់ពេញហ្នឹង ។

ដានីៈ យួនបាញ់ងាប់អស់ច្រើន អ្នកបម្រើភ្ញៀវចិនហ្នឹង?

ហឿនៈ បាទ!

ដានីៈ តែចិនងាប់តែមួយហ្នឹងទេ?

ហឿនៈ តែមួយហ្នឹង ។

ដានីៈ ប្រពន្ធអ៊ីកូនចៅឃើញច្បាស់ម៉ង ត្រូវ...?

ហឿនៈ ឃើញ! ជិះឡានជាមួយគ្នាឈាមហូរដល់ក្បាល ។

ដានីៈ ហីបាញ់ត្រូវត្រង់ណា?

ហឿនៈ បាញ់ពីលើផ្លូវជាតិក្បែររោងចក្រជប់ហ្នឹង បាញ់មុខមកលិចអីចឹង យាយខ្ញុំគេឲ្យជិះបាំងមុខ ហើរ័ពពីក្រោយមក យាយខ្ញុំដល់វាបាញ់ទ្រូតៗអីចឹង យាយខ្ញុំដេកក្រោមឡាន ដេកផ្ងៀង ហើគ្រាប់ហ្នឹង ខ្ញុំទៅមើលឡានហ្នឹងវាមិនទៅត្រង់អីចេះណា ខ្ញុំទៅមើលឃើញទៅត្រង់អីចឹង មកអីចេះ ទៅអីចេះៗហើយបានចេញផុតទៅ ។

ដានីៈ ត្រូវតែមួយហ្នឹង?

ហឿនៈ បាទ! ត្រូវតែមួយ ។

ដានីៈ ប៉ុន្តែរថក្រោះហ្នឹងវាតាមមិនទាន់ឡាន?

ហឿនៈ រថក្រោះហ្នឹងទៅដេកនៅស្ងួន ។

ដានីៈ តែរថក្រោះយួនហ្នុងវាមិនដេញតាមឡានបាញ់ហ្នឹង?

ហឿនៈ វាមកបាំងផ្លូវអត់ឲ្យយើងចេញពីកន្លែងជប់លៀងហ្នឹង ហើយដល់មួយនៅខាងអាមួយនៅទទឹង អាខាងហ្នឹងវាឡើងបើកមួកក្មេងៗយក បើកមួកកាតឹបហ្នឹង ដល់បើកយក វាឃើញបើកទ្វារបង្អួច វាដកគ្រាប់បែកទម្លាក់ក្ដឹងទៅ ក្ដឹងទៅវិល វិលអានេះដៀស ។

ដានីៈ ដៀសរួចបើប្រុយមក?

ហឿនៈ ដល់បើកប្រុយមកបានវាដាក់មួយគ្រាប់ត្រូវចិនហ្នឹងងាប់... ។

ដានីៈ ប្រពន្ធអ៊ឹកាត់មកមុន អ៊ឹមកតាមក្រោយទេ?

ហឿនៈ មកមុនខ្ញុំ ខ្ញុំមកដល់ទន្លេបិទបានឃើញយាយខ្ញុំនៅទន្លេបិទ ខ្ញុំរត់មកខូចម៉ូតូចោលលើផ្លូវជាតិលេខ៧ទៅ ខ្ញុំដើរមក ។

ដានីៈ ជិះម៉ូតូពីជប់មកខូចម៉ូតូនៅណា?

ហឿនៈ នៅលើផ្លូវជាតិលេខ៧ ។

ដានីៈ នៅម្ដុំណា?

ហឿនៈ នៅខាងលិចផ្លូវទៅពាមជាំងប្រហែលជា៥០ម៉ែត្រ ទុកចោលនៅហ្នឹង ។

ដានីៈ នៅព្រៃទទឹង?

ហឿនៈ ផ្លូវទទឹងទៅពីជប់ ទៅ... ។

ដានីៈ ថ្នល់ទទឹង គេហៅថ្នល់ទទឹង?

ហឿនៈ អាថ្នល់ទទឹងទៅត្បូងអីចេះ ។

ដានីៈ ជិះបានតែបន្តិចបានខូចហ្នឹង?

ហឿនៈ ចេញតែពីរោងចក្រមកតែមួយភ្លេចហ្នឹង ម៉ូតូវាដាច់ហ៊ុយស៊ីបហើយខូច ។

ដានី៖ ពេលខូចហើយដើរ?

ហឿន៖ ដើររហូតដល់កំពង់ដែទន្លេបិទ ។

ដានី៖ បានជួប?

ហឿន៖ ទៅដល់យាយខ្ញុំនៅហ្នឹង ។

ដានី៖ ហើយយ៉ាងម៉េចទៀតទៅ?

ហឿន៖ ទៅដល់ តា ជីម សំឡុតមកហើយនៅវ៉េរ៉ាហ្នឹង មិនគិតរកកប៉ាល់ដឹកឆ្លងទៅទន្លេបិទយួនមកដល់ហើយហ្នឹង ខ្ញុំថាចុះ អាតក់ គេនៅប្រធានកំពង់ដែហ្នឹងទៅណាចុះ ថាគ្មានឃើញអាណាម្នាក់ទេ!

ដានី៖ ឈ្មោះ តក់?

ហឿន៖ តក់ ហ្នឹងប្អូនខ្ញុំ ។

ដានី៖ ប្អូនអី បង្កើត?

ហឿន៖ ប្រធានកំពង់ដែហ្នឹង ដល់ហើយខ្ញុំដើររកកប៉ាល់មានតែអាធំៗដឹកទឹកជ័រ រកអត់បានទេ មានតែកប៉ាល់ក្អៀវ ហើយទៅដល់កណ្តាលទន្លេលោតពីមួយទៅមួយពេញក្នុងទន្លេហ្នឹង សុទ្ធតែកប៉ាល់ ចុះត្រៀមចាញ់នោះៗ! កប៉ាល់ដើររកទៅមានអាមួយនៅខាងគេនៅកណ្តាលទន្លេណុះ ឃើញក្មេងមួយនៅដេកហ្នឹង ថាទៅឯងបញ្ចេះកប៉ាល់ទៅយកកម្មករឆ្លងទៅទន្លេទៅកំពង់ចាម ថាតាអើយខ្ញុំអត់ចេះបើកផងហ្នឹង គេឲ្យខ្ញុំចាំ ថាចុះឯងចេះបញ្ចេះដែលអីចឹង បញ្ចេះចេះ អីចឹងបញ្ចេះទៅចុះ ដល់បញ្ចេះខ្ញុំយកឈើរុញអាកប៉ាល់ធំៗ រុញទៅបន្តិចៗដល់កំពង់ដែ គ្រាន់ទៅដល់អាអ្នកអត់ត្រូវមានមកហ្នឹងឡើងពេញឡើងពេញ ប្រពន្ធកូនខ្ញុំឡើងអស់ អាជីម ឡើងអស់ បញ្ចេះទ្រឹលមកបាត់! អត់ឲ្យឡើងច្រើន ហីបានមកដល់បានឲ្យកប៉ាល់ពីរបីទៅដឹកជញ្ជូនទាំងយប់ហ្នឹងទាល់តែភ្លឺ ដឹកមកដាក់កំពង់ចាម ។

ដានី៖ តា ជីម គាត់កាច គាត់ចេះតែសំឡុតអី?

ហឿន៖ កាច! សំឡុតតែអីចឹង តែខ្ញុំសំឡុតវិញអត់ហ៊ានមាត់តទេ សំឡុតតែខ្ញុំ គាត់ភ័យគាត់ ។

ដានី៖ មកដល់កំពង់ចាម អីបន្ត ជិះអីបន្តទៅទៀត?

ហឿន៖ មកដល់កំពង់ចាម ឡានៅកំពង់ចាម ឆ្លងសាឡាងបានខ្លះ ជិះមកដេកនៅកំពង់ចាមបានមួយយប់ មួយយប់ ដង្វាងធ្លាក់ហ្នឹង តា ម៉ុក ក៏នៅហ្នឹង សុន សេន នៅហ្នឹង តាពកនៅហ្នឹង ។

ដានីៈ តា ម៉ុក នៅហ្នឹងដែរ?

ហឿនៈ បាទ! នៅស្រុកកំពង់សៀមហ្នឹង ។

ដានីៈ តា ម៉ុក ម៉េចបានជាមកដល់ហ្នឹងដែរ?

ហឿនៈ តា ម៉ុក គាត់ទៅជួប តា សុន សេន នៅសួងហ្នឹងហើយមកដេកនៅកំពង់សៀមហ្នឹងដែរ មិនដេកកំពង់ចាម មកដេកសាលាស្រុកកំពង់សៀម តា ស៊ីៗនោះ នៅបីនាក់ហ្នឹង តា ពក, តា ម៉ុក ហើយផ្ទៅងធ្លាក់មុខៗហ្នឹង គិញវាមកតាមមើល វាតាមរកឃើញ ។

ដានីៈ ចឹងអ៊ីមានស្គាល់គណៈឃុំណាមួយនៅកំពង់សៀមទេ ដែលនៅជាមួយ តា ស៊ី?

ហឿនៈ អត់មានស្គាល់ទេ ថ្មីថោង អត់ស្គាល់ដីផង ទៅជួប តា ស៊ី ហ្នឹងសុំស្នាក់មួយយប់ ឡើងផុត នៅចម្ការអណ្ដូងបានមួយយប់ទៀត គេថាយួនដល់ភ្នំពេញហើយ អ៊ីចឹងខ្ញុំរត់ទៅនៅកំពង់ថ្ម ដល់កំពង់ថ្មម៉ោង៦ ។

ដានីៈ ប៉ុន្តែរត់បែកពី តា ម៉ុក បែកពី សុន សេន?

ហឿនៈ បែកហើយ តា ម៉ុក ទៅដល់ភ្នំពេញ យកទាំងក្មៀវចិនយកទាំងអីទៅបាត់ហើយ ។

ដានីៈ ហើយ តា សុន សេន ទៅណាតាមផ្លូវណា?

ហឿនៈ តា សុន សេន គាត់ទៅភ្នំពេញដែរ ។

ដានីៈ កែ ពក អី?

ហឿនៈ កែ ពក រត់ទៅភ្នំពេញដែរ ។

ដានីៈ អ៊ីចឹងអ្នកធំៗទៅភ្នំពេញអស់ទៅ?

ហឿនៈ បាទ! ទៅទាំងអស់ ។

ដានីៈ កាលហ្នឹងថ្ងៃ១ ឬថ្ងៃ៣១?

ហឿនៈ ថ្ងៃ១ឆ្នាំ៧៩ហើយ ថ្ងៃ៣១ជប់លៀងស្អែកទៅថ្ងៃ១ឆ្នាំ៧៩ហ្នឹង ។

ដានីៈ ថ្ងៃជប់លៀងហ្នឹងយួនចូលមកដល់ក្វាម?

ហឿនៈ បាទ! កំពុងតែជប់លៀង គ្រាន់តែលើកស្រាឡើងផឹក អត់ទាន់បានហូបចុកទេទាំងអស់គ្នា ម៉ោង៦កន្លះហើយហ្នឹង ។

ដានីៈ ពេលអ៊ីមកដល់កំពង់ថ្មទៅណាទៀត?

ហឿនៈ ទៅដល់កំពង់ថ្មយួនចូលដល់ភ្នំពេញ តា ជីម ស្រែកប្រកាសថា បងប្អូនទាំងអស់យើងបែកគ្នាហើយ ខ្ញុំចូលព្រៃគស៊ូ បងប្អូននៅស្រុកណាភូមិណាឲ្យទៅផ្ទះរៀងខ្លួនចុះ ឡានហ្នឹងយកជិះទៅ ខ្ញុំទៅហើយ ទៅប្រុចបាត់...។

ដានីៈ ពេលហ្នឹងបែកពីអ៊ំហើយពេលហ្នឹង?

ហឿនៈ គេបែកហើយ គេទៅឡានខ្ញុំឡើងគោងគេអត់ឲ្យគោង ខ្ញុំទៅដើរជាមួយគេជាមួយឯង អ៊ីចឹងទៅ ដើរឡប់មកនៅព្រៃកៅស៊ូចម្ការអណ្ដូងទៀត ដល់គេថាយួននៅកំពង់ថ្មពេញហើយ នៅកំពង់ថ្មពេញដើរកាត់ព្រៃទៅដើងអីចេះទៅ ។

ដានីៈ ដើរទៅជាមួយក្រុមគ្រួសារទាំងអស់?

ហឿនៈ អត់ទេ ក្រុមគ្រួសារគេជិះឡានរត់មកដល់កំពង់ធំមុន មកដល់ផ្ទះ តា ស៊ីម, សេម ហ្នឹងហើយ ។

ដានីៈ មកដល់ផ្ទះ តា ស៊ីម ?

ហឿនៈ តា ស៊ីម ខ្ញុំស្គាល់ ។

ដានីៈ តា ស៊ីម ប្រពន្ធគាត់ឈ្មោះ សេម?

ហឿនៈ តា ស៊ីម ប្រពន្ធ សេម ហ្នឹង មកជួប តា ស៊ីម ជួបអីហ្នឹងហើយ ដល់ខ្ញុំមកជួបយាយខ្ញុំឃើញតា ស៊ីម ឃើញ តាអីៗនៅហ្នឹង ។

ដានីៈ នៅកំពង់ធំហ្នឹង?

ហឿនៈ បាទ! ជួបគ្នារត់ចូលព្រៃជាមួយគ្នាទៀត ។

ដានីៈ ពេលដែលអ៊ំដើររត់ហ្នឹងពីថ្ងៃ១ចេញពីកំពង់ចាមដល់ថ្ងៃប៉ុន្មានបានទៅជួបគ្នានៅកំពង់ធំ?

ហឿនៈ មួយខែជាង ដើររកអត់ឃើញឆាយទេ ។

ដានីៈ អ៊ីចឹងមួយខែជាងហ្នឹងខាងកំពង់ធំមិនទាន់បែកទេ?

ហឿនៈ កំពង់ធំបែកអស់ហើយ ។

ដានីៈ បែកអស់ទៅជួបប្រពន្ធនៅណាអ៊ីចឹង?

ហឿនៈ ជួបនៅក្នុងព្រៃស្រុកសណ្ដាន់ ។

ដានីៈ ជួប តា ស៊ីម ក្នុងព្រៃស្រុកសណ្ដាន់?

ហឿនៈ បាទ!តា ស៊ីម ក៏រត់ដែរ រត់អស់ហើយ ទៅជួបនៅស្រុកសណ្ដាន់ភូមិដាំ ។

ដានីៈ ដល់ពេលចេញពីស្រុកសណ្ដាន់ភូមិដាំនៅហ្នឹង?

ហឿនៈ ចូលព្រៃហើយលែងជួបប្រជាជនរហូត ។

ដានីៈ ទៅដល់ណាទៀតទៅអ៊ំ?

ហឿនៈ ទៅនៅក្នុងព្រៃកំពង់ធំហ្នឹងមួយឆ្នាំ ។

ដានីៈ មួយឆ្នាំហើយទៅណាទៀត?

ហឿនៈ ខ្ញុំនៅបានមួយឆ្នាំ តា ជឹម រកសម្លាប់ ខ្ញុំរត់ចោលជួរទៅនៅចម្ការកៅស៊ូចម្ការអណ្ដូងក្នុងព្រៃ ។

ដានីៈ កាលហ្នឹង តា ជឹម គាត់ធ្វើអី?

ហឿនៈ កាលហ្នឹងនៅក្នុងព្រៃគេឲ្យគាត់ធ្វើចៅហ្វាយស្រុកសន្ទុកហ្នឹង ។

ដានីៈ ចៅហ្វាយស្រុកសន្ទុក?

ហឿនៈ បាទ! នៅក្នុងព្រៃហើយគេចាត់តាំងបណ្ដោះអាសន្នហ្នឹងណា ។

ដានីៈ គាត់ធ្វើចៅហ្វាយស្រុកសន្ទុកហើយអ៊ំធ្វើអី?

ហឿនៈ អត់! គេឲ្យធ្វើស្រែ ។

ដានីៈ អត់មានសមាជិកស្រុកសន្ទុកអីទេ?

ហឿនៈ អត់មានធ្វើអីទាំងអស់ ។

ដានីៈ កាលហ្នឹង តា ជឹម ធ្វើចៅហ្វាយស្រុកសន្ទុកពីណាជាអនុគាត់?

ហឿនៈ តា នាង មិនដឹងជាស្អីនាងទេ ។

ដានីៈ តា នាង?

ហឿនៈ តា នាង ងាប់ហើយនៅអន្លង់វែង កើតទាច ។

ដានីៈ កាលហ្នឹងអ៊ំស្គាល់ តា ប៉ូច ទេ?

ហឿនៈ តា ប៉ូច ហ្នុងខ្ញុំស្គាល់ ។

ដានីៈ គាត់ធ្វើអីហ្នុង?

ហឿនៈ កាលហ្នឹង តាប៉ូចហ្នុងស្គាល់តែឈ្មោះ មិនដឹងគេធ្វើអីទៀត ។

ដានីៈ គាត់ធ្វើគណៈស្រុកដែលអត់ទេ?

ហឿនៈ អត់ទេ! ចៅហ្វាយខេត្ត តា ប៉ូច ហ្នឹង ។

ដានីៈ ចៅហ្វាយខេត្ត! ធំជាង តា ជឹម ទៀត?

ហឿនៈ ចៅហ្វាយខេត្តគេ ប៉ុនដល់រត់ចូលព្រៃហើយមាននាទីអីទៀតអត់ មានតែ តា ជឹម ទៅដល់ហ្នុងតា ពក ឲ្យធ្វើចៅហ្វាយស្រុកសន្ទុក ខ្ញុំដឹងថាប៉ុណ្ណឹងទេ ។

ដានីៈ នៅក្នុងព្រៃធ្វើចៅហ្វាយស្រុកហ្នុងហើយនៅចង់រកសម្លាប់មនុស្សទៀត?

ហឿនៈ ចង់សម្លាប់ខ្ញុំហ្នឹង ។

ដានីៈ ប៉ុន្តែកាលទំនាស់ជាមួយអ៊ំហ្នុង គាត់មានគំរោងចង់សម្លាប់ពីណាដែលអីជិតអស់?

ហឿនៈ សម្លាប់គ្រូមួយ គ្រូមួយនៅភូមិដូងព្រីង ស្រុកសណ្ដាន់ហ្នឹង ឈ្មោះ តា ឈួន ។

ដានី៖ យ៉ាងម៉េចបានរកសម្លាប់?

ហឿន៖ គាត់មើលទ័ពជា លាបរបួសលាបថ្នាំគាត់ជាសះហើយ គាត់ថាទំពាថ្នាំហើយបេះតែធ្វើមាត់អូចៗ ថានៅមានជំនឿនៅមានបាលីអីមានអី ហីឲ្យតា គង់ កងពលហ្នឹងសម្លាប់ តា គង់ថា ខ្ញុំបានគាត់ហ្នឹងហើយមើលទ័ពខ្ញុំជា ហើយបើយកគាត់សម្លាប់ ខ្ញុំបានពីណាមើលទ័ពខ្ញុំទៀតទៅថាឲ្យ តា គង់ បីដងម៉ោង៩ប្រហែលជាថ្មើហ្នឹងហើយពូសួរកាំភ្លើងទូង គេថា គេបាញ់ តា ឈួន ងាប់ ហីខ្ញុំទៅមើលដែរ គេស្រាតខោ គេគប់លើដីហ្នឹង ខ្ញុំទៅឃើញ ខ្ញុំស្រណោះអើយ គេខំមើល ខំថែ។

ដានី៖ តា គង់ ណា?

ហឿន៖ តា គង់ មេទ័ពតាមការពារពួកកម្មករចម្ការកៅស៊ូហ្នឹង។

ដានី៖ ឈ្មោះ អី គង់?

ហឿន៖ អត់ដឹង គេទ័ព អត់ដែលដឹង គេនៅតែក្នុងព្រៃ។

ដានី៖ គាត់ទៅរកសម្លាប់តា ឈួន ហ្នឹង ពេលហ្នឹង អ៊ំថា កុំសម្លាប់គាត់ខឹងអ៊ំ?

ហឿន៖ ខ្ញុំអត់! លែងហ៊ានមាត់ទេ បើខ្ញុំហ៊ានប្រាប់ហ្នុង ខ្ញុំទៅប្រាប់ឲ្យគាត់រត់បាត់ហើយ ឲ្យតា គង់ សម្លាប់បីដង បានតា គង់ សម្លាប់។

ដានី៖ តា ដឹម ប្រាប់បីដង?

ហឿន៖ បាទ! ប្រាប់។

ដានី៖ ប៉ុន្តែមុនហ្នឹងគាត់និយាយជាមួយអ៊ំដែរ គាត់សំឡុតថា គំរាមអ៊ំធ្វើដៃ?

ហឿន៖ អាហ្នឹងអា យន់ ប្រធានមន្ទីរគាត់ទេ ខ្ញុំថាកុំធ្វើបាបគាត់អី... តា ឈួន ហ្នឹងអត់ដែលប្រាប់អត់ដែលអីទេ គាត់កំពុងតែចងជើងគ្រែឲ្យអ្នកជំងឺដេកវាហៅទៅ គ្រាន់ចេញផុតពីរោង គេដាក់គាត់នៅហ្នឹង គ្រាន់ពូថាបាញ់ តា ឈួន ខ្ញុំទៅមើល ស្រាតខោគាត់ដាក់លើថ្នួ ខ្ញុំស្រណោះ ខ្ញុំគ្រាន់តែមើលឃើញ។

ដានី៖ អ៊ំចេញពីហ្នឹងហើយទៅណាទៀតទៅ?

ហឿន៖ ចេញពីចម្ការកៅស៊ូចម្ការអណ្តូងហ្នឹង ឡើងភ្នំដងរែកហើយខែ៧។

ដានី៖ ខែ៧ ឆ្នាំណា?

ហឿន៖ ឆ្នាំ៨០ខែ៧។

ដានី៖ ឡើងភ្នំដងរែក?

ហឿនៈ បាទ! ឡើងភ្នំដងរែក គេប្រាប់ថា ត្រៀមអង្ករ៣០កំប៉ុងទៅភូមិភាគខាងជើង ហើយខ្ញុំអត់មានអីរលីង ។

ដានីៈ កាលហ្នឹង អ៊ំស្រីទាំងកូនទាំងចៅទៅទាំងអស់?

ហឿនៈ អត់ទេ! កូនស្រីខ្ញុំ ខ្ញុំផ្ញើនៅភូមិយង់ប្រអប់ យួនដឹកមកស្រុកទាំងអស់ ។

ដានីៈ អីចឹងទាំងកូនទាំងប្រពន្ធយួនដឹកមកស្រុកទាំងអស់?

ហឿនៈ មកទាំងអស់នៅកូនមួយ ឈ្មោះយួនហ្នឹង ទៅតាមក្នុងព្រៃជាមួយគ្នា ។

ដានីៈ ប្រពន្ធ តា ជឹម ប្រពន្ធអ៊ំត្រឡប់ទៅស្រុកទាំងអស់?

ហឿនៈ ប្រពន្ធ តា ជឹម យួនចាប់បាន ។

ដានីៈ យួន អត់សម្លាប់ផងហ្នឹង?

ហឿនៈ អត់សម្លាប់ បញ្ជូនដល់ផ្ទះដល់ស្រុក ទៅទាំងកូនទាំងចៅទាំងអស់ ។

ដានីៈ ពាក្យអាចាមអាភមថាយួនយកដើមស្វាធ្លាងស្វាហ្នឹងយកមកដោតមនុស្សហាលលើខ្នងប្រឡាយហ្នឹងជាពាក្យអាចាមអាភមទេ?

ហឿនៈ ពាក្យចាមអាភមអ្នករត់ អ្នកភ័យចេះតែថាទៅ អ្នកខ្លាចណា ថាតៗគ្នាទៅ ។

ដានីៈ តែ យួន អត់ស្គាល់ប្រពន្ធ តា ជឹម ថាធ្លាប់ជាគណៈស្អី?

ហឿនៈ អត់ដែលជួប អត់ដែលដឹង ។

ដានីៈ គេអត់មានដាក់គុកដាក់អីទេ?

ហឿនៈ អត់ទេ! វាអត់មានដាក់គុកទេ សួរវាទៅ ថាគេយកទៅឲ្យដេកខេត្តស្ទឹងត្រែងហ្នឹងអាមួយឈ្មោះ អា ណាត ហ្នឹង យប់ឡើងវាអត់អីស៊ី ដើរលួចបាយលួចអង្ករគេ គេអត់មានធ្វើអីផង ។

ដានីៈ គេបញ្ជូនទៅស្រុកកំណើតទៅ?

ហឿនៈ ស្រុកកំណើត! ទៅដល់ស្រុកគ្រាំកក់ យាយខ្ញុំទៅដល់មុន យាយ ហ៊ាង នេះទៅក្រោយយាយខ្ញុំយួនបញ្ជូនទៅខែ៤ ឆ្នាំ៧៩ហ្នឹង ។

ដានីៈ អ៊ំឡើងភ្នំដងរែកតែម្នាក់ឯង?

ហឿនៈ ទៅពីរនាក់កូន ឈ្មោះយួន ។

ដានីៈ ទៅដល់យ៉ាងម៉េចទៅ?

ហឿនៈ ទៅដល់ភ្នំដងរែកហ្នឹង តា ជឹម ជួបខ្ញុំ សំឡុតខ្ញុំដកកាំភ្លើង ដល់ដកកាំភ្លើង ។

ដានីៈ ទៅជួបតា ជឹម ទៀត?

ហឿនៈ ទៅជួបក្នុងព្រៃហ្នឹង ជួបឲ្យតា កាន ស្រុកស្អីទេ កងមាស ឬពាមជីកងខ្ញុំភ្លេច ។

ដានីៈ ជួប តា កាន ហ្នឹងទៀត?

ហឿនៈ ជួប តា កាន គេឲ្យ តា កាន ហ្នឹងទៅដក ហើយកាំភ្លើងខ្ញុំស្អាតណាស់ ស្នាប់ដៃពីរ កាំភ្លើងសូវៀតហ្នឹង ក្រហមឆេះថ្មីចេះម៉ង គេឲ្យទៅដក ហើយតាកាន ហ្នឹងទៅដក យី! កាំភ្លើងនេះស្អាតម្ល៉េះ អត់មានខ្មៅអីបន្តិច ក្រហម សុំដកកាំភ្លើង ខ្ញុំថាដកកាំភ្លើងខ្ញុំធ្វើអី យួននៅពេញប្រទេសមកដកកាំភ្លើង អាណាមកឲ្យដក ឲ្យតា ជឹម ហ្នឹងមកយក ខ្ញុំថា អីចឹង តា ជឹម អត់ហ៊ានមកយក ហើយឲ្យកូនប្រសារខ្ញុំអាសូរនេះ អាសូរ កាលហ្នឹង អត់ទាន់ជាកូនប្រសារខ្ញុំទេ រត់ចូលព្រៃយើងនេះឲ្យអាសូរ មកយក ថាតាឲ្យមកយកកាំភ្លើង អញថាឯងកុំយក ឲ្យតា ជឹម មកយកមើល ហើយ តា ជឹម ក៏អត់ហ៊ានមកយក ខ្ញុំស្ពាយដើរទៅជួប តាម៉ុក ក្នុងព្រៃតាមផ្លូវ តាម៉ុក ថាពួកឯងកាំភ្លើងច្រើនម្ល៉េះឲ្យអញ អញយកឲ្យទ័ពចុះទៅមុខ ពួកឯងអាក្បាលសនៅលើបានហើយ ។

ដានីៈ ក្បាលសយ៉ាងម៉េច សក់ស?

ហឿនៈ អាក្បាលសដូចខ្ញុំអីចឹង មិនបាច់ឲ្យឯងចុះទេ ឲ្យកាំភ្លើងមកអញ ខ្ញុំឲ្យទៅគាត់ ។

ដានីៈ ចុះកាលហ្នឹងអ៊ីស្គាល់ កាន ថាគណៈស្រុកនៅនៅកងមាស?

ហឿនៈ តា កាន ស្គាល់តែពេលទៅដកហ្នុង ។

ដានីៈ អ្នកស្រុកណា តា កាន ហ្នឹង?

ហឿនៈ ខ្ញុំអត់ដឹងទេ ។

ដានីៈ ចុះយ៉ាងម៉េចបានស្គាល់ឈ្មោះគាត់?

ហឿនៈ គេហៅ តា កានៗ គ្រប់គ្នាទៅដល់ហ្នុង ។

ដានីៈ ចាស់ដាងអ៊ី ឬក៏ដំណាលអ៊ី?

ហឿនៈ ក្មេងជាងខ្ញុំ ប៉ុហ្នឹងធ្វើចៅហ្វាយស្រុកតែមិនដឹងស្រុកណា ។

ដានីៈ មិញអ៊ីថា ពាមជីកង កងមាស?

ហឿនៈ អឺ! ក្មេងៗវាថា តា កាន ហ្នុងនៅពាមជីកង ឬកងមាសខ្ញុំភ្លេចយូហើយ ។

ដានីៈ ប៉ុន្តែអត់ដឹងថា តា កាន ជាអ្នកស្រុកនៅណាទេ?

ហឿនៈ អត់! គាត់ទៅធ្វើមេឃុំនៅហ្នឹងកាលសម័យ ប៉ុល ពត ។

ដានីៈ ធ្វើឃុំនៅណា?

ហឿនៈ ធ្វើមេស្រុកនៅពាមជីកង ឬកងមាសទេ ។

ដានី៖ ដល់ក្រោយមក តា កាន ទៅនៅណា?

ហឿន៖ នៅក្នុងព្រៃជាមួយគ្នា ដល់ពេលតា ម៉ុក រៀបចំឲ្យចុះ គាត់ចុះមកវិញមក...។

ដានី៖ គាត់មកស្រុកកំណើត?

ហឿន៖ មកវាយយួននៅព្រំដែនវិញ គាត់អត់ទៅស្រុកផង។

ដានី៖ ហើយយ៉ាងម៉េចទៀតទៅ តា កាន ?

ហឿន៖ ចប់ត្រឹមហ្នឹង លែងដឹងទៀត បែកគ្នារហូតហើយ។

ដានី៖ តា កាន ប្រពន្ធគាត់ឈ្មោះអី?

ហឿន៖ អត់ដឹង ឃើញតែ តា កាន ហ្នឹង ឃើញតែម្នាក់ រត់ចូលព្រៃអត់មានពីណាមានប្រពន្ធទេ។

ដានី៖ ចឹងអ៊ំ កាលឆ្នាំ៨៧ទៅជួប តា ម៉ុក, តា ម៉ុក ថាយកកាំភ្លើងពីអ៊ំហើយ អ៊ំទៅណាទៀតទៅ?

ហឿន៖ ខ្ញុំឈឺដេកពេទ្យទៅ ហើម ទៅដេកពេទ្យ តា ដឹម ប្រាប់ពេទ្យថា កុំឲ្យថ្នាំសង្កូវអីកុំចាក់ថ្នាំឲ្យខ្ញុំ។

ដានី៖ ចុះយ៉ាងម៉េចបានគាត់មានគំនុំជាមួយអ៊ំ?

ហឿន៖ គំនុំទឹងខ្ញុំថាដែលរកសម្លាប់ប្រធានមន្ទីរគាត់ហើយខ្ញុំអត់ឯកភាពហ្នឹង ទឹងតាំងពីហ្នឹង។

ដានី៖ កាលហ្នឹងយ៉ាងម៉េចបានរកសម្លាប់ប្រធានមន្ទីរគាត់?

ហឿន៖ ខ្ញុំគ្រាន់តែមកដល់កន្ទែង គាត់ប្រាប់ឲ្យកងការពារគាត់មកសម្លាប់ខ្ញុំ មកដល់វាយាំ ខ្ញុំថាឯងថី អង្គុយអញនៅបបរស៊ីទៅ ថាអត់ទេ តាឲ្យខ្ញុំមកសម្លាប់ពូឯង ខ្ញុំអត់សម្លាប់ពូឯងទេ បើពូឯងឲ្យខ្ញុំទៅសម្លាប់តាបានខ្ញុំទៅ ខ្ញុំថាមិនបាច់ទេ កុំទៅសងឈាម ទៅយើងរត់ទៅ។

ដានី៖ ឈ្មោះអីដែលថា?

ហឿន៖ ក្មេងៗហ្នឹងឈ្មោះ អាញ៉ាយ ឈ្មោះ អា ញ៉ុន ឈ្មោះ អា ហយ បីនាក់ហ្នឹងគេមក។

ដានី៖ អ្នកស្រុកនៅណាដែលពួកហ្នឹង?

ហឿន៖ អាហ្នឹងនៅស្រុកត្រាំកក់ជាមួយគ្នា។

ដានី៖ នៅភូមិជាមួយអ៊ំដែរ?

ហឿន៖ នៅភូមិត្រពាំងប្រីយ៍ទាំងអស់ ភូមិជាមួយខ្ញុំហ្នឹង។

ដានី៖ ពួកហ្នឹងនៅរស់ទេ?

ហឿន៖ អា ហយ ងាប់តាំងពីក្នុងព្រៃ ហីអាអស់ហ្នឹងដឹងងាប់អីរស់បែកគ្នាតាំងពីហ្នុងមក។

ដានីៈ អត់ដែលជួបទៀតទេ?

ហឿនៈ អត់ ។

ដានីៈ ឪពុកម្ដាយគាត់មានស្គាល់ទេ?

ហឿនៈ ស្លាប់អស់ហើយ ដឹកតែស្រាហើមខ្លួនស្លាប់អស់ហើយអត់មានអាណានៅទេ ។

ដានីៈ ចុះម៉េចបានជា តា ជឹម គាត់បញ្ជាឲ្យមកសម្លាប់អ៊ី?

ហឿនៈ ខ្ញុំអត់ឯកភាព គាត់ប្រជុំមេៗប៉ុន្មាននាក់ហ្នឹង គេឯកភាពហើយ ខ្ញុំថាខ្ញុំអត់ឯកភាពទេ ។

ដានីៈ ប្រជុំយ៉ាំងម៉េច?

ហឿនៈ ប្រជុំសម្លាប់អាមនុស្សហ្នឹង ។

ដានីៈ សម្លាប់មនុស្សណា?

ហឿនៈ អាយន់ ដែលប្រធានមន្ទីររបស់គាត់ហ្នឹងឈ្មោះយន់ ប្រពន្ធវាឈ្មោះមីអួនកូនមួយក្នុងព្រៃ ហ្នឹង ។

ដានីៈ យន់ ហ្នឹងអ្នកនៅស្រុកណា?

ហឿនៈ ស្រុកត្រាំកក់ ឃុំជាងទង ។

ដានីៈ មកជាមួយគ្នាម៉េចរកសម្លាប់គាត់? យន់ហ្នឹងខុសអីបានតាជឹម រកសម្លាប់?

ហឿនៈ វាខុសឲ្យមើលប្រពន្ធ យួនវាយទៅវារត់បែកគ្នា បាត់ប្រពន្ធគេ គេរកសម្លាប់ហ្នឹង ។

ដានីៈ បាត់ប្រពន្ធគាត់ យួនចាប់បាន យន់ហ្នឹង?

ហឿនៈ យួនអត់ចាប់ផង រត់វង្វេងក្នុងព្រៃ គេតាមរកឃើញវិញទៅ ដល់ភ្នំដងរែកបានបែក ។

ដានីៈ ដល់ពេលគាត់ប្រជុំគ្នាជាមួយមន្ទីរគាត់ហ្នឹងថាត្រូវសម្លាប់យន់ហ្នឹងចោល ព្រោះយន់ហ្នឹង ធ្វើឲ្យបាត់ប្រពន្ធគាត់កូនគាត់?

ហឿនៈ ធ្វើឲ្យបាត់ប្រពន្ធគាត់ ។

ដានីៈ ឆ្នាំណាហ្នឹង?

ហឿនៈ ឆ្នាំ៨០ហើយ រកសម្លាប់ខ្ញុំហ្នឹង ។

ដានីៈ តែរកសម្លាប់យន់ ហ្នឹងឆ្នាំណា?

ហឿនៈ ឆ្នាំ៨០ ។

ដានីៈ ខែប៉ុន្មានទៅ?

ហឿនៈ ដូចខែ១ហើយ ខ្ញុំដឹងអីចឹង ខ្ញុំរត់មកពីកំពង់ធំ ទៅកំពង់ចាម ។

ដានីៈ ចុះយន់ ហ្នឹងគេសម្លាប់បានអត់?

ហឿនៈ អត់! ខ្ញុំប្រាប់ឲ្យវាត់ទៅផ្ទះទៅ ។

ដានីៈ វាត់ទៅណាទៅឥឡូវ?

ហឿនៈ វាត់ទៅស្រុកវិញទៅ ។

ដានីៈ ឥឡូវនៅស្រុក?

ហឿនៈ នៅស្រុក ។

ដានីៈ ស្រុក...?

ហឿនៈ ស្រុកវានៅស្រុកត្រាំកក់ ឃុំជាងទង ភូមិក្បាលអូរ ។

ដានីៈ ឥឡូវគាត់នៅក្បាលអូរ?

ហឿនៈ បាទ! នៅភូមិក្បាលអូរ ។

ដានីៈ ឈ្មោះយន់ ប្រពន្ធគាត់ឈ្មោះ?

ហឿនៈ ឈ្មោះមីអូន ។

ដានីៈ ប្រពន្ធឈ្មោះអូន?

ហឿនៈ បាទ!

ដានីៈ គាត់អរគុណអ៊ីបានប្រាប់ ។

ហឿនៈ កុំប្រាប់ហ្នឹងគេសម្លាប់បាត់ ។

ដានីៈ សព្វថ្ងៃនៅរស់អីចឹងគាត់?

ហឿនៈ បែបនៅរស់ ខ្ញុំឲ្យទៅ២-៣នាក់ យាយខ្ញុំដឹងឲ្យទៅ យាយខ្ញុំមកសួរ ឈ្មោះអានី មួយ ខ្ញុំថាអានី ហ្អែងហើមស្រក់ៗ ហ្អែងទៅផ្ទះទៅ ។ ពួងងធ្វើបាបខ្ញុំ មិនជឿខ្ញុំថាទៅមើល មិនធ្វើបាប ខ្ញុំថាអញចងកម្មពៀរជាមួយហ្អែងធ្វើអី ហើយវាថាអត់មានស្បៀងទៅបាន អី នោះហ្អែងមើលអង្ករតានាង អង្ករតានាងមួយទៃវែងហើយមួយប៉ោត ខ្ញុំថាយកអង្ករ ហ្នឹង ដល់ម៉ោង៩វាយកអង្ករហ្នឹងទៅបាត់ទៅ ទៅគ្នា៥នាក់ ហើយអាអ្នកមួយនៅភូមិរន្ទះ នៅស្រុកសណ្តាន់ហ្នឹង ហ្អែងទៅមើលអានី មើលអាទិតផង ហ្អែងកុំធ្វើបាបវា វាទៅ ជាមួយឯង ហ្អែងជួយមើល ជួយការពារវាកុំឲ្យគេធ្វើបាប អញឲ្យហ្អែងនាំវាទៅ ហ្អែង ស្រុកកំណើតនៅហ្នឹង ហើយវាទៅៗទៅបាត់ ។ ដល់ព្រឹដំណើងអានី ទៅដល់ស្រុកយាយខ្ញុំ មកសួរ សួរចុះតាអញនៅយ៉ាងម៉េចអានី? ពូអត់អីទេ ពូដើររកដំឡូង រកក្តួច បានហូប រាល់តែថ្ងៃ ត្រីពេញៗប៉ោត ។

ដានីៈ នី ហ្នឹងនៅរស់ទេឥឡូវ?

ហឿនៈ នៅ ។

ដានីៈ នៅណា?

ហឿនៈ ទៅដល់ស្រុក នៅភូមិត្រពាំងឫស្សី ស្រុកត្រាំកក់ហ្នឹង ឃុំត្រពាំងធំដែរ ។

ដានីៈ នី ប្រពន្ធគាត់ឈ្មោះអី?

ហឿនៈ អត់ អត់ទាន់មានប្រពន្ធ ។

ដានីៈ ឥឡូវហ្នឹង?

ហឿនៈ ឥឡូវហ្នឹងអត់ដែលជួបគ្នាទៀត ។

ដានីៈ អត់ស្គាល់ប្រពន្ធគាត់ឥឡូវ?

ហឿនៈ អត់ ។

ដានីៈ តែគាត់នៅរស់ដល់ឥឡូវ?

ហឿនៈ នៅ! យាយខ្ញុំទៅជួបកាលវាទៅដល់ស្រុក ។

ដានីៈ ឈ្មោះនី?

ហឿនៈ ឈ្មោះ នី មិនដឹងឈ្មោះអីនីទេ ។

ដានីៈ កូនតាអី ឪពុកគាត់?

ហឿនៈ អត់ស្គាល់ទេ នៅឆ្ងាយពីគ្នា ដឹងតែចូលព្រៃជាមួយគ្នា ទៅមន្ទីរក្រសួងជាមួយគ្នា ។

ដានីៈ ពេលដែលតាជឹម គាត់ប្រជុំប្រុងរកសម្លាប់ឈ្មោះ យន់ ហ្នឹង ប្រជុំជាមួយពីណាគេខ្លះ?

ហឿនៈ មួយតានាង, ពីរតាទុន, បីខ្ញុំ, បួនតាឌុច ។

ដានីៈ តាឌុចណា?

ហឿនៈ ប្រាំតាមួយទៀតភ្លេចឈ្មោះហើយ ។

ដានីៈ តាឌុច នៅណា?

ហឿនៈ តាឌុច នៅស្រុកត្រាំកក់ហ្នឹង ។

ដានីៈ គាត់ធ្វើ?

ហឿនៈ ឥឡូវគេធ្វើធំហើយ គេចូលព្រៃជាមួយខ្ញុំហ្នឹង ។

ដានីៈ រួចគេត្រឡប់ទៅស្រុកត្រាំកក់វិញ?

ហឿនៈ ទៅស្រុកត្រាំកក់ គេឲ្យឡើងធ្វើមេទ្វិញ គេឡើងសារភាព ហើយគេបានមាសមួយដំឡឹងយកទៅ គេទិញបុណ្យសក្តិធ្វើទៅ ។ មាសមួយដំឡឹងហ្នឹងឈ្មោះធួក គាត់ឈឺងាប់ ងាប់អាឌុចហ្នឹង គេយកខ្សែកទៅស្រុកទៅ ។

ដានី៖ គាត់អត់នៅក្នុងព្រៃតស៊ូ គាត់ទៅស្រុកវិញ?

ហឿន៖ អត់ទេ! គាត់ទៅស្រុកឆ្នាំ៨០ ។

ដានី៖ កាលនៅត្រាំកក់គាត់ធ្វើអី?

ហឿន៖ អាឌុចហ្នឹងធ្វើធំណាស់ មេនគរបាលតំបន់ ដល់ទៅស្រុកគេឲ្យឡើងសារភាពហ្នឹង គេដឹងឈ្មោះវា ។

ដានី៖ គេអត់ធ្វើបាបដែរ?

ហឿន៖ អត់ ។

ដានី៖ កាលអ៊ំទៅប្រជុំថាប្រុងសម្លាប់ឈ្មោះយន់ កាលប្រជុំហ្នឹងអ៊ំមានតួនាទីអី?

ហឿន៖ អត់ទេ! កាលនៅឃួនអត់ចូលមាននាទី ដល់ទៅក្នុងព្រៃអត់មានអីទាំងអស់ ។

ដានី៖ ម៉េចបានអ៊ំទៅប្រជុំជាមួយគេ?

ហឿន៖ គេនៅតែហៅធ្លាប់មានមុខមានមាត់នឹងគ្នា គេហៅទៅប្រជុំធ្វើការ ។

ដានី៖ ជាមួយតានាងហ្នឹង?

ហឿន៖ បាទ!

ដានី៖ តានាង គាត់មានតួនាទីអនុតាជឹម?

ហឿន៖ តានាងប្រធានរោងចក្រជប់ ហើយតាឌុន ហ្នឹងកងទ័ពកងវរៈ,តាឌុច ហ្នឹងប្រធានមូលដ្ឋានភ្នំពេជ្រ ។

ដានី៖ ភ្នំពេជ្រនៅ...?

ហឿន៖ ភ្នំពេជ្រ ជប់ហ្នឹង ។

ដានី៖ អីចឹងគាត់ផ្លាស់ចេញពីនគរបាលនៅត្រាំកក់ហ្នឹងហើយ?

ហឿន៖ មកជាមួយតាជឹមហ្នឹង ។

ដានី៖ បាទ! យល់ហើយ ។ ដល់អីចឹងក្នុងចំណោមទាំងអស់ហ្នឹង អ៊ំមានតែម្នាក់ឯងទេជំទាស់អត់ឲ្យសម្លាប់ យន់?

ហឿន៖ តែខ្ញុំ គេឯកភាពទាំងអស់ ដល់អីចឹងគេកន្ទ្រប់ដី គេស្រែកដូចដរី គេថាអីចឹងតើបានអត់ហៅមកហ្នឹង ។ ដល់ខ្ញុំគេប្រជុំចប់ ខ្ញុំមកកន្លែងគេឲ្យកំលាំង៣នាក់ក្មេងៗដែលយកពីខ្ញុំទៅហ្នឹងឲ្យមកសម្លាប់ខ្ញុំ ។

ដានី៖ ដោយសារអ៊ំជំទាស់ កាលហ្នឹងគាត់បាត់ប្រពន្ធគាត់ បាត់កូនគាត់ គាត់ខឹងខ្លាំង?

ហឿន៖ បាទ! គេរកសម្លាប់ ។

ដានី៖ ដល់ពេលក្មេងៗរកមកសម្លាប់អ៊ំ ហើយក្មេងៗយំ ដល់រួចទៅតាជីមមានខឹងក្មេងៗហ្នឹងទៀតដែលអត់?

ហឿន៖ នៅតែខឹង! មកសម្លាប់ខ្ញុំនៅជិតកន្លែងគាត់១០គីឡូ សម្លាប់អត់បានខ្ញុំនាំអាក្មេងរត់មកកំពង់ចាម ។ ដល់សម្លាប់អត់បានគេឲ្យកងតាគង់ហ្នឹង មកគ្នា១៥នាក់ បេ២ដើម ហើយកាំភ្លើងគ្រប់ដៃអាការ ដល់មកខ្ញុំនៅជាមួយកងទ័ពតាជុំ កងពលធំហ្នឹង ទ័ពតាជុំឲ្យទាន់ស្លឹកឈើទាំងអស់ ហើយខ្ញុំនៅអង្គុយជាមួយតាជុំដូចអីចឹង ហើយវាទៅឃើញខ្ញុំវាតំរង់បេដាក់ខ្ញុំទាំងពីរនាក់អីចឹង ហើយកាំភ្លើងអាការក៏តំរង់ដាក់ខ្ញុំ ឈរមើលសំឡក់ខ្ញុំហ្នឹង ។ ហើយខ្ញុំថាហ្វែងធ្វើអីអញ អញដឹងហ្វែងមកសម្លាប់អញ អញអត់ធ្វើកំរើក អត់ធ្វើដឹងអង្គុយមើលវាដែរ ។ ដល់ហើយមួយសន្ទុះវាចេញទៅបាត់ទៀតទៅ ។

ដានី៖ អត់ហ៊ានបាញ់?

ហឿន៖ អត់! កងពលធំវាម៉េចហ៊ាន ទ័ពគេពេញដី ។

ដានី៖ តាជុំ?

ហឿន៖ បាទ!

ដានី៖ តាជុំ កាលជំនាន់ហ្នឹងនៅណាដែរ?

ហឿន៖ នៅក្នុងព្រៃ ស្រុកស្ទឹងត្រង់ ក្នុងព្រៃចម្ការអណ្តូងហ្នឹង កោះសូទាងជើងក្នុងព្រៃ ។

ដានី៖ តែមុនហ្នឹងតាជុំ គាត់ធ្វើអី កាលមុនយួនមិនទាន់ចូល?

ហឿន៖ កងពលរហូត ទ័ព នៅធ្វើកងពលរហូត ។

ដានី៖ កងពលនៅណា?

ហឿន៖ អត់ដឹងគាត់នៅណា ដឹងតែគាត់កងពលធំ ។

ដានី៖ អ៊ំស្គាល់គាត់ពីអង្កាល់?

ហឿន៖ ស្គាល់រត់ចូលព្រៃ ហើយបានស្គាល់ ។

ដានី៖ កាលពីមុនមិនដែលស្គាល់?

ហឿន៖ អត់ទេ!

ដានី៖ អត់ដឹងគាត់នៅណា?

ហឿន៖ អត់ដឹងនៅណាទេ ។

ដានី៖ អីចឹងបកមកដល់កន្លែងអ៊ំជួបតាម៉ុកហើយឲ្យកាំភ្លើងទៅតាម៉ុក អ៊ំធ្វើអីទៀតទៅ?

ហឿន៖ ឈឺដេកពេទ្យ នៅក្នុងពេទ្យអត់ធ្វើអីទេ ។

ដានី៖ ដេកពេទ្យនៅណា?

ហឿន៖ ដេកនៅពេទ្យក-៧ ១០០១ហ្នឹង ជាប់ទន្លេល្ពៅ។

ដានី៖ ១០០១ក្រែងមិនមែនកន្លែងរបស់ តា ម៉ុក ណាអី?

ហឿន៖ តាម៉ុក នៅ១០០២ហើយ ចេញមក១០០២ តាសុន សេន នៅ១០០១ហ្នឹង។

ដានី៖ ម៉េចបានគាត់ទៅ១០០១?

ហឿន៖ គាត់ចេញពី១០០១ មកបើកច្រកថ្មីនៅច្រក១០០២ មកខាងលិចវិញ។

ដានី៖ មកបើកច្រក១០០២វិញ ១០០១ប្រគល់ពីណាទៅ?

ហឿន៖ តាសុន សេន។

ដានី៖ ប្រគល់ឲ្យទៅតាសុន សេន វិញ?

ហឿន៖ បាទ!

ដានី៖ ដំបូងបំផុត តាម៉ុក គាត់ទៅដល់១០០១?

ហឿន៖ បើកច្រក១០០១ហ្នឹង តាម៉ុកហ្នឹង។ ដល់ត្រូវកំលាំងឡើងទៅច្រើនគាត់ឲ្យតាសុន សេន ហ្នឹងនៅច្រក១០០១ គាត់ទៅបើកច្រក១០០២មួយទៀត។

ដានី៖ ហើយអីចឹងតាសុន សេន គាត់ទៅដល់ច្រក១០០១ ឆ្នាំណា?

ហឿន៖ ឡើងទៅខែ២ ឆ្នាំ៨០។

ដានី៖ តែអ៊ំឡើងទៅខែ៧?

ហឿន៖ ឡើងទៅក្រោយ ឡើង២សារ ទៅលើកក្រោយដកអស់ហើយ ឡើងទាំងអស់។

ដានី៖ ពេលហ្នឹងអ៊ំឈឺហើម?

ហឿន៖ ឈឺហើមទាំងមូលខ្លួន កំរើកអត់រួចផង។

ដានី៖ ក្រែងកាលហ្នឹងតាម៉ុក គាត់ប្រាប់ពេទ្យថាម៉េច?

ហឿន៖ តាម៉ុក គាត់អត់មានយកទៅដាក់ពេទ្យទេ ដល់ហើយគាត់ត្រូវផ្លាស់មកច្រក១០០១ទៀត គាត់ចូលសួរខ្ញុំ។

ដានី៖ ១០០២?

ហឿន៖ អ៊ឺ! ១០០២ហ្នឹង សួរខ្ញុំថាអាមួយមកដេកពេទ្យហ្នឹងម៉េចហើយ ឈ្មោះអី? គាត់ប្រាប់ថាឈ្មោះខ្ញុំហ្នឹង អីចឹងអត់នៅឈឺនៅហើម មើលអត់ទាន់ជាទេ អត់ដែលឲ្យអី តាជីម ប្រាប់ថាអត់ឲ្យមើល អត់ឲ្យថ្នាំលេបទៀត។ តាម៉ុក ថា «ហ្វែងតែងរាប់មនុស្សហ្នឹងហ្វែង

កំសាប់ដែរ ហែ្វងមើលប៉ុណ្ណឹងមិនជា» សំឡុតពេទ្យហ្នឹង ប្រធានពេទ្យ តាស៊ី និងតាលន ហ្នឹង ។

ដានី: តាស៊ី គណៈស្រុកកំពង់សៀមហ្នឹង?

ហឿន: កំពង់សៀមហ្នឹង គេមកធ្វើប្រធានពេទ្យហ្នឹង ។

ដានី: មកធ្វើប្រធានពេទ្យហ្នឹងហើយតាជឹម គាត់ធ្វើអីឡើងទៅដល់ហ្នឹង?

ហឿន: តាជឹម ចេញមក១០៨នេះ មិនដឹងមកធ្វើអីទេ ។

ដានី: ១០៨ខាងកងពល ឬស្អី? ១០៨ ឬ៨០៨?

ហឿន: ៨០៨ហ្នឹង មកមិនដឹងធ្វើអី អត់ដឹងធ្វើអី ។

ដានី: ពេលនៅហ្នឹងជួបតាស៊ី?

ហឿន: ជួបតាស៊ី គាត់និយាយប្រាប់រឿងហ្នឹងទៀត ។

ដានី: ពេលដែលអ៊ំនៅពេទ្យហ្នឹង តាស៊ី និយាយប្រាប់ហ្នឹងទៀត!

ហឿន: និយាយប្រាប់ម្តងទៀត ។

ដានី: កាលហ្នឹងជួបតាអាន អត់នៅហ្នឹង?

ហឿន: តាអាន នៅភូមិប្រជាជនហៅទន្លេល្ពៅ ។

ដានី: នៅទន្លេល្ពៅ?

ហឿន: បាទ!

ដានី: កាលហ្នឹងពេលអ៊ំនៅប្រជាជនជួបតាស៊ី ចុះតាកាន គាត់នៅហ្នឹងទៀតដែលអត់?

ហឿន: អត់ដែលជួបទេ! ជួបកាលមកដកកាំភ្លើង ដល់ឡើងទៅរំសាយទៅចែកគ្រប់ទិសទៅមិនដឹង គាត់ទៅនៅត្រង់ណា អត់ដឹង ឬតាម៉ុក រៀបឲ្យចុះមកក្នុងវិញអត់ដឹង ។

ដានី: តាស៊ី គណៈស្រុកកំពង់សៀម គាត់ធ្វើប្រធានពេទ្យនៅហ្នឹង?

ហឿន: ប្រធានពេទ្យក-៧គេហ្នឹង ។

ដានី: អ៊ំសំរាកពេទ្យហ្នឹងប៉ុន្មានខែទៅបានជា?

ហឿន: ខ្ញុំទៅដេកគ្រាន់តែគេឲ្យថ្នាំបេអងលេបបាន៣ដង ខ្ញុំនោម ខ្ញុំបត់ដៃ បត់ជើងរួច ខ្ញុំតោងគ្រែដើរចុះឡើងៗទៅជាទៅ ។ ដល់ជាខ្ញុំលែងនៅក្នុងពេទ្យហ្នឹងហើយ ខ្ញុំទៅនៅឃ្លាំងតាសុន សេន ខ្ញុំទៅចិត្តឯងទេ ពេទ្យប្រើតែធ្វើផ្ទះអត់ដឹងចាស់ដឹងក្មេងអត់ដឹងឈើ អត់ដឹងជាខ្ញុំអត់ធ្វើ ខ្ញុំទៅនៅឃ្លាំង ។

ដានី: ពេលអ៊ំមិនទាន់ជាស្រួលបួលផង ពេទ្យគេប្រើ?

ហឿនៈ គ្រាន់តែដើររួចគេប្រើឲ្យធ្វើគ្រែពេទ្យ ធ្វើផ្ទះ ។

ដានីៈ ពីណាអ្នកប្រើ?

ហឿនៈ ប្រធានពេទ្យតាស៊ី, តាជីវ៉ូ ហ្នឹង ។

ដានីៈ តាស៊ី ហើយនិងតាជីវ៉ូ?

ហឿនៈ បាទ!

ដានីៈ តាជីវ៉ូ ហ្នឹងមកពីណា?

ហឿនៈ តាលន អនុប្រធានតាស៊ី ។

ដានីៈ តាលន ហ្នឹងនៅណាពីមុន?

ហឿនៈ អត់ដឹង ។

ដានីៈ មិនមែននៅជាមួយតាស៊ីទេ?

ហឿនៈ អត់ទេ! អត់នៅជាមួយទេ នៅកន្លែងផ្សេងៗទៅជួបគ្នាហ្នឹង គេចាត់តាំងទៅ ។

ដានីៈ ដល់ពេលអ៊ំអត់នៅហ្នឹង មកនៅឃ្លាំងតាសុន សេនវិញ?

ហឿនៈ បាទ! ខ្ញុំសរសេរសំបុត្រ សុំអ៊ំ ថាអ៊ំខ្ញុំសុំទៅជួបតាម៉ុក ព្រោះតាម៉ុក ផ្តាំផ្ញើរថាឯងជាថ្ងៃណាទៅតាមអញថ្ងៃហ្នឹង ហើយឥឡូវអ៊ំឲ្យខ្ញុំទៅ ឬមិនឲ្យ សុំអ៊ំមេត្តាអនុគ្រោះខ្ញុំផង ខ្ញុំនិយាយតែប៉ុណ្ណឹង ។ ផ្ញើរទៅបាត់ ដល់ថ្ងៃក្រោយគាត់ត្រូវទៅជួបតាម៉ុក ជួបតាប៉ុលពតហ្នឹងខ្ញុំផ្ញើរសំបុត្រមួយទៀត ផ្ញើរតាមតាគង់ កងការពារតាសុន សេន ដល់គាត់ទៅបាត់ មកវិញ ខ្ញុំសួរម៉េចសំបុត្រខ្ញុំមានឲ្យតាដែរ? ថាឲ្យ គាត់មើលហើយដាក់ហោប៉ៅទៅ ដាក់ហោប៉ៅហើយចប់ អីចឹងខ្ញុំសុំអ៊ំនៅជាមួយឃ្លាំងអ៊ំផងបានទេអ៊ំ ហើយគាត់ឲ្យនៅទៅ ។

ដានីៈ គាត់អត់មាននិយាយថាគាត់បានឲ្យសំបុត្រហ្នឹងទៅតាម៉ុក អត់មាននិយាយ?

ហឿនៈ អត់បាននិយាយ, បែបតាម៉ុក មានប្រាប់មកគាត់ បានគាត់ឲ្យនៅ ។

ដានីៈ ឲ្យនៅឃ្លាំង?

ហឿនៈ បាទ!

ដានីៈ នៅឃ្លាំងធ្វើអីខ្លះទៅ?

ហឿនៈ គ្រាន់តែចែកចាយសម្ភារៈ ដឹកឲ្យទ័ពជាប់រហូត ដឹកឲ្យប្រជាជន ដឹកសុទ្ធតែឡាន ។

ដានីៈ អ៊ំស្គាល់តាសុន សេន ច្បាស់អត់?

ហឿនៈ ស្គាល់ច្បាស់ តែទើបនឹងជួបពេលឡើងភ្នំហ្នឹង ។

ដានី៖ អ៊ំអាចរៀបរាប់ពីអត្តចរិត ពីបុគ្គលិកលក្ខណៈរបស់គាត់?

ហឿន៖ អាក្រក់ណាស់ ។

ដានី៖ អាក្រក់?

ហឿន៖ សម្លាប់តែខ្មែរ ។

ដានី៖ អ៊ីចឹង?

ហឿន៖ ដូចខ្ញុំនិយាយហើយម្តងថា គុកហ្នឹងធំណាស់ ចាប់ម្តង២០០ដាក់ពេញ ពេញគុកគេ យកមីនទៅដាក់កន្លែង ដាក់កន្លែងព្រៃឬស្សី ហើយឲ្យនាំអ្នកគុកហ្នឹងដោះឲ្យទៅកាប់ឬស្សី ដល់កាប់ឬស្សីផ្ទុះមីនគ្រឹងទៅ អាណាងាប់ៗទៅ អាណាអត់ងាប់គេថែម ។

ដានី៖ នៅណាហ្នឹង?

ហឿន៖ នៅប្រក១០០១ ជិតពេទ្យកំពង់អំពិលហ្នឹង ។

ដានី៖ ឆ្នាំណា?

ហឿន៖ ឆ្នាំ៨២-៨៣-៨៤រហូត ។

ដានី៖ គាត់នៅសម្លាប់មនុស្សទៀត?

ហឿន៖ រហូត! នៅតែធ្វើអ៊ីចឹង ។

ដានី៖ មនុស្សហ្នឹងសមាសភាពយ៉ាងម៉េចបានគេឲ្យទៅធ្វើអ៊ីចឹង?

ហឿន៖ សមាសភាពអី ទ័ពតែឡើងពីក្នុងបានឆ្អឹង បានខ្លាយ បានស្បែកខ្លា បានកន្ទុយក្ងោកយកទៅលក់ឲ្យថៃ យកខោអាវ យកមុងភួយអីទៅលក់ឲ្យថៃ ចូលស្រុកថៃ ដល់អ៊ីចឹងតែចូលគេសម្លាប់ តែឃើញផ្លូវដើរគេទៅដាក់មីនស្អាត់២-៣ចម្ការ ។

ដានី៖ តាសុន សេន គាត់ដាក់ស្អាត់?

ហឿន៖ ដាក់មីនស្អាត់ ។

ដានី៖ អ៊ីចឹងគាត់ដាក់ហ្នឹង ដើម្បីកុំឲ្យទ័ពហ្នឹងយករបស់របរទៅលក់ឲ្យថៃ?

ហឿន៖ បាទ! ដាក់ឲ្យងាប់ ទៅដាន់ងាប់ ។

ដានី៖ ហើយយ៉ាងម៉េចទៀត តាសុន សេន?

ហឿន៖ ដល់អ៊ីចឹងគាត់សម្លាប់អ៊ីចឹង ដល់ចាប់យួនបានយកទៅសម្លាសន៍ហើយ យកមកដល់គុកជិតកន្លែងគាត់ហ្នឹង លែងអត់មានដាក់ខ្នោះ ខ្សែរដាក់ទាំងជើង ជើងទាំង២ដាក់ចូលក្នុងខ្នោះហ្នឹង ខ្ញុំទៅនោមលួចមើលឃើញ ។

ដានី៖ អ៊ីចឹងយួនមានចាប់បានដែរពេលនៅ១០០១?

ហឿនៈ យួនហ្នឹងលាវចាប់បានយកមកជូនឲ្យតាខៀវ, តាសុន សេនហ្នឹង ។

ដានីៈ យួនចាប់បានប៉ុន្មាននាក់?

ហឿនៈ ចាប់បានតែម្នាក់ហ្នឹង គេវាយបែកក្បាលសសំពោងអស់ហើយរុំ ។

ដានីៈ យួនលាវចាប់បានប្រគល់ឲ្យតាសុន សេន?

ហឿនៈ ចាប់ឲ្យទៅតាសុន សេន ។ វាសុំបាយលាវស៊ី លាវចាប់បានវាយបែកក្បាលអស់ ។

ដានីៈ ហ្នឹងយួន?

ហឿនៈ យួន ។

ដានីៈ យួនហ្នឹងជាស្អី ជាប្រជាជន ឬកងទ័ព?

ហឿនៈ ទ័ពៗយួននៅស្រុកលាវ ទ័ពហ្នឹងនៅលាវ ។

ដានីៈ ដល់ចាប់ឲ្យតាសុន សេនៗ សួរចំលើយ ។

ហឿនៈ សួរចំលើយ ធ្វើឲ្យសម្ភាសន៍អីៗ ។

ដានីៈ ដល់ពេលរួចទៅប្រលែង?

ហឿនៈ ដល់គាត់ដឹកមកកន្លែងគាត់ គាត់ឲ្យនៅក្នុងគុកក្មួយខ្ញុំអាហួនហ្នឹង វាថាយកយួនទៅលែង ហើយខ្មែរដាក់គុកអត់មានឲ្យរួចទេ ។

ដានីៈ រួចម៉េចទៀតទៅ?

ហឿនៈ ដល់ពេលពេញគុក គេយកមីនទៅដាក់ ហើយបានលែងឲ្យទៅកាប់ឬស្សីកន្លែងដាក់មីនហ្នឹង ។ មីន៦៩ដាក់ទៅផ្ទុះដូចច្បាំងគ្នាចឹង ងាប់! អាណាអត់ងប់នៅបាក់ដៃបាក់ជើង គេបាញ់ថែម រហូតដល់ពេញគុកគេធ្វើចឹងទៀត រហូតទាល់តែយួនចូល ។

ដានីៈ បាទ! ចុះយួនម្នាក់ហ្នឹងយ៉ាងម៉េចទៅ?

ហឿនៈ រត់ទៅស្រុកវាបាត់ទៅ ។

ដានីៈ រត់ពេលណា?

ហឿនៈ ទៅបាន២ថ្ងៃ ៣ថ្ងៃ វារត់ទៅបាត់ទៅ ។

ដានីៈ ចុះម៉េចបានអ៊ីដឹងថាវារត់?

ហឿនៈ ឪមិនដឹង បើក្មួយខ្ញុំនៅកន្លែងជិតគ្នាហ្នឹង ។

ដានីៈ ចុះអត់មានពីណាហ៊ានសួរគាត់ទេ? មានសួរតាសុន សេនទេ?

ហឿនៈ អត់មានទេ! មាននរណាហានសួរ មាននរណាទៅហ៊ានចូលទៅជិតកន្លែងគេ ។

ដានីៈ អ៊ឹមានប្រសាសន៍កាលពីម្សិល ថាម៉េចពីណាទៅសួរហើយក៏គាត់សំឡុតថាមិត្តញ៉ាន់...?

ហឿនៈ អាហ្នឹងខ្ញុំដឹកអង្ករទៅចែកប្រជាជន ដឹកទៅចេញផុតពីឃ្លាំង យួនមួយក្រុមលោតភ្ជួនៗ រំលងផ្លូវ ខ្ញុំទៅដល់សួរថាអ៊ីខ្ញុំឃើញយួនមួយក្រុមលោតមកចំកន្លែងអ៊ី យើកុំបំផុសបំផុល មិត្តញ៉ាន់ការពារបានហើយ អត់មានយួនទេ គាត់ថាចឹង ។

ដានីៈ មិត្តញ៉ាន់មួយណា?

ហឿនៈ គាញ៉ាន់! កងពលនៅកោះកុងហ្នឹង ។

ដានីៈ អូ! គាញ៉ាន់ហ្នឹង អនុតាមុតហ្នឹង?

ហឿនៈ មិត្តញ៉ាន់ គាត់នៅការពារព្រំដែនដែលផ្លូវច្រកឡើងភ្នំដងរែកហ្នឹង ឡើងអត់រួចមានផ្លូវតែមួយហ្នឹង គាញ៉ាន់ ។

ដានីៈ ដល់ចឹងគាត់ថាកុំមកបំផុសបំផុល គាញ៉ាន់ហ្នឹងការពារអត់ឲ្យចូលទេ?

ហឿនៈ ថាគាញ៉ាន់ការពារច្រកហ្នឹងបានហើយ អត់ឲ្យមានយួនឡើងទេ ប៉ុនរទេះគោទៅបន្តគ្នាឡើងហើយ ។ រទេះគោទៅដឹកជ័យភ័ណ្ឌខ្មែរក្រហមហ្នឹង ។

ដានីៈ ប៉ុន្តែ អ៊ំឃើញយួនច្បាស់?

ហឿនៈ យួន! អត់មានឃើញទេ ឃើញតែអាចាប់មកសម្លាប់ហ្នឹងឃើញ ។

ដានីៈ ប៉ុន្តែអ៊ំប្រាប់គាត់ថាយួនលោតផ្លោតៗម៉េចនោះ?

ហឿនៈ កាលហ្នឹងឃើញវាលោតភ្ជួនៗមុខឡានហ្នឹង ។

ដានីៈ វាលោតមកធ្វើអីគេ?

ហឿនៈ យួនហ្នុងវាកាំភ្លើងគ្រប់ដៃ វាលោតសម្រុកចូលមកកន្លែងតាខៀវហ្នឹង ។ ហើយទៅដល់កន្លែងតាខៀវ ខ្ញុំចូលប្រាប់ ប្រាប់ទៅ គាត់ថាកុំផុសបំផុលអត់មានយួនទេ មិត្តញ៉ាន់ការពារបានហើយខាងមុខ ដល់តែខ្ញុំត្រឡប់ទៅឡើងឡានវិញបើកអង្ករយកទៅឲ្យប្រជាជនជួបគាត់ ជួបយួនមួយក្រុមទៀត លោតចូលក្បែរផ្ទះហ្នឹង ខ្ញុំត្រឡប់មកវិញទៀត ថាអ៊ំខ្ញុំឃើញយួនលោតមិញនៅអូរប្ញស្សីហ្នឹង លោតចូលមកចំកន្លែងអ៊ឹងហើយ អត់ទេកុំបំផុសបំផុល គាត់ថាចឹងទៀត ខ្ញុំលែងប្រាប់ ។ ដល់ខ្ញុំមកដល់ផ្ទះស្អែកឡើងវាងងឹតដីបាញ់ ។

ដានីៈ យួនបាញ់?

ហឿនៈ បាញ់!

ដានីៈ បាញ់គាត់?

ហឿនៈ បាញ់ពួកលាវចេញ ចេញពីលាវមកបាញ់ ពួកលាវតស៊ូហ្នឹង បាញ់និយាយពីស្លាប់អី អត់ព្វទេ ។ ១៣០, ១០៥, ធ្លាក់តែមួយគ្រឹង៣៧គ្រប់ ។ កន្លែងឃ្លាំងខ្ញុំនេះ បើកភ្នែក អត់រួចទេ ហុយ ។

ដានីៈ ប៉ុន តាខៀវអត់ត្រូវអីទេ?

ហឿនៈ តាខៀវយំអត់ចេញទឹកភ្នែក ។

ដានីៈ ម៉េចបានយំអត់ចេញទឹកភ្នែក?

ហឿនៈ តាឃីគាត់នៅចាំផ្លូវចូលនៅក្បែរផ្ទះគាត់ ផ្លូវជីកស្បៀង, តាឃីហ្នឹងមានកាំភ្លើង... ។

ដានីៈ អូ! តាឃី មិនមែនតាខៀវទេ?

ហឿនៈ តាឃីហ្នឹងមេទ័ពប៉ូលីស ហើយតាសុន សេនហ្នឹងឈ្មោះ តាខៀវហ្នឹង ។

ដានីៈ តាសុន សេនហ្នឹងអត់ ម៉េចពេលដែលយួនហ្នឹង យួនអត់ចាប់គាត់អត់បាញ់គាត់ទេ?

ហឿនៈ ចាប់ម៉េចបានបើទ័ពការពារចូលគាត់មិនដល់ផង ។

ដានីៈ ហើយ តាសុន សេនហ្នឹងត្រូវជាមួយយួន ឬក៏យ៉ាងម៉េច?

ហឿនៈ ទេ! បាត់តាំងពីហ្នឹងមក ដល់ទាក់ទងតាឃី តាឃីប្រាប់ថាអីខ្ញុំទប់ទល់លែងបានហើយ គោងស្មៅអាកូន! អត់មានស្មៅគោងទេ គោងគល់ឬស្សី អត់មានគល់ឬស្សីទេផ្ទុះអស់ ហើយ ដាច់បានអស់ហើយ ហើយកន្លែងគាត់ក៏ដាច់ ។

ដានីៈ តាឃីហ្នឹងរាយការណ៍ប្រាប់សុន សេន?

ហឿនៈ បាទ! ប្រាប់ ប្រាប់ថាអីឯងចេញមិនចេញ បើអត់ចេញខ្ញុំទៅហើយ ដល់តាសុន សេន ទាក់ទងមកតាឃី តាឃីលែងមាត់ត ដល់លែងមាត់ត បានតាខៀវចេញ ដល់តាខៀវ ចេញ បានតាឃីសួរទៀតបាត់ បាត់តាឃីរត់តាម តាមកំពុងដើរទៅតាមផ្លូវទៅត្បូង ទៅដល់ភូមិទន្លេល្ពៅមានមនុស្សឯណា យួនគៀរយកអស់ ដឹកសម្ភារៈសុទ្ធតែរទេះគោ ។

ដានីៈ អីចឹងរត់ទៅណាទៅ?

ហឿនៈ រត់ចេញមកដើរមកមួយខែបានដល់ដីថៃ មកដល់ដីថៃប្រជាជនចេញទៅនៅដីថៃហ្នឹង ហៅឡានថៃអា១២បាំងមកដឹកទៅច្រក១០០១ កន្លែងតាម៉ុក, ១០០២ហ្នឹង រឿងហ្នឹង ចប់ត្រឹមហ្នឹងអស់ហើយ ។

ដានីៈ បាទ! ហើយកាលហ្នឹងថាលាវដែលចាប់ឲ្យហ្នឹងលាវក្រហម?

ហឿនៈ លាវក្រហម អាលាវចេញមកតស៊ូហ្នឹង ។

ដានីៈ លាវតស៊ូប្រឆាំងជាមួយរដ្ឋាភិបាលលាវវិញហ្នឹង?

ហឿនៈ អាប្រឆាំងចេញមកគស៊ូហ្នឹង អាលាវសនៅខាងក្នុង។

ដានីៈ បាទ! ចុះអ៊ីពេលដែល អ៊ីចឹងដល់ពេលរត់ចូលដៃថៃអី កាលហ្នឹងតាអានអីគាត់ទៅនៅឯណា?

ហឿនៈ នៅជាមួយគ្នាដល់រត់ទៅហ្នឹងដែរ។

ដានីៈ ដល់ថៃដែរ?

ហឿនៈ បាទ! ទៅនៅម្ដុំហ្នឹងទាំងអស់ មនុស្សរាប់ម៉ឺន។

ដានីៈ ហើយម៉េចទៅ ចេញពីហ្នឹងទៅអ៊ីទៅនៅណា?

ហឿនៈ ដល់ឡើងឡានទៅច្រក១០០២ កន្លែងតាម៉ុកហ្នឹង យកប្រជាជនទៅដាក់ហ្នឹង សរុបធ្វើបញ្ជីកំលាំងខ្ញុំមាន៥ម៉ឺននៅសល់១ម៉ឺន។

ដានីៈ ម៉េចចឹង?

ហឿនៈ ងាប់អស់! សុទ្ធតែក្បាលតាខៀវដើរទៅ ដើរជាន់តែក្បាលខ្មែរ។

ដានីៈ នៅណា ស្លាប់នៅណា?

ហឿនៈ ស្លាប់នៅទន្លេល្អៅ នៅភូមិ នៅក្នុងព្រៃតែអត់ដឹងថាព្រៃស្អីទេ។

ដានីៈ ស្លាប់ដោយសារមូលហេតុអី?

ហឿនៈ យួន អាថៃក្រហម វានាំយួនមកវាយខ្មែរ វាយពួកប៉ុល ពតហ្នឹង សុទ្ធតែថៃ។

ដានីៈ ថៃក្រហមហ្នឹងវាត្រូវជាមួយយួន?

ហឿនៈ បាទ! នាំយួនមកវាយ ហើយដូចថាផ្លូវហ្នឹងអត់មីនវាកាច់ស្លឹកឈើគ្រប វានៅឈរចាំហើយវាថាកុំចុះផ្លូវហ្នឹងមីន ទៅពុំបានទេ រត់ទៅផ្លូវនោះ ផ្លូវនោះយួនយាម ត្រៀមនៅហ្នឹង គ្រាន់តែដើរទៅដាក់រូវមកខ្ទេច។

ដានីៈ ថៃក្រហមហ្នឹង?

ហឿនៈ ថៃក្រហម វាគ្រាន់តែនាំផ្លូវ អាយួនវាអ្នកបាញ់។

ដានីៈ អាថៃក្រហមវាអ្នកបញ្ឆោត?

ហឿនៈ បាទ! បញ្ឆោតផ្លូវនេះទៅមិនបានទេគេចាប់ ផ្លូវហ្នឹងទៅមីននៅច្រើនណាស់ ទៅផ្លូវនេះបានអត់អី អត់មីនមែន ប៉ុន្តែយួនត្រៀមផ្លូវអស់ ទៅផ្លូវវាបាញ់ងាប់អស់។

ដានីៈ ៥ម៉ឺន! នៅសល់តែ១ម៉ឺន។

ហឿនៈ សល់តែ១ម៉ឺន។

ដានីៈ ពេលដែលចូលដីថៃហើយ នៅជាមួយតាម៉ុក១០០២វិញ?

ហឿនៈ នៅជាមួយតាម៉ុក ១០០២ ។

ដានីៈ ឆ្នាំណា?

ហឿនៈ អាហ្នឹង៨៥ ហើយចូល៨៥ ។

ដានីៈ ចូល៨៥ ហើយហ្នឹង?

ហឿនៈ ទៅដល់ហ្នឹង បារាំងដឹកឥវ៉ាន់យកចាក់ចូល ។

ដានីៈ អីចឹង១០០១ហ្នឹងត្រូវបាត់បង់អស់ហើយ?

ហឿនៈ អស់ហើយ! ខ្ទេចហើយ ប៉ុន្តែតាញ៉ាន់នៅការពារច្រកហ្នឹងយួនចូលអត់បាន វាអស់យួនទៅបាញ់ៗងាប់អស់ កន្លែងមុខតាខៀវនោះគដូចភ្នំ ទៅខាងផ្លូវសុទ្ធតែមីន ទៅខាងសុទ្ធតែមីន មកដាក់សុទ្ធតែខ្ទូសេត អត់មានអាការទេ ហើយនិងបេ ។

ដានីៈ តាញ៉ាន់ បាញ់?

ហឿនៈ កងតាឃីហ្នឹង តម្រួត បាញ់ងាប់គរដូចភ្នំ វាហែរដូចបុណ្យកឋិនមក ។

ដានីៈ អ៊ូ! បាញ់យួនងាប់គដូចភ្នំ?

ហឿនៈ បាទ!

ដានីៈ ចឹងអ៊ី! ១០០១ បាត់បង់ឆ្នាំ៨៥?

ហឿនៈ ៨៥! ថ្ងៃ១ ថ្ងៃ២ហ្នឹង រត់ចោលកន្លែង ។

ដានីៈ ខែប៉ុន្មាន?

ហឿនៈ អាហ្នឹង៨៥ហ្នឹងចូល៨៥ ខែ១ ខែ២ហើយ កាលពីវាកំពុងតែវាយហ្នឹងនៅក្នុងឆ្នាំ៨៤ ។

ដានីៈ បាទ! ដល់ពេលអីចឹងអ៊ីទៅដល់ទឹកដីថៃបានប៉ុន្មាន បានចូលមក១០០២ជាមួយ តាម៉ុកវិញ?

ហឿនៈ ទៅចូលដីថៃដេកបាន១ខែ តាសុន សេន ចេញមកពីព្រៃមកដល់ឃើញ ឃើញប្រជាជនគេនាំមកកន្លែងប្រជាជនដែលរត់ពីសមរភូមិ គាត់ទាក់ទងឡានថៃមកដឹកទាំងថ្ងៃហ្នឹងដឹកទៅកន្លែងតាម៉ុក ។

ដានីៈ ដឹកទៅទាំងអស់?

ហឿនៈ បាទ!

ដានីៈ កាលហ្នឹងតាអានអីនៅហ្នឹងដែរអត់ទេ?

ហឿនៈ ទៅជាមួយគ្នា តាអាន មកដល់ថៃហ្នឹងជាមួយគ្នា ។

ដានីៈ ដល់ដីថៃហើយចូលមកជាមួយតាម៉ុក តាអានមកជាមួយទាំងអស់?

ហឿន៖ រត់មកទាំងទ័ព ទាំងអីហ្នឹង ទាំងប្រជាជន ប្រជាជនភូមិទន្លេល្ពៅឡើងមកទាំងអស់ ។

ដានី៖ ហើយដល់ពេលមកដល់កន្លែងតាម៉ុក ម៉េចទៀតទៅអ៊ី?

ហឿន៖ ដល់កន្លែងតាម៉ុក មកដល់មិនទាន់បានធ្វើរោងបាននៅធ្វើផង យួនផ្ទោងដាក់ទៀត ។

ដានី៖ ផ្ទោងរត់ទៅណាវិញទៅ?

ហឿន៖ ដល់ផ្ទោងដាក់ទៀតរត់ចេញមកក្រោយ មកដីថៃទៀត រត់មកដល់ដីថៃវាផ្ទោងដាក់ដីថៃទៀត នាំគ្នាក្រាញនៀលនៅហ្នឹងមិនដឹងទៅណាទៀត គេហៅដងទង់ៗ ។

ដានី៖ ដងទង់ដីថៃ?

ហឿន៖ បាទ!

ដានី៖ ចឹងពេលដែលឆ្នាំ ៨៥ហ្នឹង អា១០០២ ក៏យួនយកបានដែរ?

ហឿន៖ បាន!

ដានី៖ យកបានទាំងអស់អីចឹង?

ហឿន៖ បាទ! ១០០០កន្លែងតាម៉ុកនោះក៏យកបាន ។

ដានី៖ ១០០៣ហ្នឹង!

ហឿន៖ ១០០៣ហ្នឹង,១០០១ ។

ដានី៖ ១០០១,១ ០០២, ១០០៣, ៨០៨ក៏យកបានដែរ?

ហឿន៖ បាទ! យកបានទាំងអស់ហើយ ។

ដានី៖ យកបានទាំងអស់អីចឹង? យួននៅទាំងអស់?

ហឿន៖ យួននៅទាំងអស់ ។ ខ្មែរចូលដីថៃក្នុងជំរំទាំងអស់ បារាំងផ្តល់គ្រប់សព្វទាំងអស់ ។

ដានី៖ អីចឹងពេលនេះអ៊ំនៅដងទង់ហ្នឹង រយៈពេលប៉ុន្មានទៅបាន...?

ហឿន៖ នៅរាប់ខែ រាប់ឆ្នាំយូរណាស់, ផ្លាស់ពីកន្លែងហ្នឹង តែបារាំងចូលដល់កន្លែងហ្នឹង តាម៉ុកដេញពីកន្លែងហ្នឹងទៅនៅត្រង់នោះហើយកាត់ឈើផ្លូវអត់ឲ្យឡានទៅរួច ហើយាយៗ ចេះតែថារត់យួនពួនបារាំងៗ ហើយខ្ញុំថាម៉េចយាយ រត់យួនពួនបារាំងហ្នឹង? ចុះមិនមើលបារាំងដឹកអីយកមកចាក់ តាម៉ុកដេញប្រជាជន ឲ្យផ្លាស់កន្លែងទៅនៅផ្សេង អាហ្នឹងគាត់ចេះតែដើរស្រែក រត់យួនពួនបារាំង ។

ដានី៖ បារាំងដឹកអីយកមក?

ហឿន៖ ដឹកអង្ករ គ្រាប់សណ្តែក ស្ករសរ បន្លែគ្រប់មុខសព្វទាំងអស់ ។

ដានី៖ ប៉ុន្តែដល់ពេលដឹកមក តាម៉ុក អត់ឲ្យយកទេ?

ហឿនៈ ឲ្យអី! យកមកចាក់ចោលដូចភ្នំនៅហ្នឹង គ្រាន់តែចាក់ចោលហើយរត់ទៅផ្លាស់កន្លែងទៀតហើយកប់ឈើលប់ផ្លូវអត់ឲ្យបារាំងទៅរួច ហើយបារាំងវាចូលពីកន្លែងក្រោយទៅដាក់នៅហ្នឹងទៀតរត់ចេញពីហ្នឹងទៀត ។

ដានីៈ តាម៉ុក ខ្លាចបារាំងមកយកប្រជាជនទៅអស់ ឬក៏យ៉ាងម៉េច?

ហឿនៈ ខ្លាចបារាំងយកប្រជាជន ។

ដានីៈ អីចឹងគាត់ចេះតែអត់ឲ្យបារាំងនេះ ដើម្បីគាត់បានប្រជាជន?

ហឿនៈ គាត់អត់ឲ្យបារាំងមកជួប អត់ឲ្យបារាំងចិញ្ចឹម ហើយដល់អាឆ្នាំ៨៨ សកលលោកគាបសង្កត់ ខ្ញុំដឹងនៅជាមួយតាម៉ុកហើយកាលហ្នឹង នៅស្រោចដើមម្រេច គាត់ដាំម្រេចភូមិអូរតាចក់ ស្រោចម្រេច ពួកគាត់ហៅកងពលគ្រប់កងពល គ្រប់អង្គភាពទាំងអស់មក មកម្នាក់ប្រាប់ថា ឥឡូវដឹកប្រជាជនចូលជំរំ សកលលោកគាបសង្កត់គាត់ហើយ គ្រាន់តែថាប៉ុណ្ណឹងឲ្យទៅវិញ មកមួយទៀតប្រាប់ម្នាក់អីចឹង ២នាក់មកអីចឹង ប្រាប់ អត់មានមកជួបជុំគ្នាទេ...សកលលោកគាបសង្កត់ថា ឲ្យតាម៉ុកនាំទ័ពនាំប្រជាជនចេញឲ្យផុតពីដីថៃ២៤ម៉ោងឲ្យចេញឲ្យផុត បើចេញមិនផុតទេ គេកំទេច ដល់ថាអីចឹងតាម៉ុកដឹកប្រជាជនយកមកដាក់ជំរំអូរត្រាវឲ្យបារាំងរាប់ ចូលហើយចូលពេលហ្នឹងហើយ ។

ដានីៈ ៨៨?

ហឿនៈ ដឹង៨០ប៉ុន្មានទេ! បារាំងចិញ្ចឹមបានពីរឆ្នាំ ចិញ្ចឹមហើយបារាំងដឹកយកមកប្រគល់ឲ្យ ហ៊ុន សែន អស់មក ទ័ពហ្នឹងគេបែកាណុងដាក់វិញ ។

ដានីៈ អីចឹងអ៊ំចេញមកខាងក្នុងវិញ បារាំងដឹកមកទីណា?

ហឿនៈ ខ្ញុំអត់មកក្នុង ខ្ញុំមកនៅដីនៅអន្លង់វែងតាម៉ុករហូត ។

ដានីៈ នៅរហូតដល់ឆ្នាំណា?

ហឿនៈ រហូតដល់ឆ្នាំ៨៩, ៨៩ខ្ញុំសុំគេមកនៅអូររថក្រោះនេះឯង ។

ដានីៈ ម៉េចអីចឹង ម៉េចបាន៨៩ចេញមកណោះ?

ហឿនៈ ៨៩ខ្ញុំចេញមកហើយ ។

ដានីៈ អីចឹង៨៩ អត់បានចុះមកនៅអន្លង់វែងទេ?

ហឿនៈ អត់ទេ! អត់បានមកអន្លង់ទេ ចេញពីអូរត្រាវឡើងឡាន, ឡើងឡានឆ្នាំ៨៩ សោម ជន នេះគេទៅយកមកដាក់នៅឡាក់៧០ ។

ដានីៈ ចុះម៉េចបានអ៊ំមកនៅនេះ ដោយសារ...?

ហឿនៈ ដល់ហើយមកនៅអូររជៅក្រោះអត់មានដីស្រែ ខ្ញុំសុំតាជនមកដល់ទីនេះបានមានដីស្រែ ។

ដានីៈ ម៉េចបានអ៊ីផ្លាស់ពី៨៩ ផ្លាស់ពីកន្លែងតាម៉ុក មកនៅអូររជៅក្រោះវិញ?

ហឿនៈ តាម៉ុក ដឹកចូលដំរំថាអាក្បាលសឲ្យចូលដំរំ អាខ្មៅនៅច្បាំង នៅវាយយួន ហើយខ្ញុំអាក្បាលសជិះឡានមកនៅអូរគ្រាវឲ្យបាររាំងរាប់ទៅ ។

ដានីៈ រួចទៅតាជន សោម ជន នេះទៅយក?

ហឿនៈ តាជននៅអូរឡាក់៧០នេះ គេទៅលេងដំរំ ខ្ញុំថាអូនឲ្យអញទៅនៅជាមួយអូនឯងផងទៅ អញអស់អីទីពឹងហើយ ថាចាំមើលតិចទៀត ដល់អត់បានមួយខែផងឃើញឡានគេទៅយក ខ្ញុំក៏មកជាមួយគេមក ។

ដានីៈ កាលហ្នឹងអ៊ំនៅជាមួយតាម៉ុកអត់មានការងាររតួនាទីអីទេ?

ហឿនៈ អត់ទេ! មានអីទេ សុទ្ធតែប្រជាជនទាំងអស់ មានណាមាននាទីតំណែងអីអត់ទេ!

ដានីៈ អីចឹងដល់ពេល៨៩អ៊ំមកនៅនេះ?

ហឿនៈ មកនៅឡាក់៧០ ។

ដានីៈ ឡាក់៧០នៅឯណា?

ហឿនៈ នៅខាងលិចអូររជៅក្រោះដីថៃ ។

ដានីៈ ដល់ពេលនៅបានប៉ុន្មានទៅបានចូល...?

ហឿនៈ ខ្ញុំមកនៅឡាក់៧០ហ្នឹងបាន១អាទិត្យ បាន១អាទិត្យ បានចុះមកនៅអូររជៅក្រោះ នៅអូររជៅក្រោះបានដល់ឆ្នាំ៩២គេរៀបចំបោះឆ្នោត គេរៀបចំបោះឆ្នោត៩៣ហ្នឹង គេចេញចូលៗពីក្នុងទៅក្រៅ ពីក្រៅមកក្នុង ចេញចូលបាន សុំគេមកនៅតាសាញនេះធ្វើស្រែ នៅនោះអត់ស្រែមានតែដីចម្ការ ។

ដានីៈ ចុះអ៊ំជួបអ៊ំស្រីកូនចៅឆ្នាំណា?

ហឿនៈ អ៊ំស្រីហ្នឹង ខ្ញុំនៅភ្នំដងរែក ខ្ញុំនៅឃ្លាំងតាខៀវហ្នឹង ជួបនៅ៨៤នេះ ប៉ុនចូលជិតដាច់ហើយ, ៨៤ ដល់ជួបយាយហ្នឹងធ្វើផ្ទះមិនទាន់ហើយផង យួនវាយ៨៥ហ្នឹងខែ១ ខែ២វាយហើយ ។

ដានីៈ អីចឹងអ៊ំស្រីទៅដល់ស្រុកកំណើតហើយ គាត់ត្រឡប់មកវិញ?

ហឿនៈ បាទ! មកវិញ ។ ទៅដល់គេរករឿងថាបាត់ប្ដី មានតែប្ដីធ្វើទ័ព ប៉ុល ពត អីចឹងគេរកចាប់ រកចាប់គាត់មកដេកនៅភ្នំពេញ១ឆ្នាំទៀត ។ មកដេកនៅភ្នំពេញមាឆ្នាំគេតាមមក

មើល ថាអត់ឃើញមានប្ដីទៀត អត់មានប្ដីអាតក់នេះប្អូនយាយហ្នឹង គេមានម៉ូយគេពីជំរំ ទៅរកកំលាំងនាំចេញ កំលាំងទៅក្រៅវិញ អីចឹងនាំកូននាំចៅឡើងមកយប់ ។

ដានី៖ ឆ្នាំណា?

ហឿន៖ អត់ដឹងឆ្នាំ យាយខ្ញុំគេចេញទៅជួបខ្ញុំក្នុង៨៤ ជិត៣០ហើយ ជិតដាច់ហើយ ។

ដានី៖ ៨៤ ជិតដាច់ហើយ?

ហឿន៖ បាទ!

ដានី៖ ទៅជួបនៅខាង...?

ហឿន៖ ជួបនៅ ក-៧, ១០០១ ។

ដានី៖ គាត់ទៅរកឃើញ?

ហឿន៖ ទៅរកឃើញ ទៅវេនផ្លូវ ឡានដឹកអង្ករទៅឲ្យច្រក១០០១ហ្នឹងហីតាម៉ុកផ្ញើរពួកគ្រួសារ ហ្នឹងវាមាន២០គ្រួសារ ឡានដឹកទៅ វាវេនផ្លូវកន្លែងតានេះ ទៅចូលកន្លែងតា សុន សេន ហ្នឹង ។ ហើយខ្ញុំអត់ដឹងគេទៅទេ ព្រឹកឡើងខ្ញុំរៀបអីវ៉ាន់ ពីល្ងាចរៀបម្ដងនៅសល់ពេញដីលើកដាក់ក្នុងឃ្លាំងហើយអស់ ម៉ោង៩ខ្ញុំចេញមកយាយខ្ញុំនៅក្បែររបង ។

ដានី៖ អីចឹងដល់ពេលអីផ្លាស់មក១០០២ ជាមួយតាម៉ុក មកជាមួយយាយកូនចៅ ហីត្រឡប់មកអូររជក្រោះនេះក៏មកជាមួយគ្នាទាំងអស់គ្នាដែរ?

ហឿន៖ មកជាមួយទាំងអស់! ជួបគ្នាហើយបានមក ។

ដានី៖ មកដំបូង មកនៅឯអូររជក្រោះ?

ហឿន៖ បាទ! ចេញពីអូររជក្រោះបានមកនៅឯនេះ មកនៅឆ្នាំ៩១ហើយ គេរៀបបោះឆ្នោតហើយ ។

ដានី៖ កាលហ្នុងគណៈសមរភូមិនៅសំឡូតនេះពីណាខ្លះទៅ?

ហឿន៖ តាម៉េតធំជាងគេ ។

ដានី៖ តាម៉េតធំជាងគេបន្ទាប់មក បន្ទាប់ពីតាម៉េតពីនណាគេ?

ហឿន៖ បន្ទាប់ពីតាម៉េត តាសោម ជន គេខាងត្រួតត្រាលើដីត្បូង ។

ដានី៖ ចុះតាទិត?

ហឿន៖ តាទិត នៅខាងសែនចៅ ប៉ុនគេគ្រប់គ្រងនៅលើដីត្បូងហ្នឹងដែរ តាជន អនុ តាទិតប្រធាន ។

ដានី៖ អាហ្នឹងគេហៅសមរភូមិលេខប៉ុន្មានដែរនៅនេះ?

ហឿនៈ អត់ដឹងទេ! គេថាច្រកកោះកុង១ គេអត់ថាលេខ។

ដានីៈ អានេះច្រកកោះកុង ឬក៏ច្រក...?

ហឿនៈ បាទ! ពីត្រឹមប៉ៃលិនទៅទល់កោះកុង-កំពង់សោម នាទីរបស់តាម៉ុត, ពីប៉ៃលិនទៅទល់រតនៈគីរី នាទីរបស់តាម៉ុក គឺគាត់ចែកគ្នាពេលដែលគាត់ដាច់ដើងហើយហ្នឹង។

ដានីៈ អីចឹងពីប៉ៃលិនទៅដល់កោះកុងនាទីរបស់តាម៉ុត?

ហឿនៈ បាទ!

ដានីៈ មាស មុត?

ហឿនៈ មុខសញ្ញាតាមុតហើយ។

ដានីៈ ចុះតាម៉េត?

ហឿនៈ តាម៉េតនៅច្រកនេះ ច្រកអីគេហ្នឹង...អត់ដឹងទេ។

ដានីៈ ប៉ុនតាម៉េត ហើយតាមុតពីណាធំជាង?

ហឿនៈ តាម៉េតធំជាង ហ៊ូ! តាមុត ធំជាងតាម៉េត។ តាមុតក្តាប់មួយចំហៀងប្រទេសហើយ តាម៉េត ត្រឹមតែកងពល។

ដានីៈ តាម៉េត!

ហឿនៈ បាទ! តាម៉េត។ តាមុតមួយចំហៀងប្រទេសតាំងពី... កូនប្រសារតាម៉ុកពុំមែនតូចជាងគេទេ។

ដានីៈ ចុះតាទិត គាត់កាលហ្នឹង អ៊ីស្គាល់តាទិត ពេលមកជួបគាត់ដែរអត់?

ហឿនៈ មកជួបគាត់នៅឡាក់៧០ មកនៅមកចុះដល់ហ្នឹង ក៏គាត់ដើរមកដល់ហ្នឹង តាទិត។

ដានីៈ ប៉ុន្មានកងពលទៅនៅខាងហ្នឹង?

ហឿនៈ តាទិតហ្នឹង?

ដានីៈ អត់ទេ! ខ្ញុំចង់ដឹងថាពីកោះកុងទៅដល់ប៉ៃលិន មានប៉ុន្មានកងពល?

ហឿនៈ រាប់អត់អស់ទេ តាមុតហ្នឹងប្រធានធំហើយ មានកងពលអៀង ដាន មានកងពល ន៉ែ តាសួីទេភ្លេចអស់ហើយ អត់ចាំទេ កងពលតាម៉ឹង កងពលន៉ែច្រើនណាស់រាប់អត់អស់ទេ កងពលតាអីមួយទៀតទេ ភ្លេចអស់ហើយ អត់ចាំទេ ច្រើនណាស់ ច្រើនកងពល ពីហ្នឹងទៅកោះកុង រាប់អត់អស់ទេ។

ដានីៈ បាទ! ច្រើនណាស់ណ៎។ ហើយចុះអ៊ីមកដល់នេះនៅឆ្នាំ៩២ នៅនេះរហូតម៉ង?

ហឿនៈ បាទ!

ដានី៖ ហើយចុះដីអ៊ំ ពីត្រឹមណាទៅ ពីឆ្នាំ៩៧?

ហឿន៖ ដីខ្ញុំត្រឹមផ្លូវហ្នឹងទៅទល់ញ៉ាបមុខផ្ទះខ្ញុំ របងវត្តពីខាងត្បូង ហើយតាមុតយកធ្វើនៅសល់ដីកូនខ្ញុំ អានេះខ្ញុំមកនៅដីកូនហ្នឹង ។

ដានី៖ ដីអ៊ំអស់រលីង?

ហឿន៖ គេយកទាំងអស់ ។

ដានី៖ គេយកឆ្នាំណា?

ហឿន៖ ឆ្នាំ២០០០ ។

ដានី៖ ពីណាអ្នកយក?

ហឿន៖ តាមុត ឲ្យមេឃុំគៀបកខ្ញុំឲ្យខ្ញុំប្រគល់ដី ។

ដានី៖ មេឃុំពីណាគេ?

ហឿន៖ មេឃុំហ្នឹងជំទប់លេខ១ គេអ្នកមក ឈ្មោះតាម៉ៃ នាមត្រកូលមិនដឹងឈ្មោះអី ជំទប់លេខ១អាហ្នឹង

ដានី៖ គេយកដីអ៊ំធ្វើអី?

ហឿន៖ យកដីធ្វើវត្តហ្នឹង ធ្វើរាល់ថ្ងៃ អត់ឲ្យថ្នូរអត់ឲ្យអី ។

ដានី៖ ដីវត្តទាំងអស់ហ្នឹង ជាដីរបស់អ៊ំទាំងអស់ ឬក៏ដីរបស់អ៊ំមួយចំណែក?

ហឿន៖ ដីកូនខ្ញុំពីរនាក់ហើខ្ញុំម្នាក់វាបី ប៉ុនដីហ្នឹងធំណាស់ទៅទល់របងវត្តពីខាងត្បូងមកទល់ផ្លូវហ្នឹង ។

ដានី៖ ទទឹងប៉ុន្មាន បណ្តោយប៉ុន្មាន?

ហឿន៖ អត់អីវាស់ អត់ដែលវាស់ ។

ដានី៖ ដល់ពេលគេមកយក អ៊ំមានតវ៉ាមានអី?

ហឿន៖ តវ៉ាម៉េច បើគេថាហែ្វងតែទៅនិយាយកន្លែងណា តែអញពុអត់បានទេ ។

ដានី៖ ពីណាគេនិយាយចឹង?

ហឿន៖ តាមុត! សំឡុតខ្ញុំចឹង និយាយធំណាស់ ។

ដានី៖ សំឡុតអ៊ំឆ្នាំណា?

ហឿន៖ ឆ្នាំ២០០០ ដែលគេហៅប៉ូលីស គេហៅមេជំទប់ មេភូមិអីគេមកហ្នឹង គេសំឡុតពេលហ្នឹង ហើយខ្ញុំថា ខ្ញុំមិនបានឲ្យទេ ដីហ្នឹងអឹងឯងឲ្យខ្ញុំឥឡូវអឹងឯងមកយក ត្រូវឲ្យថ្នូរអីមកខ្ញុំ ខ្ញុំថាអីចឹងហើយខ្ញុំចុះដើរចេញមកផ្ទះមក ។

ដានី៖ ហើយគាត់ថាម៉េច?

ហឿនៈ ខ្ញុំមកជុតទៅគេនៅជុំគ្នាហ្នឹងទៅ ខ្ញុំមកចេញ ខ្ញុំថាខ្ញុំអត់ឲ្យទេដីខ្ញុំខំធ្វើសុទ្ធតែមីន អឹងឯង កាលពេលអត់មនុស្សហៅខ្ញុំមកឲ្យ ដល់ពេលមានមនុស្សអឹងឯងដកដីខ្ញុំ ខ្ញុំមិនឲ្យខ្ញុំដើរចេញ មកផ្ទះមក ។

ដានីៈ រួចទៅគាត់ថាម៉េច?

ហឿនៈ អត់ថា អត់មាត់ត ។

ដានីៈ រួចចុះគាត់មានឲ្យថ្នូរអីអឺដែរអត់?

ហឿនៈ អត់មានថ្នូរមានឲ្យអីទេ អាកូនខ្ញុំពីនាក់ក៏អត់ដែរ យកទាំងស្រស់ម៉ង អាហ្នឹងលើកទី១ រឹបដីប្រជាជនធ្វើស្រែសហករណ៍ ដល់លើកទី២យកដីខ្ញុំធ្វើវត្ត ។ អាហ្នឹងលើកទី១ លើកទី២ ឥឡូវជិតដល់លើកទី៣ទៀតហើយ ។

ដានីៈ លើកទី៣យ៉ាងម៉េច?

ហឿនៈ លើកទី៣ យកដីគេក្បែរៗផ្ទះទាំងអស់ទៀត យកដីគេទាំងអស់ ហីដីកូនគាត់ឈ្មោះមីកាភាព ប្ដីវាឈ្មោះអាធន យកដីហ្នឹងទាស់គ្នាចុះឡើងជាមួយកូន ហីនឹងពុកហ្នឹង ដល់យូរទៅចាញ់កូន! ចាញ់កូនវាយដំបងយករហូត ។ ចែកឲ្យហើយយកវិញ វាថាចឹង ចែកឲ្យហើយយកវិញខ្ញុំអត់ឲ្យ វាលើករបងពីរបីដង ។

ដានីៈ ចុះតាមុត ប្រពន្ធគាត់ឈ្មោះអី?

ហឿនៈ ឈ្មោះយាយខា ដឹងស្អីខាទេ?

ដានីៈ យាយខា អ្នកស្រុកនៅ?

ហឿនៈ នៅស្រុកជាមួយគ្នាក្មួយគាត់ ។

ដានីៈ ក្មួយគាត់! គាត់យកក្មួយ ហើយគាត់មានកូនប៉ុន្មានអ្នក?

ហឿនៈ កូនអត់ដែលទៅជិតទេ ខ្ញុំស្អប់តាំងពីហ្នុងមក កូន៤, ៥នាក់នោះ ។

ដានីៈ ស្គាល់កូនទី១ឈ្មោះអី?

ហឿនៈ កូនទីមួយឈ្មោះមីកាភាពនោះ កូនជាមួយយាយខុម ។

ដានីៈ យាយខុម?

ហឿនៈ បាទ!

ដានីៈ ហើយកូនជាមួយយាយខុម មានតែមួយហ្នឹងទេ?

ហឿនៈ តែមួយហ្នឹង! អូ២ អាប្រុសមួយនៅខាងអន្ទង់ក្រកូននេះ ។

ដានីៈ ឈ្មោះអី?

ហឿនៈ រកនឹកមិនឃើញ! អាវុធ ឈ្មោះ អាវុធ ។

ដានីៈ ឈ្មោះ ភាពហើយហ្នឹង វុធហ្នឹង កូនជាមួយយាយខុម?

ហឿនៈ អាហ្នឹងកូនយាយខុមពីរហ្នឹង ។

ដានីៈ បានកូនក្រោយប៉ុន្មានទៀត?

ហឿនៈ កូនក្រោយអត់ដែលស្គាល់ទេ! កូនច្រើន៨, ៥នាក់ណុះ ។

ដានីៈ ៨,៥នាក់?

ហឿនៈ បាទ! អត់ដែលទៅជិត ទៅបៀតទេ ខ្ញុំស្អប់យកដីខ្ញុំ...។

ដានីៈ ស្អប់គាត់តាំងពីយកដីអ៊ឹមក អ៊ឹស្អប់គាត់តែម្ដង?

ហឿនៈ បាទ! តែមាត់រក ខ្ញុំលែងមាត់រក ។

ដានីៈ អត់ដែលនិយាយគ្នាទេអ៊ីចឹង?

ហឿនៈ អត់! អ៊ីចឹងបានពិម្សិលម្ងៃមកទិញនំយាយខ្ញុំ ខ្ញុំថាយាយឯងមាត់រកគាហ្នឹងដឹងបានគាហ្នឹង មកទិញ ថាអត់មានមាត់ទេ គាត់ចូលមកទិញ ទិញអស់៩០បាតដែរ ។

ដានីៈ ហើយគាត់មាននិយាយថាម៉េចអត់?

ហឿនៈ អត់បានសួរនិយាយអីៗទេ! ខ្ញុំគ្រាន់តែសួរមាត់រកអី បានជាគាត់មកទិញ ហើយខ្ញុំថា ទិញហ្នឹង បែបគេគិតកាត់ទោស បានជាមកទិញកុំអញនិយាយរឿងគាត់ហ្នឹង ខ្ញុំថាអ៊ីចឹង គេគិតកាត់ទោសមកនិយាយកុំឲ្យអញនិយាយពីរឿងគាត់ ។

ដានីៈ កាត់ទោសអីគេអ៊ឹដឹងរឿងគេកាត់ទោសយ៉ាងម៉េច?

ហឿនៈ កាត់ទោសរឿងខ្មែរក្រហម ។

ដានីៈ អ៊ឹដឹងដែរ?

ហឿនៈ ដឹង! គេសម្ភាសន៍ប៉ុន្មានដងហើយហ្នឹង ។

ដានីៈ គេសម្ភាសន៍ពីណា?

ហឿនៈ គេសម្ភាសន៍តាមុគហ្នឹង! ម៉ាយ៉ារិត មកសម្ភាសន៍ហ្នឹង ។

ដានីៈ ចុះអ៊ឹដែលពីណាមកសម្ភាសន៍អ៊ឹដែរទេ?

ហឿនៈ អត់ទេ! មានគាត់ម្ដងហ្នឹង ។

ដានីៈ មានតែខ្ញុំហ្នឹង មកលើកទីមួយ?

ហឿនៈ បាទ!

ដានី៖ បាទ! អឹដោយសារយប់ហើយឥឡូវខ្ញុំអគុណអ៊ឹច្រើន ដែលផ្ដល់ដូចថាចំណាយពេលខ្ញុំសម្ភាសន៍អ៊ឹនេះច្រើនដែរណាអ៊ឹ ។

ហឿន៖ បាទ!

ដានី៖ អ៊ីចឹងខ្ញុំអគុណអ៊ឹច្រើនណាអ៊ឹ!

«ចប់»